សមាសភាគកសាងផែនការបន្សាំ និងភាពធន់នៅតំបន់ឆ្នេរ

# ការវិភាគថ្លៃចំណាយនិងផលចំណេញនៃការកែប្រែទម្លាប់ក្នុង កសិកម្មសម្រាប់ឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុក្នុងតំបន់ឆ្នេរ




Cambodia Climate Change Alliance (CCCA)

Implemented by: Supported by:

Ministry of Environment

European Union

Empowered lives Resilient nations

Danida

SWEDEN

UNEP-DHI CENTRE
for Water and Environment

UNEP

DHI


២០១២

# បុព្វកថា

ខ្ញុំមានក្តីសោមនស្សរីករាយ សូមបង្ហាញរបាយការណ៍ ស្តីពីការវិភាគថ្លៃចំណាយនិងផលចំណេញនៃការកែប្រែ ទម្លាប់ក្នុងកសិកម្មសម្រាប់ឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុនៅតំបន់ឆ្នេរ ដែលជាសមិទ្ធផល នៃកិច្ចសហប្រតិបត្តិការប្រកបដោយ ផ្លែផ្កាវាងស្ថាប័នរដ្ឋ គ្រប់កំរិត ដូចជា ថ្នាក់ខេត្ត ស្រុក និងអង្គការមិនមែន រដ្ឋាភិបាលផ្សេងៗ គម្រោង និងកម្មវិធី ដែលទាក់ទងជាមួយការអភិវឌ្ឍន៍តំបន់ឆ្នេរ និងការប្រែប្រួលអាកាសធាតុ។ របាយការណ៍នេះ នឹងរៀបរាប់សង្ខេបពីសកម្មភាពអនុវត្តគម្រោង និង វិធីសាស្ត្រ ដើម្បីបញ្ជ្រាបសកម្មភាពនិងវិធីសាស្ត្រការបន្សាំការប្រែប្រួលអាកាសធាតុនៅថ្នាក់ក្រោមជាតិ និងរៀបចំ រចនាសម្ព័ន្ធ និងកសាងសមត្ថភាព ដើម្បីអនុវត្តន៍វិធានការបន្សាំការប្រែប្រួលអាកាសធាតុ ។

របាយការណ៍នេះ ផ្តោតលើការវិភាគថ្លៃចំណាយនិងផលចំណេញនៃការកែប្រែទម្លាប់ក្នុងកសិកម្មដើម្បីឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុនៅតំបន់ឆ្នេរ ដើម្បីបង្កើតការជ្រើសរើស ដែលភាពធន់នឹងការប្រែប្រួលអាកាសធាតុ និងផ្តល់នូវប្រាក់ចំណូលខ្ពស់ដល់សហគមន៍បន្សាំនឹងការផ្លាស់ប្តូរទម្លាប់។ ការវិភាគលើបញ្ហាសកម្មភាពជីវភាពរស់នៅសំខាន់ៗនៅតំបន់គោលដៅអនុវត្តគម្រោងក្នុងឃុំចំនួន០៦ ក្នុងស្រុកព្រៃនប់ ខេត្តព្រះសីហនុ និងឃុំចំនួន០២ នៅស្រុកមណ្ឌលសីមា ខេត្តកោះកុង។ របាយការណ៍នេះ រៀបចំឡើងដោយយោងតាមរបាយការណ៍ដែលទទួលបានតាមរយៈការធ្វើសម្ភាសន៍តាមឃុំដែលបានជ្រើសរើស និងបង្ហាញទស្សនៈទូលំទូលាយអំពីវិធីមធ្យោបាយរបស់សហគមន៍ អាចបន្សាំនឹងការប្រែប្រួលអាកាសធាតុ និងនៅពេលជាមួយគ្នាអាចកែលម្អជីវភាពរស់នៅបាន ។ ការវិភាគថ្លៃចំណាយនិងផលចំណេញបានអនុវត្តលើសមកម្មភាពជីវភាពរស់នៅចំនួន ០៦ សកម្មភាព ។

ភាពសម្បូណ៌បែបនៃធនធានធម្មជាតិ និងបរិស្ថាននៅតំបន់ឆ្នេរសមុទ្រកម្ពុជា បានរងផលប៉ះពាល់រយៈពេលជាច្រើនឆ្នាំពីសកម្មភាពអភិវឌ្ឍន៍។ លើសពីនេះទៀត ការប្រែប្រួលអាកាសធាតុក៏បង្កឲ្យមានផលប៉ះពាល់ដល់ជីវភាពរស់នៅតំបន់ឆ្នេរសមុទ្រ ជាពិសេសតំបន់ទំនាបដូចជា ទឹកជំនន់ ការជ្រាបចូលទឹកសមុទ្រ និងការហូរច្រោះឆ្នេរ ។ សេចក្តីត្រូវការលើការកែលម្អលើការគ្រប់គ្រង គឺដើម្បីធានាដល់ការកែលម្អដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គម នៅក្នុងតំបន់ដោយមិនបង្កឲ្យមានផលប៉ះពាល់ដល់ធនធានធម្មជាតិ និងបរិស្ថាន ជាពិសេសវាជាការបន្ទាន់ទាក់ទងនឹងផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុចំពោះជីវភាពរស់នៅនាពេល បច្ចុប្បន្នដែលសហគមន៍តំបន់ឆ្នេរកំពុងតែបង្កើតការបន្សាំ និងបង្កើនភាពធន់ដល់សហគមន៍។ នៅពេលជាមួយគ្នា វាអាចប្រើប្រាស់សម្រាប់អនុវត្ត និងពង្រីកទៅផ្នែក ដ៏ទៃទៀតនៅតំបន់ឆ្នេរ និងខេត្តដ៏ទៃទៀត ។

របាយការណ៍នេះ មានសារៈសំខាន់ចំពោះអាជ្ញាធរឃុំ ស្រុក និងខេត្ត ព្រមទាំងមន្ទីរជំនាញនៅក្នុងខេត្តនៅតំបន់ឆ្នេរសមុទ្រកម្ពុជា ដើម្បីដោះស្រាយបញ្ហាស្មុគស្មាញទាក់ទងនឹងការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គម និងការប្រែប្រួលអាកាសធាតុ ការគ្រប់គ្រងបរិស្ថាន និងធនធានធម្មជាតិ ប្រកបដោយចីរភាព ។ របាយការណ៍ នេះ នឹងបង្ហាញពីសារប្រយោជន៍ដល់អ្នកអាន មានដូចជា អ្នករៀបចំ

គោលនយោបាយនៅថ្នាក់ជាតិ អ្នកធ្វើផែនការ និងស្ថាប័នរដ្ឋ អង្គការមិនមែនរដ្ឋាភិបាល គម្រោងផ្សេងៗ និងផ្នែកឯកជន ព្រមទាំងជាមូលដ្ឋាន ដល់ការអប់រំ ការស្រាវជ្រាវផងដែរ ។

ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា អ្នកអានទាំងអស់នឹងស្វែងយល់ពីរបាយការណ៍នេះ ដែលជាធនធានដ៏មាន តម្លៃសម្រាប់ការងារការប្រែប្រួលអាកាសធាតុនៅកម្ពុជា ។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០១៤

**អគ្គនាយកបច្ចេកទេស**

**និងជាប្រធានគណៈកម្មាធិការដឹកនាំគម្រោង**

**វេជ្ជ. ឡុញ ហ៊ាល**

# សេចក្តីថ្លែងអំណរគុណ

របាយការណ៍ការវិភាគថ្លៃចំណាយនិងផលចំណេញ នៃការកែប្រែទម្លាប់ក្នុងកសិកម្មសម្រាប់ឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុក្នុងតំបន់ឆ្នេរនេះ ត្រូវបានរៀបរៀងឡើងនៅក្រោមសមាសភាគកសាងផែនការបន្សុាំ និងភាពធន់ក្នុងតំបន់ឆ្នេរសមុទ្រកម្ពុជា ក្រោមកម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា។ របកគំហើញក្នុងរបាយការណ៍នេះ បានផ្អែកលើមេរៀននានា ដែលទទួលបានពីសកម្មភាពដែលអនុវត្តនៅក្រោមសមាសភាគនេះ។

តាងនាមឲ្យក្រុមការងារតំបន់ឆ្នេរសមុទ្រកម្ពុជា ខ្ញុំបាទសូមសំដែងការដឹងគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះឯកឧត្តម **សាយ សំអាល់** រដ្ឋមន្ត្រីក្រសួងបរិស្ថាន និងជាអនុប្រធានគណៈកម្មាធិការជាតិគ្រប់គ្រង និងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា ដែលតែងតែជម្រុញ ណែនាំ និងគាំទ្រយ៉ាងខ្លាំងក្លាដល់កិច្ចប្រឹងប្រែងរបស់ក្រុមការងារ ដើម្បីសម្រេចបានរបាយការណ៍នេះ។ ខ្ញុំក៏សូមថ្លែងអំណរគុណដល់ឯកឧត្តម លោក លោកស្រី ជាសមាជិកគណៈកម្មាធិការដឹកនាំគម្រោង ក្រុមការងារជនបង្គោលថ្នាក់ជាតិ ក្រុមការងារបច្ចេកទេសថ្នាក់ខេត្ត ទីប្រឹក្សាជាតិ និងអន្តរជាតិ រួមទាំងភាគីពាក់ព័ន្ធទាំងអស់ ដែលបានរួមចំណែកផ្តល់មតិល្អៗ ចំពោះការចងក្រងរបាយការណ៍នេះ ។

ជាចុងក្រោយ សូមថ្លែងអំណរគុណដល់កម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា ចំពោះការឧបត្ថម្ភគាំទ្រដល់សមាសភាគកសាងផែនការ និងភាពធន់ដល់ប្រែប្រួលអាកាសធាតុនៅតំបន់ឆ្នេរសមុទ្រកម្ពុជា តាមរយៈភ្នាក់ងារអនុវត្ត DHI សហការល្អជាមួយក្រសួងបរិស្ថាន។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០១៤

**គណៈកម្មាធិការដឹកនាំគម្រោង**

**អនុប្រធានអចិន្ត្រៃយ៍**

**បណ្ឌិត វ៉ាន់ មុនីនាថ**

# ពាក្យបំព្រួញ និងអក្សរកាត់

| | | |
|---|---|---|
| ADB | Asian Development Bank | ធនាគារអភិវឌ្ឍន៍អាស៊ី |
| AEA | Agro-Ecological Systems Analysis | ការវិភាគប្រព័ន្ធកសិអេកូឡូស៊ី ក្សេត្របរិស្ថាន |
| AFD | The Agence Française de Développement | ទីភ្នាក់ងារបារាំងដើម្បីអភិវឌ្ឍន៍ |
| AGM | Annual General Meeting | សន្និបាតប្រចាំឆ្នាំ |
| ASSP | Agricultural Sector Support Programme | កម្មវិធីទ្រទ្រង់វិស័យកសិកម្ម |
| CARDI | Cambodian Agricultural Research and Development Institute | វិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា |
| CARP | Coastal Adaptation and Resilience Planning Component | សមាសភាគកសាងផែនការបន្សាំនិងធន់នៅក្នុងតំបន់ឆ្នេរ |
| CBO | Community Based Organisation | អង្គការសហគមន៍ |
| CCCA | Cambodia Climate Change Alliance | សម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា |
| CDP | Commune Development Plan | ផែនការអភិវឌ្ឍន៍ឃុំ |
| CF | Community Fisheries | សហគមន៍នេសាទ |
| CFO | Community-based Fisheries Organisation | អង្គការសហគមន៍នេសាទ |
| DAE | Department of Agricultural Extension, MAFF | នាយកដ្ឋានផ្សព្វផ្សាយកសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| DAHP | Department of Animal Health and Production | នាយកដ្ឋានផលិតកម្មនិងបសុព្យាបាល |
| Danida | Danish International Development Assistance | ជំនួយអភិវឌ្ឍន៍អន្តរជាតិប្រទេសដាណឺម៉ាក់ |
| EU | European Union | សហភាពអឺរ៉ុប |
| FFD | Farmer Field Day | ទិវាស្រែកសិករ |
| FFS | Farmer Field Schools | សាលាស្រែកសិករ |
| FiA | Fisheries Administration | រដ្ឋបាលជលផល |
| FO | Farmer Organisation | អង្គការកសិករ |
| GEF | Global Environment Facility | មូលនិធិបរិស្ថានពិភពលោក |
| HH | Household | គ្រួសារ/ខ្នងផ្ទះ |
| IFAD | International Fund for Agricultural Development | មូលនិធិអន្តរជាតិសម្រាប់អភិវឌ្ឍន៍កសិកម្ម |
| IPM | Integrated Pest Management | វិធានការចម្រុះការពារដំណាំ |
| IRR | Internal Rate of Return | អត្រាចំណូលផ្ទៃក្នុង |

| | | |
|---|---|---|
| IUU | Illegal, Unreported and Unregulated | មិនស្របច្បាប់ មិនរាយការណ៍ និងគ្មានការទប់ស្កាត់ |
| JICA | Japan International Cooperation Agency | ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន |
| KK | Kohkong | កោះកុង |
| MAFF | Ministry of Agriculture, Forestry and Fisheries | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| MCS | Monitoring, Control and Surveillance | ការតាមដាន ត្រួតពិនិត្យ និងឃ្លាំមើល |
| MoE | Ministry of Environment | ក្រសួងបរិស្ថាន |
| MoWRAM | Ministry of Water Resources and Meterology | ក្រសួងធនធានទឹក និងឧតុនិយម |
| NAPA | National Adaptation Program of Actions to Climate Change | កម្មវិធីសកម្មភាពជាតិបន្សាំនឹងការប្រែប្រួលអាកាសធាតុ |
| NCCC | National Climate Change Committee | គណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ |
| NGO | Non-Governmental Organisation | អង្គការមិនមែនរដ្ឋាភិបាល |
| NPV | Net Present Values | តម្លៃបច្ចុប្បន្នសុទ្ធ |
| NRM | Natural Resource management | ការគ្រប់គ្រងធនធានធម្មជាតិ |
| OFAT | On-Farm Adaptive Trials | ការសាកល្បងបន្សាំនៅតាមកសិដ្ឋាន |
| PDA | Provincial Directorates of Agriculture | មន្ទីរកសិកម្មខេត្ត |
| PDWRAM | Provincial Department of Water Resources and Meterology | មន្ទីរធនធានទឹកនិងឧតុនិយម |
| PFiA | Provincial Fisheries Administration | ខណ្ឌរដ្ឋបាលជលផល |
| PRA | Participatory Rural Appraisal | ការវាយតម្លៃជនបទតាមបែបចូលរួម |
| RGC | Royal Government of Cambodia | រាជរដ្ឋាភិបាលកម្ពុជា |
| SHV | Sihanoukville | ក្រុងព្រះសីហនុ |
| SLPP | Smallholder Livestock Production Programme | កម្មវិធីផលិតកម្មសត្វតាមគ្រួសារ |
| SLR | Sea Level Rise | កំណើនកំពស់ទឹកសមុទ្រ |
| ST | Short Term | រយៈពេលខ្លី |
| TOT | Training of Trainers | ការបណ្តុះបណ្តាលគ្រូបង្គោល |
| UNDP | United Nations Development Programme | កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ |
| VAHW | Village Animal Health Worker | បុគ្គលិកសុខភាពសត្វភូមិ |

# សេចក្តីសង្ខេបប្រតិបត្តិ

របាយការណ៍នេះគឺជា*ការវិភាគការចំណាយ និងផលចំណេញខាងសេដ្ឋកិច្ច និងសង្គម នូវជម្រើសនានានៃទម្លាប់ក្នុងកសិកម្មដែលកែសម្រួល និងដែលមិនសូវងាយរងគ្រោះចំពោះផលប៉ះពាល់ នៃវិសម្ភាពអាកាសធាតុ និងការប្រែប្រួលអាកាសធាតុ*។ ការវាយតម្លៃនេះបានធ្វើឡើងជាផ្នែកមួយនៃលទ្ធផល ២.៥ នៃ CARP ។

វិធីសាស្ត្រដែលយកមកប្រើប្រាស់គឺការគណនា និងវិភាគទិន្នន័យសេដ្ឋកិច្ចតាមគ្រួសារ/កសិដ្ឋាននៃទម្លាប់អនុវត្តក្នុងកសិកម្ម ដោយប្រើប្រាស់វិធីសាស្ត្រផលចំណេញដុលដែលត្រូវគេស្គាល់ជាទូទៅ។ ការគណនាទាំងនេះមានបង្ហាញពិស្តារជាតម្លៃបច្ចុប្បន្នសុទ្ធ (NPV) និងអត្រាចំណូលផ្ទៃក្នុង (IRR) សម្រាប់សកម្មភាពអនុវត្តបង្ហាញដែលបានលើកស្នើឡើងនីមួយៗ។ លើសពីនេះ ការចំណាយ និងផលចំណេញសង្គមជាទ្រង់ទ្រាយអរូបីយ៍ ក៏ត្រូវបានពិចារណាផងដែរ។

ទីតាំងដូចខាងក្រោមនេះត្រូវបានជ្រើសយកសម្រាប់ជាសហគមន៍គោលដៅ៖

- ឃុំទឹកថ្លា ទឹកល្អក់ ព្រៃនប់ ទួលទទឹង អូរឧកញ៉ាហេង ស្រុកព្រៃនប់ ខេត្តព្រះសីហនុ
- ឃុំព្រៃនប់ និងទួលគរគី ស្រុកមណ្ឌលសីមា ខេត្តកោះកុង

### ទិដ្ឋភាពរួមនៃសកម្មភាពអនុវត្តបង្ហាញដែលបានស្នើឡើង

សកម្មភាពដែលបានជ្រើសយកចំនួនប្រាំដូចខាងក្រោមនេះស្ថិតក្នុងការវិភាគសេដ្ឋកិច្ច៖

១. កម្មវិធីបណ្តុះបណ្តាលកសិកម្មចម្រុះដល់(ក)បុគ្គលិកផ្សព្វផ្សាយកសិកម្មនិង(ខ)គ្រួសារ/ខ្នងផ្ទះ នៅក្នុងយុទ្ធសាស្ត្របន្សុាំនឹងការប្រែប្រួលអាកាសធាតុនិងផលិតកម្មចម្រុះ(រួមបញ្ចូលដំណាំ សត្វចិញ្ចឹម ត្រី ទឹក)នៅក្នុងឃុំគោលដៅ។ មុននេះមានការវិភាគក្សេត្រប្រព័ន្ធដែលជាផ្នែករួមមួយនៃកម្មវិធីនេះ។

២. គម្រោងសហគមន៍នេសាទនៅពាមក្រសោប ក្រោមកិច្ចសហការជាមួយរដ្ឋបាលជលផល ជាពិសេសដើម្បីពង្រឹងវិធានការច្បាប់ និងពង្រឹងការអនុវត្ត។ ទំនាក់ទំនងរវាងសហគមន៍នេសាទជាមួយការបន្សុាំនឹងការប្រែប្រួលអាកាសធាតុបង្ហាញថា ការអភិវឌ្ឍការនេសាទជាទូទៅ និងវិធានការច្បាប់ ទំនងជាត្រូវការឲ្យកែសម្រួលមុខរបររបស់សហគមន៍អ្នកនេសាទ។

៣. ការលើកកំពស់ និងបង្កើនវត្តមានពូជដំណាំដែលឆាប់ផ្តល់ផល ជាពិសេស ស្រូវស្រាលរដូវវស្សា អាចសម្រួលដល់ការប្រមូលផលមុនពេលទឹកជំនន់ធំមកដល់ និងការឡើងកំពស់ទឹកសមុទ្រនៅក្នុងឃុំគោលដៅ។ គេត្រូវសាកល្បងពូជដំណាំបែបនេះ(ដោយកសិករមិនមែនជាអ្នកបង់ខាត)នៅក្នុងទីតាំងជាក់លាក់ ដែលទំនងជាមានប្រសិទ្ធភាព។

៤. លើកកំពស់ការចិញ្ចឹមសត្វនៅក្នុងឃុំចំនួន ៧ ដោយប្រើប្រាស់ប្រព័ន្ធកែលម្អពូជជាបន្តបន្ទាប់ - បានសាកល្បងដោយជោគជ័យនៅកម្ពុជា ឡាវ និងកន្លែងដទៃ។ នេះជាវិធានការឆ្លើយតបទៅនឹងបញ្ហាទឹកជំនន់ ដោយសារគេអាចចល័តសត្វចិញ្ចឹមបាន។

៥. លើកកំពស់ការអភិរក្សទឹកនៅក្នុងស្រែ ការរក្សាទឹកភ្លៀងទុកក្នុងកសិដ្ឋាននិងវិធីស្រោចស្រពខ្នាតតូច។

៦. គម្រោងសហគមន៍ព្រៃឈើនៅទួលគរគីក្រោមកិច្ចសហការជាមួយរដ្ឋបាលព្រៃឈើ។ ព័ត៌មានអំពីគម្រោងនេះពុំមានគ្រប់គ្រាន់សម្រាប់កំណត់ថ្លៃចំណាយ និងរៀបចំការវិភាគការចំណាយនិងផលចំណេញឡើយ។

៧. ពង្រឹងការថែទាំទំនប់សហគមន៍ ការគ្រប់គ្រងប្រព័ន្ធដោះទឹកនិងប្រព័ន្ធស្រោចស្រពក្រោមកិច្ចសហការជាមួយក្រសួងធនធានទឹកនិងឧតុនិយម - សម្រាប់ព្រែនប់ និងទួលគរគី។ ព័ត៌មានអំពីគម្រោងនេះពុំមានគ្រប់គ្រាន់សម្រាប់កំណត់ថ្លៃចំណាយ និងរៀបចំការវិភាគថ្លៃចំណាយនិងផលចំណេញឡើយ។

**សេចក្តីសង្ខេបការប៉ាន់ស្មានចំណាយសម្រាប់អនុវត្តសកម្មភាពក្នុងសមាសភាគ CARP**

| សកម្មភាព | សេចក្តីពិពណ៌នា | ចំនួន ($) |
|---|---|---|
| **សកម្មភាព ១** | កម្មវិធីបណ្តុះបណ្តាលកសិករអំពីការបន្សាំនឹងការប្រែប្រួលអាកាសធាតុ និងផលិតកម្មចម្រុះក្នុងឃុំចំនួន ៧ | ២២៥.០០០ |
| **សកម្មភាព ២** | គម្រោងសហគមន៍នេសាទនៅពាមក្រសោប ខេត្តកោះកុង | ៨០.០០០ |
| **សកម្មភាព ៣** | ការសាកល្បងពូជដំណាំតាមកសិដ្ឋាន ការអនុវត្តបង្ហាញ និងការបណ្តុះបណ្តាលអំពីការជ្រើសរើសពូជក្នុងឃុំចំនួន ៧ | ៣២.០០០ |
| **សកម្មភាព ៤** | ប្រព័ន្ធចិញ្ចឹមសត្វដោយបន្តប្រើប្រាស់ពូជក្នុងឃុំចំនួន ៧ | ១៧៥.០០០ |
| **សកម្មភាព ៥** | ការសាកល្បងតាមកសិដ្ឋានអំពីការគ្រប់គ្រងទឹក ការរក្សាទុកទឹក និងប្រព័ន្ធស្រោចស្រពខ្នាតតូច | ៥០.០០០ |
| **សរុប** | | ៥៦២.០០០ |

ការអនុវត្តបង្ហាញសកម្មភាព ១-៥ ដូចដែលបានកត់សំគាល់ សុទ្ធតែផ្តល់ផលចំណេញខាងសេដ្ឋកិច្ចទាំងសម្រាប់ CARP និងគ្រួសារដែលចូលរួម។ ការគណនាបង្ហាញពីភាពរឹងមាំ និងទំនងជារក្សាបានផលចំណេញកម្រិតខ្ពស់ សូម្បីអត្រាសន្មតិនៃកម្រិតប្រាក់ចំណូលនិងការបន្សាំមានកម្រិតទាបជាងការរំពឹងទុកក៏ដោយ។

**ការចំណាយ និងផលប្រយោជន៍ខាងសង្គម**

ការអនុវត្តបង្ហាញសកម្មភាពនានាដែលបានស្នើឡើង សុទ្ធតែស្របគ្នាជាមួយអាទិភាពដែលតំណាងសហគមន៍បានលើកឡើង និងពង្រឹងយុទ្ធសាស្ត្រដោះទ័លដែលមានបច្ចុប្បន្នរបស់ពួកគេ។ ដូច្នេះ ការចំណាយខាងសង្គមមានកម្រិតទាបណាស់ ប៉ុន្តែផ្តល់ផលចំណេញច្រើនពាក់ព័ន្ធនឹងសកម្មភាពដែលស្នើឡើងដោយសារសកម្មភាពដែលស្នើឡើងគាំទ្រដល់អាទិភាពដែលសហគមន៍បានលើកឡើង។ ក្រៅពីនេះ មានផលប្រយោជន៍បន្ថែមទៀតដែលលំបាកក្នុងការគណនា។

ការកាត់បន្ថយសម្ពាធមកលើបរិស្ថាន ក៏ដូចជា សុខភាពសត្វ និងមនុស្សតាមរយៈការលើកកំពស់បច្ចេកវិទ្យានៃវិធានការចម្រុះគ្រប់គ្រងដំណាំ (IPM)។ ការជម្រុញផលិតកម្មបន្លែ និងសត្វ ទំនងជានឹងលើកកំពស់អាហារូបត្ថម្ភ ក៏ដូចជាប្រាក់ចំណូលផងដែរ។

## បញ្ហាស្ថាប័ន

ការអនុវត្តរាល់សកម្មភាពដែលបានលើកស្នើឡើង អាស្រ័យលើកិច្ចសហប្រតិបត្តិការរលូនរវាង CARP, MoE និងស្ថាប័នផ្សេងទៀតនៃរាជរដ្ឋាភិបាលកម្ពុជា–ជាពិសេស ស្ថាប័នចំណុះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (MAFF) ដែលរួមទាំងមន្ទីរ កសិកម្ម ខណ្ឌរដ្ឋបាលជលផល និងមន្ទីរធនធានទឹកនិងឧតុនិយម។

នៅក្នុងស្ថាប័នដែលបានកត់សំគាល់ខាងលើ សមត្ថភាពសម្រាប់ប្រតិបត្តិការអាចមានកម្រិតកំណត់។ ដូច្នេះ ការពិគ្រោះយោបល់ និងការពិភាក្សាទាន់ពេលវេលាអំពីតួនាទី និងការទទួលខុសត្រូវ ដែលទាក់ទងនឹងការអនុវត្តពិតជាមានសារៈសំខាន់ជាទីបំផុត។

## វត្តមានពេលវេលាខ្លីសម្រាប់ការអនុវត្ត

សមាសភាគ CARP គ្រោងនឹងបញ្ចប់នៅចុងត្រីមាសទី១ ឆ្នាំ ២០១៤។ ដូច្នេះ អាចមានពេលត្រឹមតែមួយរដូវបង្កបង្កើនផលតែប៉ុណ្ណោះ (រដូវវស្សាឆ្នាំ ២០១៣) សម្រាប់សកម្មភាពអនុវត្តបង្ហាញ។ នេះមិនមែនជាស្ថានភាពល្អឡើយ ដោយសាររាល់សកម្មភាពអនុវត្ត អាចទទួលផលប្រយោជន៍ពីវត្តមានសមាសភាគនេះ ទាក់ទងនឹងសកម្មភាពបន្ត និងការពង្រឹងជាបន្ថែម។

ក្នុងចំណោមសកម្មភាពដែលលើកស្នើទាំង ៥ ដែលត្រូវវិភាគសេដ្ឋកិច្ច សកម្មភាព ១,៣ និង៥ ត្រូវបានចាត់ទុកថាមិនអាស្រ័យជាសំខាន់លើរយៈពេលខ្លីនៃការគាំទ្រនេះឡើយ ដោយសារតែតាមធម្មតា មធ្យោបាយបឋម( សាលាស្រែកសិករ ) ដំណើរការខ្លាំងក្លាបំផុតតែត្រឹមមួយរដូវប៉ុណ្ណោះក្នុងទីតាំងនីមួយៗ។

ទាំងសកម្មភាព ២ និង៤ ពឹងផ្អែកច្រើនលើសកម្មភាពបន្តឲ្យបានគ្រប់គ្រាន់ និងសកម្មភាពពង្រឹងនៅក្រោយការអនុវត្តក្នុងឆ្នាំដំបូង។ ដូច្នេះ ឥទ្ធិពលមកលើផលចំណូលនៅពាមក្រសោប ត្រូវគេរំពឹងថានឹងអាចកើតមានពេញលេញនៅក្រោយរយៈពេល ៥ ឆ្នាំ ចំណែកប្រព័ន្ធចិញ្ចឹមសត្វត្រូវគេរំពឹងថានឹងមានអ្នកបន្តចូលរួមកាន់តែច្រើនសម្រាប់រយៈពេលបីឆ្នាំឬច្រើនជាងនេះ។ *ដូច្នេះ សកម្មភាពទាំងនេះប្រឈមហានិភ័យច្រើនដោយសារត្រូវការឲ្យមានសកម្មភាពបន្ត និងការពង្រឹងបន្ថែម។*

ការប៉ាន់ស្មានថ្លៃចំណាយសម្រាប់សកម្មភាពភាគច្រើន រួមបញ្ចូលការគិតគូរអំពីលក្ខខណ្ឌបន្ត និងការពង្រឹងបន្ថែមទាំងនេះ ដោយលៃទុកសាច់ប្រាក់សម្រាប់ឃុំនីមួយៗ ដើម្បីអនុវត្តសកម្មភាពបែបនេះជាបន្ត។ ការលៃទុកបែបនេះអាចធ្វើឡើង តាមរយៈការចាត់ចែងរបស់ក្រុមប្រឹក្សាឃុំក្នុងការជួលបុគ្គលិកផ្សព្វផ្សាយនៅថ្នាក់ឃុំ ឧទា.សម្រាប់រយៈពេល ៣ឆ្នាំ ដែលរួមទាំង ការផ្តល់ការងារពេញម៉ោងជាបន្ត ប្រសិនបើសកម្មភាពនេះផ្តល់ផលល្អ និងបើក្រុមប្រឹក្សាឃុំមានមូលនិធិសម្រាប់បំពេញថ្លៃចំណាយនេះ។

ក្នុងន័យសេដ្ឋកិច្ច ការប្រៀបធៀបសកម្មភាពអនុវត្តបង្ហាញដែលបានវិភាគមានដូចតទៅ៖

## ការប្រៀបធៀបផលចំណេញខាងសេដ្ឋកិច្ច

| សកម្មភាពសាកល្បង | ផ្តល់ផលផ្ទាល់ដល់គ្រួសារនានា | អត្រាចំណូលផ្ទៃក្នុង | តម្លៃបច្ចុប្បន្នសុទ្ធនៃការវិនិយោគ[1] | ផលចំណេញក្នុងគ្រួសារនីមួយៗ |
|---|---|---|---|---|
| ១និង៣៖ FFS | ១២០០ | ១៩៣ % | $១,៧លាន | $១៤១៧ |
| ២៖ ពាមក្រសោប | ២៧៧ | ៦០% | $០,៥លាន | $១៨០៦ |
| ៤. ការចិញ្ចឹមសត្វ | ៦០០ | ៣១% | $០,៣លាន | $៥០០ |
| ៥. ការរក្សាទឹកទុក | ២០០ | ៥៦% | $ ០,១លាន | $៥០០ |

ជាការច្បាស់ណាស់ថាសកម្មភាពអនុវត្តបង្ហាញទាំង៥ នៅក្នុងការវិភាគសេដ្ឋកិច្ចនេះត្រូវបានចាត់ទុកថាជាបេក្ខភាពពិតប្រាកដសម្រាប់ការអនុវត្ត ដោយសារវាសុទ្ធតែជាការវិនិយោគដែលផ្តល់ផលចំណេញ។ នៅក្នុងករណីដែលមានមូលនិធិក្នុងកម្រិតកំណត់ សកម្មភាពអនុវត្តបង្ហាញរួមគ្នា ១ និង៣ គួរតែបានលើកយកមកអនុវត្ត បន្ទាប់មកសកម្មភាព ២ ពោលគឺ គម្រោងសហគមន៍នេសាទនៅពាមក្រសោបដែលជាអាទិភាពទី ២។ គេគួរតែរួមបញ្ចូលផងដែរនូវសកម្មភាព ៥ ជាមួយសកម្មភាព ១ និង៣។ ប្រសិនបើមានធនធានគ្រប់គ្រាន់សម្រាប់ការវិនិយោគបន្ថែម គេគួរអនុវត្តសកម្មភាពទី ៤ ផងដែរ។

សកម្មភាពខាងដើម ដែលរួមទាំង ការពិចារណាក្រៅពីកត្តាសេដ្ឋកិច្ច នាំមកនូវអនុសាសន៍ដូចតទៅ៖

១. អនុវត្តរួមគ្នាសកម្មភាព ១, ៣ និង៥៖ ការប្រែប្រួលអាកាសធាតុ និងផលិតកម្មចម្រុះ ការអនុវត្តបង្ហាញពូជដំណាំរយៈពេលខ្លី និងការអនុវត្តបង្ហាញពីការរក្សាទឹកទុកក្នុងស្រែ ដែលជាសកម្មភាពមួយ ប៉ុន្តែនៅក្រោមកិច្ចសន្យាដាច់ដោយឡែកពីគ្នាជាមួយ **DAE/PDA, CARDI / PDA និង PDWRAM**។

២. ពិចារណាអនុវត្តសកម្មភាព ២៖ ការអភិវឌ្ឍសហគមន៍នេសាទពាមក្រសោប ក្នុងករណីដែលមានការធានាពីក្រុមប្រឹក្សាឃុំ ក៏ដូចជា ពីស្ថាប័នគ្រប់គ្រងឧទ្យានជាតិ និងរដ្ឋបាលជលផល ទាក់ទងនឹងសកម្មភាពបន្ត និងពង្រឹងបន្ថែមនៅក្រោយឆ្នាំ ២០១៤។ ចំណុចនេះអាចរាប់បញ្ចូលការសន្យាផ្តល់មូលនិធិមួយចំនួនពីសហគមន៍ពាមក្រសោបផងដែរ។

៣. ពិចារណាអនុវត្តសកម្មភាព ៤ (ប្រព័ន្ធមូលនិធិបង្វិលដើម្បីចិញ្ចឹមសត្វដោយផ្តល់ពូជជាបន្តទៅកសិករដទៃ) ប្រសិនបើមានអង្គការមិនមែនរដ្ឋាភិបាលសមស្រប ឬ ភ្នាក់ងារប្រហែលគ្នានេះ សម្រាប់អនុវត្ត និងបន្តសកម្មភាពនេះ។

៤. ពិចារណាអនុវត្តសកម្មភាព ៦-៧ ក្រោយមានការពិគ្រោះយោបល់បន្ថែមជាមួយអង្គការដៃគូ។

[1] តួលេខទាបនៃ NPV (NPV(១០%)) ត្រូវបានជ្រើសយកសម្រាប់ការបង្ហាញនេះ។

បច្ចុប្បន្ន រាល់ចំណុចខាងលើនេះស្ថិតក្នុងការពិគ្រោះយោបល់ និងចរចាបន្ថែមទៀតជាមួយស្ថាប័នដែលមានបំណងធ្វើជាដៃគូ។ ឧទា. ជាការច្បាស់ណាស់ថា សកម្មភាព១ គួរតែបានចាប់ផ្តើមអនុវត្តនៅតាមមូលដ្ឋាន មិនឲ្យយឺតជាងថ្ងៃទី០១ ខែមករា ឆ្នាំ២០១៣ ដើម្បីត្រៀមខ្លួនជាស្រេចសម្រាប់អនុវត្តសកម្មភាពចំបងៗ (សាលាស្រែកសិករ) នៅខែ មេសា ឆ្នាំ ២០១៣។

ការពិគ្រោះយោបល់ និងការចរចាទាំងនេះអាចបង្ហាញពីតម្រូវការឲ្យមានការកែលម្អទិដ្ឋភាព និងអនុសាសន៍ខ្លះៗសម្រាប់ស្ថាប័នដែលមានសក្តានុពលជាដៃគូ។

# មាតិកា

**បុព្វកថា** ........ i
**សេចក្តីថ្លែងអំណរគុណ** ........ iii
**ពាក្យបំព្រួញ និងអក្សរកាត់** ........ viii
**សេចក្តីសង្ខេបប្រតិបត្តិ** ........ ix
ទិដ្ឋភាពរួមនៃសកម្មភាពអនុវត្តបង្ហាញដែលបានស្នើឡើង ........ ix
**១. សេចក្តីផ្តើម** ........ ១
១.១វិធីសាស្រ្តនិងទិន្នន័យ ........ ២
**២. តំបន់ឆ្នេរ** ........ ៤
២.១សហគមន៍គោលដៅ ........ ៥
**៣. សកម្មភាពអនុវត្តបង្ហាញអំពីទម្លាប់កសិកម្មដែលកែប្រែ** ........ ៧
៣.១ទិដ្ឋភាពរួមនៃសកម្មភាពអនុវត្តបង្ហាញដែលបានលើកស្នើ ........ ៧
៣.២ទម្រង់រួមនិងការប៉ាន់ស្មានថ្លៃចំណាយ ........ ៩
**៤. ការវិភាគថ្លៃចំណាយនិងផលចំណេញ** ........ ៤២
៤.១ការវិភាគសេដ្ឋកិច្ចសម្រាប់សកម្មភាព១និង៣ ........ ៤៣
៤.២ការវិភាគសេដ្ឋកិច្ចសម្រាប់សកម្មភាពបង្ហាញ២ ........ ៤៩
៤.៣ការវិភាគសេដ្ឋកិច្ចសម្រាប់សកម្មភាពបង្ហាញ៤ ........ ៥២
៤.៤ការវិភាគសេដ្ឋកិច្ចសម្រាប់សកម្មភាពសាកល្បង៥ ........ ៥៥
៤.៥សង្ខេបអំពីការគិតគូរផ្សេងទៀត ........ ៥៨
**៥. សេចក្តីសន្និដ្ឋាននិងអនុសាសន៍** ........ ៦០
៥.១អនុសាសន៍ ........ ៦១
**តារាងឯកសារយោង** ........ ៦២
**ឧបសម្ព័ន្ធ**
ឧបសម្ព័ន្ធ ១៖ លក្ខខណ្ឌប្រតិបត្តិ ក្រុមការងារគម្រោង កម្មវិធីនិងបុគ្គលដែលបានជួប
ឧបសម្ព័ន្ធ ២៖ ទិន្នន័យ និងថវិកា
ឧបសម្ព័ន្ធ ៣៖ ការគណនាសេដ្ឋកិច្ច (លំហូរសាច់ប្រាក់)

# ១. សេចក្ដីផ្ដើម

រាជរដ្ឋាភិបាលកម្ពុជាបានកំណត់តំបន់ឆ្នេរជាគោលដៅការងាររបស់កម្ពុជាសម្រាប់បន្សាំទៅនឹងផលប៉ះពាល់នាបច្ចុប្បន្ន និងអនាគតនៃការប្រែប្រួលអាកាសធាតុ។ តំបន់ឆ្នេរកម្ពុជាកំពុងរងការគំរាមកំហែងពីផលប៉ះពាល់ធ្ងន់ធ្ងរនៃការប្រែប្រួលអាកាសធាតុ ដូចជា ខ្យល់ព្យុះ ព្យុះសមុទ្រ កំណើនកំពស់ទឹកសមុទ្រ និងការជ្រាបចូលនៃទឹកប្រៃ។

របាយការណ៍នេះ *វិភាគថ្លៃចំណាយ និងផលចំណេញខាងសេដ្ឋកិច្ចនិងសង្គមនៃជម្រើសសម្រាប់ទម្លាប់អនុវត្តក្នុងកសិកម្មដែលកែប្រែ ដើម្បីកាត់បន្ថយភាពងាយរងគ្រោះពីផលប៉ះពាល់នៃវិសមរូបអាកាសធាតុ និងការប្រែប្រួលអាកាសធាតុ។* ការវាយតម្លៃនេះបានធ្វើឡើងជាលទ្ធផល ២.៥ នៃ CARP។

CARP មានគោលបំណងកសាងសមត្ថភាពបន្សាំក្នុងតំបន់ឆ្នេរ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ខេត្ត និងដើម្បីបង្កើតផែនការបន្សាំក្នុងតំបន់ឆ្នេរ តាមរយៈសកម្មភាពជាក់ស្តែងនៃការធ្វើផងរៀនផង ពោលគឺការកសាងសមត្ថភាពដែលមានការចូលរួមនៃអ្នកពាក់ព័ន្ធពីថ្នាក់កណ្តាល និងថ្នាក់វិមជ្ឈការ។ បន្ទាប់មក ផែនការបន្សាំដែលបានបង្កើតឡើងសម្រាប់តំបន់ឆ្នេរ នឹងត្រូវបម្លែងជាវិធានការបន្សាំដែលអនុវត្តបង្ហាញជាក់ស្តែងនៅក្នុងសហគមន៍ដែលងាយរងគ្រោះ នៅក្នុងតំបន់កសិកម្ម ឬតំបន់ព្រៃកោងកាងមួយចំនួន។[2]

ការវាយតម្លៃនេះ ដែលជាការបន្តពី "ការវាយតម្លៃយុទ្ធសាស្ត្រដោះទ័ល" "ការពិនិត្យភាពងាយរងគ្រោះនៃទម្លាប់ដែលមានស្រាប់ក្នុងកសិកម្ម" និង "ការវាយតម្លៃភាពងាយរងគ្រោះ និងហានិភ័យនៃបរិចិញ្ចឹមជីវិតរបស់សហគមន៍" ត្រូវបានរៀបចំឡើង ដើម្បីវាយតម្លៃសេដ្ឋកិច្ច នៃសំណើសកម្មភាពអនុវត្តបង្ហាញដែលបានស្នើឡើង។ សកម្មភាពដែលបានជ្រើសយកគឺជាសកម្មភាពដែលបានលើកស្នើនៅក្នុងរបាយការណ៍ ស្តីពី "ការវាយតម្លៃភាពងាយរងគ្រោះ និងហានិភ័យនៃបរិចិញ្ចឹមជីវិតរបស់សហគមន៍" ខែ កក្កដា ឆ្នាំ ២០១២។

របាយការណ៍នេះត្រូវបានរៀបរៀងឡើងដូចតទៅ៖ ក្រោយបង្ហាញជូនវិធីសាស្ត្រ និងតំបន់គោលដៅនៅក្នុងជំពូក២-៣ នៅក្នុងជំពូក ៤ មានសេចក្តីពិពណ៌នាអំពីការបង្កើត និងកសាងផែនការសម្រាប់សកម្មភាពអនុវត្តបង្ហាញដែលបានលើកស្នើ ដែលរួមទាំង ការប៉ាន់ស្មានដំបូងអំពីថ្លៃចំណាយផងដែរ។ បន្ទាប់មកចំណុចទាំងនេះ ត្រូវបានដាក់សម្រាប់ការវិភាគសេដ្ឋកិច្ចនៅក្នុងជំពូក ៥ ដែលបង្ហាញពីលទ្ធផលចំបងៗនៃការវិភាគ ចំណែកសេចក្តីពិស្តារមាននៅក្នុងឧបសម្ព័ន្ធ ៣ ។ ក្រោយសង្ខេបអំពីការពិចារណាផ្សេងទៀត ការសន្និដ្ឋាន និងអនុសាសន៍មានបង្ហាញជូននៅក្នុងជំពូក ៦។

[2] Cambodia Climate Change Alliance, "Coastal Adaptation and Resilience Planning Component", 2010, p. 34

## ១.១ វិធីសាស្ត្រ និងទិន្នន័យ

### វិធីសាស្ត្រ

និយាយដោយខ្លី វិធីសាស្ត្រនេះគឺ ការគណនា និងវិភាគទិន្នន័យសេដ្ឋកិច្ចកសិដ្ឋាន/គ្រួសារនៃទម្លាប់អនុវត្តក្នុងកសិកម្ម ដោយប្រើប្រាស់វិធីសាស្ត្រផលចំណេញដុល ដែលគេស្គាល់ជាទូទៅ។ ការគណនាទាំងនេះត្រូវបានគិតជាតម្លៃបច្ចុប្បន្នសុទ្ធ(NPV) និងអត្រាចំណូលផ្ទៃក្នុង(IRR) សម្រាប់សកម្មភាពដែលបានស្នើឡើង។ លើសពីនេះ ការចំណាយ និងផលចំណេញសង្គមអរូបិយ៍ក៏បានពិចារណាផងដែរ។

ដោយសារតែពាណិជ្ជកម្មសេរី អវត្តមានពន្ធនិងអាករនានាលើសម្ភារៈកសិកម្មឬកសិផល (លើកលែងតែផលិតផលខ្លះៗដូចជាឥន្ធនៈ)និងភាពប្រកួតប្រជែងខាងទីផ្សារនៃការជួញដូរទំនិញជាកសិផល និងសម្ភារៈកសិកម្មនៅក្នុងខេត្តដែលអនុវត្តគម្រោង (ជាពិសេស តំបន់ដែលស្ថិតនៅជិតព្រំដែន) មានការប៉ាន់ស្មានថាថ្លៃសេដ្ឋកិច្ចជារួមនៃទំនិញជាកសិផលនិងសម្ភារៈកសិកម្មចំបងៗដែលធ្វើពាណិជ្ជកម្ម ឆ្លុះបញ្ចាំងយ៉ាងជិតស្និទ្ធអំពីថ្លៃហិរញ្ញវត្ថុ។ សម្រាប់គោលបំណងនៃកិច្ចការនេះ ដែលជាការវាយតម្លៃក្នុងតំបន់គោលដៅ និងជម្រើសរវាងសកម្មភាពអនុវត្តបង្ហាញនានាសម្រាប់តំបន់គោលដៅនីមួយៗ យើងយល់ថាពុំចាំបាច់ធ្វើការគណនាដាច់ដោយឡែកពីគ្នាអំពីផលចំណូលហិរញ្ញវត្ថុ និងសេដ្ឋកិច្ច/សង្គមឡើយ។

ជាជំនួស មានការគណនាតម្លៃបច្ចុប្បន្នសុទ្ធ(NPV)ចំនួនពីរឈុត សម្រាប់សកម្មភាពអនុវត្តបង្ហាញនីមួយៗ៖ (ក) ការគណនាមួយប្រើប្រាស់អត្រាអប្បហា ៥% ក្នុងរយៈពេល ២០ឆ្នាំ និង (ខ) ការគណនាប្រើប្រាស់អត្រាអប្បហា ២០% សម្រាប់រយៈពេល ២០ឆ្នាំ។ ការគណនាបែបនេះផ្តល់របាយសមហេតុផល អំពី NPVដែលអាចទទួលបាន។ ករណីសម្រាប់រយៈពេលខ្លី ១៥ ឆ្នាំ ត្រូវបានពិចារណានៅក្រោមការវិភាគភាពងាយប្រែប្រួលនៃសកម្មភាពនីមួយៗ។

### ទិន្នន័យ

ការវិភាគនេះបានផ្អែកលើទិន្នន័យដែលមានស្រាប់ ក៏ដូចជា ទិន្នន័យដែលប្រមូលបានពីសហគមន៍នីមួយៗផងដែរ ដែលមានដូចតទៅ៖

ទិន្នន័យផលិតផលនៅតាមកសិដ្ឋាន/គ្រួសារ ក៏ដូចជា ដែលទាក់ទងនឹងថ្លៃលក់នៅក្នុងកសិដ្ឋាន និងថ្លៃដើមត្រូវបានប្រមូលយក មួយផ្នែកតាមរយៈការអង្កេតឆាប់រហ័សដោយផ្ទាល់ពីសហគមន៍គោលដៅ និងមួយផ្នែកបានមកពីប្រភពដែលមានស្រាប់នៃទិន្នន័យបែបនោះ។ ការស្វែងរកទិន្នន័យបែបនេះជួបការលំបាកខ្លាំងណាស់ ដោយសារទិន្នន័យបែបនេះពុំទំនងជាមានស្រេចឡើយនៅកម្ពុជា។ លក្ខខណ្ឌមិនសមស្របនៃទិន្នន័យ ដែលនាំឲ្យមានសំណើស្វែងរកវិធីនានា ដើម្បីកែប្រែលក្ខខណ្ឌនេះ ដូចជា តាមរយៈការធ្វើបច្ចុប្បភាពជាទៀងទាត់នៃមូលដ្ឋានទិន្នន័យនៅកម្រិតកសិដ្ឋាននៅក្នុងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ MAFF។

ដើម្បីឲ្យការគណនាបែបនេះមានសុពលភាព ថ្លៃចំណាយនិងផលចំណេញនៅក្នុងកសិដ្ឋាន ទិន្នផល និងបរិមាណសម្ភារៈកសិកម្មដែលប្រើប្រាស់ក្នុងកសិដ្ឋាន ត្រូវតែជាតួលេខបច្ចុប្បន្ននៅសហគមន៍គោលដៅ។ ពោលគឺ វាជាថ្លៃចំណាយនិងថ្លៃដើមសម្ភារៈកសិកម្មដែលអាចទទួលបាននាពេលបច្ចុប្បន្ននេះនៅកម្រិតគ្រួសារ

ក្នុងសហគមន៍គោលដៅ។ ដូចគ្នានេះដែរ សម្រាប់ទិន្នផល និងបរិមាណសម្ភារៈកសិកម្មនៅក្នុងកសិដ្ឋាន វាត្រូវតែជាទិន្នផល និងបរិមាណ និងតាមធម្មតា បានទទួល ឬអនុវត្តនៅក្នុងសហគមន៍ និងគ្រួសារ/កសិដ្ឋាន។ សុពលភាពទិន្នន័យបែបនេះគឺជាកត្តាជោគជ័យសំខាន់មួយសម្រាប់សកម្មភាព ២.៦ទាំងមូល។ យើងមានទំនុកចិត្តក្នុងកម្រិតសមហេតុផលថា ទិន្នន័យដែលប្រើប្រាស់មានសុពលភាព បើទោះជាពុំសុក្រិតក៏ដោយ។ សូមអានកំណត់សំគាល់នៅចុងសន្លឹកនានា ដែលផ្តល់សេចក្តីពន្យល់នៅក្នុងករណីមានការសន្មត។

តារាងដំបូងនៃទម្លាប់កសិកម្មដែលមានសក្តានុពល[3] សម្រាប់កែប្រែ ត្រូវបានប្រមូលយកនៅថ្ងៃទី ២៤-២៨ ខែមេសា។ តារាងនេះត្រូវបានកែសម្រួល ជាពិសេសតាមរយៈលទ្ធផលពីសកម្មភាព២.៥ នៃ CARP៖ “ការពិនិត្យភាពងាយរងគ្រោះនៃទម្លាប់ក្នុងកសិកម្មតបនឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ” ខែកក្កដា ឆ្នាំ ២០១២ ក៏ដូចជា តាមរយៈលទ្ធផលនៃសកម្មភាព ២.៣ នៃ CARP: “ការវាយតម្លៃភាពងាយរងគ្រោះ និងហានិភ័យនៃរបរចិញ្ចឹមជីវិតរបស់សហគមន៍” ខែកក្កដា ឆ្នាំ២០១២។

[3]“ទម្លាប់ក្នុងកសិកម្ម” នៅក្នុងបរិបទនេះ ជាគោលការណ៍ រួមបញ្ចូល ការចិញ្ចឹម ការនេសាទ និងព្រៃឈើ/ដំណាំចំការធំៗ។

# ២. តំបន់ឆ្នេរ

តំបន់ឆ្នេរកម្ពុជា ចែកចេញជាខេត្តចំនួនបួន (កំពត កោះកុង ព្រះសីហនុ និងកែប)។ ផ្ទៃដីសរុបក្នុងខេត្តទាំងនេះមានប្រមាណ ១៧.២៣៧គ.ម$^{២}$។ ឆ្នេរសមុទ្រកម្ពុជាមានប្រវែង ៤៣៥គ.ម ដែលស្ថិតនៅក្នុងឈូងសមុទ្រថៃ។ នៅតាមឆ្នេរសមុទ្រ មានកំពង់ផែទឹកជ្រៅមួយស្ថិតនៅក្រុងព្រះសីហនុ និងត្រូវបានចាត់ទុកថាជាមជ្ឈមណ្ឌលសេដ្ឋកិច្ចនៅកម្ពុជា។[4]

អាកាសធាតុក្នុងតំបន់ឆ្នេរ ត្រូវបានឲ្យនិយមន័យថាជាអាកាសធាតុមូសុងត្រូពិក ដែលមានកំពស់ទឹកភ្លៀងរវាង ២.០០០ និង ៤.០០០ម.ម។ បរិមាណនេះខ្ពស់ជាងក្នុងតំបន់ផ្សេងទៀតនៃប្រទេសកម្ពុជា។[5] តំបន់ឆ្នេរមានប្រភពទឹកសាបជាច្រើន ដែលបានពីស្ទឹង ទន្លេ និងបឹងនានា ដែលហូរកាត់តំបន់នេះ។ បើទោះជាមានប្រភពទឹកសាបប្រកបដោយសក្តានុពលបែបនេះក៏ដោយ កង្វះទឹកសាបគឺជាបញ្ហាមួយក្នុងតំបន់នេះ។

នៅក្នុងរដូវភ្លៀង ទន្លេ ស្ទឹង និងបឹងមានទឹកជំនន់ ដែលបំផ្លាញដំណាំនៅក្នុងតំបន់ទំនាប។ នៅរដូវប្រាំង ទឹកក្នុងទន្លេនៅតំបន់ខ្សែទឹកខាងក្រោម ទទួលបានល្បាយទឹកប្រៃ និងទឹកសាប ដែលធ្វើឲ្យទឹកនេះមិនសមស្របសម្រាប់គោលបំណងនៃការស្រោចស្រព។[6] ការសង្កេតនានាបង្ហាញថា ទឹកសមុទ្រអាចចូលមកដល់ ១០គ.ម នៅតាមដងទន្លេ និងប្រឡាយនានា។




រូបទី ២.១៖ ការប្រើប្រាស់ដីក្នុងតំបន់ឆ្នេរ

4 3/2-2012, http://www.wepa-db.net/policies/state/cambodia/seaarea.htm

5 IBID

6 Cambodia Climate Change Alliance, ”Coastal Adaptation and Recilience Planning Component”, 2010, p. 16

## ២.១ សហគមន៍គោលដៅ

ទីតាំងដូចខាងក្រោមនេះត្រូវបានជ្រើសរើសជាសហគមន៍គោលដៅ៖

- **ឃុំទឹកថ្លា ទឹកល្អក់ សាមគ្គី ព្រៃនប់ ទួលទទឹង និងអូរឧកញ៉ាហេង នៃស្រុកព្រៃនប់[7] ខេត្តព្រះសីហនុ**
- **ឃុំពាមក្រសោប និងទួលគគីរ ស្រុកមណ្ឌលសីមា ខេត្តកោះកុង**

*សហគមន៍ទាំងប្រាំបីនេះក្នុងស្រុកចំនួនពីរ ត្រូវបានជ្រើសយកដូចមានក្នុងឯកសារCARP[8]និងឯកសារបន្តបន្ទាប់។ ដូចមានចែងក្នុងCARP "ស្រុកព្រៃនប់ និងមណ្ឌលសីមា ត្រូវបានជ្រើសរើសជាស្រុកសាកល្បងនៅក្នុងការពិគ្រោះយោបល់ រវាងក្រសួងបរិស្ថាន (MoE ) អាជ្ញាធរខេត្ត និងស្រុកក្នុងតំបន់ឆ្នេរ CCCAនិងទីប្រឹក្សាជាតិ និងអន្តរជាតិ។ ការជ្រើសរើសសហគមន៍ទាំងនេះបានផ្អែកលើកត្តាដែលថា តំបន់ទាំងនេះជាប់ជាមួយឆ្នេរសមុទ្រ និងច្រើនតែផ្សំដោយតំបន់ដីទំនាបនិងតំបន់ងាយរងគ្រោះជាខ្លាំងចំពោះកំណើនកំពស់ទឹកសមុទ្រ ព្យុះសមុទ្រ ការជ្រាប ចូលនៃទឹកប្រៃ និងព្យុះត្រូពិក។*

ខាងក្រោមនេះគឺជាសេចក្តីអធិប្បាយខ្លីមួយអំពីសហគមន៍គោលដៅ៖

### ស្រុកព្រៃនប់ ខេត្តព្រះសីហនុ

ស្រុកព្រៃនប់មានប្រជាជន ១៨.៤៤៤គ្រួសារ និងចំនួនមនុស្ស៩៣.១៤១នាក់។ ស្រុកនេះស្ថិតនៅក្នុងតំបន់ទំនាបដែលមានផ្ទៃដីសរុប១០.០០០ហិកតា សម្រាប់ការផលិតស្រូវ ដែលស្ថិតក្រោមកិច្ចការពារពីប្រព័ន្ធទំនប់មួយ។ ប្រព័ន្ធទំនប់នេះត្រូវបានស្តារឡើងវិញអស់រយៈពេលបួនឆ្នាំ តាមរយៈមូលនិធិពីទីភ្នាក់ងារបារាំងដើម្បីអភិវឌ្ឍន៍ (AFD)។ កិច្ចព្រមព្រៀងមួយរវាងក្រសួងធនធានទឹក និងឧតុនិយម (MoWRAM) និងអ្នកប្រើប្រាស់ទឹកនៅព្រៃនប់ បែងចែកការទទួលខុសត្រូវលើការថែរក្សាទំនប់។ ទោះជាយ៉ាងណាក៏ដោយ ក្រុមនេះសង្កេតឃើញថា MoWRAM ទំនងជាមិនអាចថែរក្សាប្រព័ន្ធទំនប់បានគ្រប់គ្រាន់ ដោយសារតែឥឡូវនេះ ទឹកសមុទ្រជន់លិចស្រុកព្រៃនប់ម្តងម្កាលផងដែរ។ នេះក៏អាចបង្កឡើងដោយសារតែភាពខ្វះខាត (កំពស់, ប្រវែង) នៃប្រព័ន្ធនេះផងដែរ។

ចំនួនគ្រួសារ និងប្រជាជននៃក្នុងឃុំទាំង៦ ក្នុងស្រុកព្រៃនប់គឺ៖

| ស្រុក | ឃុំ | ចំនួនប្រជាជនសរុប | ចំនួនគ្រួសារសរុប |
|---|---|---|---|
| ព្រៃនប់ | ទឹកថ្លា | ៥.១២៣ | ១.១៣៣ |
| | ទឹកល្អក់ | ៤.១១១ | ៨៦១ |
| | សាមគ្គី | ៣.៩៩១ | ៩៥៩ |
| | ព្រៃនប់ | ៧.៣១៥ | ១.៣៨៧ |
| | ទួលទទឹង | ៤.៤៦៧ | ៨៥៩ |
| | អូរឧកញ៉ាហេង | ៨.៤១៤ | ១.៥៧១ |
| **សរុប** | | ៣៣.៤២១ | ៦.៧៥៦ |

ប្រភព៖ កម្រងទិន្នន័យឃុំ ឆ្នាំ ២០១២ និងផែនការខេត្ត ឆ្នាំ ២០១១

[7] ស្រុកព្រៃនប់មាន ១៤ឃុំ ក្នុងនោះឃុំចំនួន ៦ ត្រូវបានរួមបញ្ចូលក្នុងគម្រោងនេះ។

8Cambodia Climate Change Alliance, "Coastal Adaptation and Recilience Planning Component", 2010, Apendix G p. 115

ផែនទីមួយបង្ហាញទីតាំងឃុំចំនួន ៦ និងសេចក្តីអធិប្បាយអំពីលក្ខណៈរូប មាននៅក្នុងរបាយការណ៍វាយតម្លៃភាពងាយរងគ្រោះ និងហានិភ័យនៃ CARP ដែលអធិប្បាយផងដែរអំពីករណីនៃភាពក្រីក្រ និងទិដ្ឋភាពដទៃទៀត។ ផ្នែកទាំងនេះមិនមានចែងឡើងវិញទេនៅក្នុងរបាយការណ៍នេះ។

## ស្រុកមណ្ឌលសីមា ខេត្តកោះកុង

អ្នកភូមិជិត ៩៥% ដែលរស់នៅពាមក្រសោប ធ្វើការនេសាទ ដោយ ៦៤% នៃចំនួនគ្រួសារទាំងនេះមានការនេសាទជាមុខរបរចំបងរបស់ពួកគេ។ បន្ទាប់ពីមានកិច្ចប្រឹងប្រែងរបស់រដ្ឋាភិបាលដើម្បីបញ្ឈប់ការកាប់បំផ្លាញព្រៃកោងកាងនៅក្នុងដែនការពារ អ្នកនៅមូលដ្ឋានជាច្រើនបានប្តូររបរទៅចិញ្ចឹមមាន់ និងទា រកក្តាម និងខ្យង នេសាទ ជំនួញខ្នាតតូច បរបាញ់ បើកបរទូកលឿនតូចៗ ជួសជុលទូក និងឧបករណ៍នេសាទ ក្រងស្បូវ ការកែច្នៃត្រី និងជួសជុលផ្ទះ។[9]

ដោយសារគ្រួសារស្ទើរទាំងអស់ក្នុងឃុំពាមក្រសោប គឺជាអ្នកនេសាទ ឃុំមួយជាបន្ថែមនៅក្នុងស្រុកមណ្ឌលសីមាត្រូវបានជ្រើសយក ដើម្បីធានាថា កសិករក៏មានតំណាងនៅក្នុងសកម្មភាពនានាសម្រាប់ខេត្តកោះកុង។ ឃុំនេះគឺ ទួលគរគី។

ចំនួនគ្រួសារ និងប្រជាជនក្នុងឃុំគោលដៅចំនួនពីរនៅខេត្តកោះកុងគឺ៖

| ស្រុក | ឃុំ | ចំនួនប្រជាជនសរុប | ចំនួនគ្រួសារសរុប |
|---|---|---|---|
| មណ្ឌលសីមា | ពាមក្រសោប | ១.៣១៧ | ២៧៧ |
| | ទួលគរគី | ១.១៩៩ | ២៤១ |
| សរុប | | ២.៥១៧ | ៥១៨ |

ប្រភព៖ ផែនការខេត្ត ឆ្នាំ ២០១២

ផែនទីដែលបង្ហាញទីតាំងឃុំចំនួនពីរ និងសេចក្តីអធិប្បាយអំពីលក្ខណៈភូមិសាស្ត្រមាននៅក្នុងរបាយការណ៍វាយតម្លៃភាពងាយរងគ្រោះ និងហានិភ័យនៃCARPដែលក៏អធិប្បាយផងដែរអំពីករណីនៃភាពក្រីក្រ និងទិដ្ឋភាពដទៃទៀត។ ផ្នែកទាំងនេះមិនមានចែងឡើងវិញនៅក្នុងរបាយការណ៍នេះទេ។

9Cambodia Climate Change Alliance, ”Coastal Adaptation and Recilience Planning Component”, 2010, p. 23 - 24

# ៣. សកម្មភាពអនុវត្តបង្ហាញអំពីទម្លាប់កសិកម្មដែលកែប្រែ

## ៣.១ ទិដ្ឋភាពរួមនៃសកម្មភាពអនុវត្តបង្ហាញដែលបានលើកស្នើ

សកម្មភាពដែលបានជ្រើសយកចំនួនប្រាំដូចខាងក្រោមនេះត្រូវបានវិភាគសេដ្ឋកិច្ច៖

១. កម្មវិធីបណ្តុះបណ្តាលអំពីកសិកម្មចម្រុះដល់ (ក)បុគ្គលិកផ្សព្វផ្សាយកសិកម្ម និង(ខ)គ្រួសារ/ខ្នងផ្ទះ នៅក្នុងយុទ្ធសាស្ត្របន្សាំនឹងការប្រែប្រួលអាកាសធាតុ និងផលិតកម្មចម្រុះ (ការរួមបញ្ចូលដំណាំ ការសត្វចិញ្ចឹម ត្រី ទឹក) នៅក្នុងឃុំគោលដៅ ៧-៨។ មុននេះមានការវិភាគក្បែត្រប្រព័ន្ធដែលជាផ្នែករួមមួយ នៃកម្មវិធីនេះ។

២. គម្រោងសហគមន៍នេសាទនៅពាមក្រសោប ក្រោមកិច្ចសហការជាមួយរដ្ឋបាលជលផល ជាពិសេសដើម្បីពង្រឹងវិធានការច្បាប់ និងពង្រឹងការអនុវត្ត។[10] ទំនាក់ទំនងនៃសហគមន៍នេសាទជាមួយការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុបង្ហាញថា គេទំនងជាត្រូវការនូវការអភិវឌ្ឍជាទូទៅខាងការនេសាទ និងវិធានការច្បាប់ ដើម្បីកែសម្រួលមុខរបររបស់សហគមន៍អ្នកនេសាទ(សូមអានបន្ថែមខាងក្រោម)។

៣. ការលើកកំពស់ និងបង្កើនវត្តមានពូជដំណាំដែលឆាប់ផ្តល់ផល ជាពិសេស ស្រូវស្រាលរដូវវស្សា អាចសម្រួលដល់ការប្រមូលផលមុនពេលទឹកជំនន់ធំមកដល់ និងការឡើងកំពស់ទឹកសមុទ្រនៅក្នុងឃុំគោលដៅ។ គេត្រូវសាកល្បងពូជដំណាំបែបនេះ(ដោយកសិករមិនមែនជាអ្នកបង់ខាត)នៅក្នុងទីតាំងជាក់លាក់ ដែលទំនងជាមានប្រសិទ្ធភាព។

៤. លើកកំពស់ការចិញ្ចឹមសត្វនៅក្នុងឃុំចំនួន ៥ ដោយប្រើប្រាស់ប្រព័ន្ធកែលម្អពូជជាបន្តបន្ទាប់ - បានសាកល្បងដោយជោគជ័យនៅកម្ពុជា ឡាវ និងកន្លែងដទៃ។ នេះជាវិធានការឆ្លើយតប ទៅនឹងបញ្ហាទឹកជំនន់ ដោយសារគេអាចចល័តសត្វចិញ្ចឹមបាន។

៥. លើកកំពស់ការអភិរក្សទឹកនៅក្នុងស្រែ ការរក្សាទឹកភ្លៀងទុកក្នុងកសិដ្ឋាននិងវិធីស្រោចស្រពខ្នាតតូច។

របាយការណ៍វាយតម្លៃភាពងាយរងគ្រោះ និងហានិភ័យនៃរបរចិញ្ចឹមជីវិតរបស់សហគមន៍ ខែកក្កដា ឆ្នាំ ២០១២ បានលើកស្នើសកម្មភាពអនុវត្តបង្ហាញពីរបន្ថែមទៀតដូចខាងក្រោម។ ទោះជាយ៉ាងណាក៏ដោយ ការវិភាគសេដ្ឋកិច្ចលើសកម្មភាពទាំងនេះមិនធ្វើបានឡើយ ដោយសារតែខ្វះទិន្នន័យ។

i. គម្រោងសហគមន៍ព្រៃឈើនៅទួលគរគីក្រោមកិច្ចសហការជាមួយរដ្ឋបាលព្រៃឈើ ដែលអាចអនុវត្តបាននៅទួលគរគី។ គម្រោងនេះអាចរាប់បញ្ចូល សិទ្ធិក្នុងការលែងសត្វឲ្យស៊ីស្មៅ សម្រាប់សត្វចិញ្ចឹមនៅក្នុងដែនដីព្រៃ ក៏ដូចជា ថ្នាលបណ្តុះកូនឈើផងដែរ។ ទំនាក់ទំនងរវាងសហគមន៍ព្រៃឈើជាមួយការបន្សាំនឹងការប្រែប្រួលអាកាសធាតុបង្ហាញថាការដាំដើមឈើអាចជាវិធីមួយសម្រាប់ការពារដំណាំ

[10] មកទល់បច្ចុប្បន្ននេះ FiA បានចុះបញ្ជីសហគមន៍នេសាទចំនួន ២១នៅក្នុងតំបន់ឆ្នេរ។ គួរតែមានការចុះបញ្ជីសហគមន៍នេសាទជាផ្លូវការនៅ FiA (ដោយសារជាលក្ខខណ្ឌដូចមានចែងក្នុងអនុក្រឹត្យស្តីពីការគ្រប់គ្រងសហគមន៍នេសាទ) – បន្ថែមលើការចុះបញ្ជីជាសហគមន៍តំបន់ការពារធម្មជាតិនៅក្រសួងបរិស្ថាន។

និងផ្ទះការពារស្ថិរភាពទំនប់ ផ្តល់អុស និងផ្លែឈើ ក៏ដូចជា ការផ្តល់ប្រាក់ចំណូល នៅក្នុងករណីដែលមានដីសមស្រប (ដូចជានៅទួលគរគី)។

ii. ពង្រឹងការថែទាំទំនប់សហគមន៍ ការគ្រប់គ្រងប្រព័ន្ធដោះទឹក និងប្រព័ន្ធស្រោចស្រពក្រោមកិច្ចសហការជាមួយក្រសួងធនធានទឹកនិងឧតុនិយម - សម្រាប់ព្រៃនប់ និងទួលគរគី។

*"ជាទូទៅ សកម្មភាពអនុវត្តបង្ហាញដែលបានលើកស្នើសម្រាប់CARP ទាំងនេះ អាចអធិប្បាយថាៈ*

- *វិធានការភាគច្រើនសម្រាប់ទប់ទល់នឹងការប្រែប្រួលអាកាសធាតុ ត្រូវបានស្នើឡើងដោយឃុំគោលដៅ និងមន្ត្រីពាក់ព័ន្ធ។ ទោះជាយ៉ាងណាក៏ដោយ ការចាត់ចែងអនុវត្តដែលបានលើកស្នើនៅត្រូវពិភាក្សាបន្ថែមជាមួយភាគីទាំងនេះ និងអ្នកពាក់ព័ន្ធដទៃទៀតផងដែរ។ (ប៉ុន្តែ មិនបានរាប់បញ្ចូលការជួសជុលប្រព័ន្ធទំនប់ឡើយ ដែលបង្ហាញច្បាស់ថាជាជាអាទិភាពទីមួយសម្រាប់ឃុំគោលដៅ។ កង្វល់នេះត្រូវបានទុកសម្រាប់ផ្នែកដទៃនៃCARP ទៅតាមការឯកភាពគ្នា)។*
- *អាទិភាពមួយ(នៅមុនការគណនា)ត្រូវបានរំពឹងថាអាចផ្តល់ផលចំណេញយ៉ាងច្រើនខាងសង្គម បរិស្ថាន សេដ្ឋកិច្ចនិងរបបចិញ្ចឹមជីវិតជាទូទៅ ទន្ទឹមនឹងអាចបន្សុំទៅនឹងការប្រែប្រួលអាកាសធាតុដែលបានព្យាករណ៍ផងដែរ។*
- *ជាទូទៅ សកម្មភាពអនុវត្តបង្ហាញបង្កជាហានិភ័យតិចតួចសម្រាប់ការអនុវត្ត ជាពិសេសសម្រាប់គ្រួសារដែលពាក់ព័ន្ធ - ដោយសារតែគំរូនៃការអនុវត្ត ដែលបានលើកស្នើត្រូវបានសាកល្បងដោយជោគជ័យនៅក្នុងកាលៈទេសៈប្រហែលគ្នានេះ*
- *ត្រូវបានរំពឹងថាមានលក្ខខណ្ឌធនធានប្រាកដប្រជា*
- *ត្រូវបានរំពឹងថាអាចអនុវត្តបានពីសំណាក់ ស្ថាប័ន និងដៃគូពាក់ព័ន្ធ និងដែលបានកត់សំគាល់ហើយក្នុងករណីពាក់ព័ន្ធ ក៏មានការលើកស្នើវិធានការកសាងសមត្ថភាពផងដែរ។*

*ទោះជាយ៉ាងណាក៏ដោយ រយៈពេលខ្លីសម្រាប់គម្រោងនេះ (CARP ចប់នៅចុងត្រីមាសទី ១ ឆ្នាំ ២០១៤) បង្កជាការប្រឈមមួយ ដោយសារវាផ្តល់ពេលសម្រាប់តែមួយរដូវបង្កបង្កើនផលតែប៉ុណ្ណោះ (ឆ្នាំ ២០១៣)សម្រាប់ការអនុវត្ត។ រយៈពេលអនុវត្តខ្លីបែបនេះ មិនសមស្របឡើយសម្រាប់កិច្ចប្រឹងប្រែងអភិវឌ្ឍន៍ណាមួយ ដែលតាមធម្មតា ត្រូវការពេល ឧទា. ពី ៣-៥ ឆ្នាំ។*

*ទោះជាយ៉ាងណាក៏ដោយ សកម្មភាពអនុវត្តបង្ហាញដែលបានលើកស្នើ នៅតែអាចចាប់ផ្តើមប្រតិបត្តិការ និងអនុវត្តដូចការគ្រោងទុកនៅក្នុងឃុំគោលដៅ។ ប៉ុន្តែ ជាការល្អគួរតែមានពេលបន្ថែមទៀតសម្រាប់សកម្មភាពបន្ត ការពង្រឹងបន្ថែម ការប្រើប្រាស់មេរៀនដែលទទួលបាន និងការប្រមូលផ្តុំលទ្ធផល ក៏ដូចជាសម្រាប់ការពង្រីកសកម្មភាពទៅកន្លែងផ្សេងទៀត។*

*ការសង្កេតនេះមានការពាក់ព័ន្ធសម្រាប់រាល់សកម្មភាពអនុវត្តបង្ហាញ ពោលគឺមិនត្រឹមតែសកម្មភាពទាំង ៦ ខាងដើមប៉ុណ្ណោះទេ ដែលត្រូវបានចាត់ទុកថាមិនងាយរងគ្រោះឡើយនៅក្នុងរយៈពេលខ្លីខាងមុខ។"*[11]

[11]ស្រង់ចេញពីរបាយការណ៍វាយតម្លៃភាពងាយរងគ្រោះ និងហានិភ័យនៃ CARP ផ្នែកទី ៦.២

## ៣.២ ទម្រង់រួម និងការប៉ាន់ស្មានថ្លៃចំណាយ

**១. កម្មវិធីបណ្តុះបណ្តាលអំពីកសិកម្មចម្រុះសម្រាប់ (ក)បុគ្គលិកផ្សព្វផ្សាយកសិកម្ម/ការនេសាទ និង(ខ) គ្រួសារ/ខ្នងផ្ទះ អំពីយុទ្ធសាស្រ្តបន្សាំនឹងការប្រែប្រួលអាកាសធាតុនៅកម្រិតខុសៗគ្នា និងផលិតកម្មចម្រុះ (ការរួមបញ្ចូលដំណាំ ការសត្វចិញ្ចឹម ត្រី ទឹក) នៅក្នុងឃុំចំនួន ៧។ មានការវិភាគក្សេត្រប្រព័ន្ធជាមុន (វិធីសាស្រ្ត PRA ដែលប្រើប្រាស់ដោយ MAFF)។**

គោលគំនិតមួយដែលស្របជាមួយចំណុចទាំងនេះ បច្ចុប្បន្ននេះមានអនុវត្តនៅក្រោមគម្រោង NAPA នៅកម្ពុជា ដែលទទួលមូលនិធិពី GEF, UNDP និង IFAD។ គម្រោងនេះបានអនុវត្តតាំងពីឆ្នាំ២០០៩ និងបានពង្រីកដល់កសិករប្រមាណ ៦០០០នាក់ នៅខេត្តព្រះវិហារ និងក្រចេះ។ សញ្ញាណនៃការបន្សាំក៏មានភាពស្របគ្នាជាមួយឯកសារសមាសភាគCARPផងដែរ ដែលសង្កត់ធ្ងន់លើចំណងទាក់ទងរវាងគម្រោងដែលបានកត់សំគាល់ខាងលើ ហើយមួយផ្នែកនៃគោលបំណងរបស់CARPគឺផ្តោះប្តូរបច្ចេកវិទ្យា និងចំណេះដឹងអំពីការបន្សាំនឹងការប្រែប្រួលអាកាសធាតុ (ការចងក្រងជាឯកសារអំពីឥទ្ធិពលពីកម្ពុជាក្នុងឧបសម្ព័ន្ធ ២)។

លើសពីនេះ គោលគំនិតអំពីសាលាស្រែកសិករត្រូវបានអនុវត្តនៅកម្ពុជា និងប្រទេសដទៃទៀត (ជាពិសេស នៅវៀតណាម និងបង់ក្លាដែស) ដោយមានឥទ្ធិពលជោគជ័យកម្រិតខ្ពស់ ក្នុងការបង្កើនប្រាក់ចំណូលនៅជនបទ ក៏ដូចជា ការកាត់បន្ថយឥទ្ធិពលមិនចង់បានមកលើបរិស្ថាន និងសុខភាពមនុស្ស តាមរយៈការសាយភាយនៃបច្ចេកវិទ្យាអំពីវិធានការចម្រុះការពារដំណាំ (IPM)។[12]

នៅទីបំផុត គោលគំនិតនេះផ្តល់លទ្ធភាពក្នុងការបង្កើតដំណោះស្រាយដែលបង្កើតឡើងឲ្យស្របតាមគ្រួសារនីមួយៗ ក៏ដូចជា សហគមន៍និងឃុំនីមួយៗ ដោយសារតែវិធានសាលាស្រែកសិករ ត្រូវបានរួមបញ្ចូលជាមួយការវិភាគជាមុននៃប្រព័ន្ធក្សេត្របរិស្ថានសម្រាប់ឃុំនីមួយៗ។ គំរូដែលមានប្រសិទ្ធភាពសម្រាប់ការវិភាគប្រព័ន្ធក្សេត្របរិស្ថាន បច្ចុប្បន្នត្រូវនាយកដ្ឋានផ្សព្វផ្សាយកសិកម្មយកមកប្រើប្រាស់។ គំរូនេះរួមបញ្ចូលដំណាំចំការធំៗ សត្វចិញ្ចឹម និងជលផល ទឹក និងប្រភពសម្រាប់របរចិញ្ចឹមជីវិតដទៃទៀតទៅក្នុងសញ្ញាណកសិកម្ម (ឬរបរចិញ្ចឹមជីវិត)ចម្រុះ និងអាចឲ្យគ្រួសារនីមួយៗ ក៏ដូចជា សហគមន៍របស់ពួកគេទាំងមូលបង្កើតដំណោះស្រាយពិស្តារដែលបង្កើតឡើងសម្រាប់ឆ្លើយតបនឹងតម្រូវការជាក់លាក់ ការនិយមចូលចិត្ត និងឱកាសនានារបស់ពួកគេផងដែរ។[13]

តាមរយៈការផ្តល់ឱកាសដើម្បីស្វែងរកដំណោះស្រាយពិស្តារ រាល់កង្វល់របស់គ្រួសារនានា (មិនត្រឹមតែទាក់ទងនឹងការប្រែប្រួលអាកាសធាតុប៉ុណ្ណោះទេ) អាចសម្រុះសម្រួលបានផងដែរ ទន្ទឹមនឹងអាចបញ្ចៀសលទ្ធផលដែលមិនផ្តល់ជោគជ័យពេញលេញដែលបានពីដំណោះស្រាយដាច់ដោយដុំ តបនឹងឧបសគ្គនានា។

---

[12]ឯកសារនានារួមមាន (ក)ASSP Impact Assessment, Danida, Dhaka, 2003, និង (b) Mid-term Review of IPM Programme, Danida, Hanoi, 2003.

[13]ឧទា. ក្រុមមនុស្សក្នុងអាយុខុសគ្នា អាចមានជម្រើស និងឱកាសខុសៗគ្នា។

សំណើសម្រាប់ការវាយតម្លៃសេដ្ឋកិច្ច៖ ការបង្កើតកម្មវិធីបណ្តុះបណ្តាលកសិករ អំពីការដាំដំណាំ/របរចម្រុះនៅក្នុងឃុំគោលដៅចំនួនប្រាំពីរ[14] ដោយអនុវត្តតាមគោលគំនិតដែលបានអធិប្បាយខាងលើ។ ការអនុវត្តជាជំហានដូចតទៅ៖

- *i.* *ធ្វើការវិភាគក្សេត្រប្រព័ន្ធក្នុងឃុំចំនួន ៧ (៣ខែ)*
- *ii.* *ការកែសម្រួលម៉ូដែល និងកម្មវិធីសិក្សាសម្រាប់លក្ខខណ្ឌតំបន់ឆ្នេរ (១ខែ)*
- *iii.* *ការអនុវត្តកម្មវិធីបណ្តុះបណ្តាលគ្រូបង្គោល ដល់ភ្នាក់ងារផ្សព្វផ្សាយដែលបច្ចុប្បន្ននេះមានការពាក់ព័ន្ធទាំងភ្នាក់ងារនៅក្នុងរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាលនិងវិស័យឯកជន ទៅតាមការពាក់ព័ន្ធ(៣ខែ)។ នេះជាការអភិវឌ្ឍសមត្ថភាព ដែលអាចមានការប្រើប្រាស់ទូលំទូលាយនៅក្រៅឃុំគោលដៅបច្ចុប្បន្ននៃCARPផងដែរ។*
- *iv.* *ការអនុវត្តកម្មវិធីបណ្តុះបណ្តាលកសិករ/អ្នកនេសាទ ដោយប្រើប្រាស់គោលគំនិតសាលាស្រែកសិករ យ៉ាងហោចណាស់រយៈពេលមួយឆ្នាំ ឬ វែងជាងនេះបើអាចធ្វើបាន។ អាចរាប់បញ្ចូលទស្សនកិច្ចទៅទីតាំងនានាដែលមានបញ្ហាដូចគ្នា ប្រសិនបើអាចធ្វើបាន។*
- *v.* *ការបង្កើតមូលដ្ឋានសម្រាប់បន្តនិរន្តរភាពសម្រាប់ការបណ្តុះបណ្តាលរំលឹកឡើងវិញនិងអាចជាការគាំទ្រដល់ការផ្សព្វផ្សាយតាមបែបផ្សេង ស្របជាមួយវិធីខាងលើ(ប៉ុន្តែមិនសូវខ្លាំងភ្លា) ដើម្បីបន្តសកម្មភាពនេះនៅក្រោយបញ្ចប់គម្រោងនេះ។*
- *vi.* *ការតាមដាន និងចងក្រងជាឯកសារអំពីឥទ្ធិពល និងបទពិសោធន៍តាមជំហាន i-v។*

ការរំពឹងទុកអំពីឥទ្ធិពល ឡូក់ហ្វ្រេម និងការប៉ាន់ស្មានតម្លៃចំណាយសម្រាប់ការអនុវត្តបង្ហាញសកម្មភាព ១ ដែលបានលើកស្នើ មានដូចខាងក្រោម៖

[14] ពាមក្រសោប អាចមានលក្ខណៈគ្រប់គ្រាន់សម្រាប់សកម្មភាពដែលលើកស្នើនៅក្រោមសហគមន៍នេសាទ ប៉ុន្តែសាលាស្រែកសិករឯកទេសមួយចំនួនក៏អាចអនុវត្តបានផងដែរ - ត្រូវធ្វើការសម្រេច

| សេចក្តីអធិប្បាយ | សូចនាករ | ប្រភពនៃការផ្ទៀងផ្ទាត់ | ការសន្មតិ |
|---|---|---|---|
| **សមិទ្ធផលះ**<br><br>**បង្កើនទ្វេដងនៃប្រាក់ចំណូលប្រចាំគ្រួសារ និងការបន្សាំចំពោះការប្រែប្រួលអាកាសធាតុ សម្រាប់៧៥%នៃអ្នកចូលរួមក្នុងសាលាស្រែកសិករ.**[15] | • បង្កើនប្រាក់ចំណេញមធ្យមប្រចាំគ្រួសារបាន ២០០ដុល្លា ក្នុង១ ហិកតា និងសមមូលជាសត្វចិញ្ចឹម និងផលនេសាទ<br>• បង្កើនសមត្ថភាពភ្នាក់ងារផ្សព្វផ្សាយដើម្បីណែនាំអំពីការប្រែប្រួលអាកាសធាតុនិងកសិកម្មចម្រុះ | • របាយការណ៍សកម្មភាព ការពិនិត្យ និងវាយតម្លៃ | |
| **លទ្ធផល ១.** ការបន្សាំនឹងការប្រែប្រួលអាកាសធាតុនៅកម្រិតខុសៗគ្នាក្នុងការដាំដំណាំចម្រុះ និងកម្មវិធីបណ្តុះបណ្តាលអំពីIPM | • ការអនុវត្តសកម្មភាពផ្សព្វផ្សាយដោយផ្ទាល់ដល់កសិករ ១២០០គ្រួសារ តាមរយៈសាលាស្រែកសិករចំនួន៤៨លើក ដែលអនុវត្តពេញមួយរដូវ និងដល់កសិករ ៦០០០គ្រួសារដោយប្រយោលក្នុងឃុំចំនួន ៧ រហូតដល់ឆ្នាំ ២០០៤ | • ការតាមដានសកម្មភាព ការពិនិត្យ និងវាយតម្លៃ | • សកម្មភាពនានាដែលគាំទ្រ នឹងបន្ថែមទំនុកចិត្តគ្រប់គ្រាន់ដល់គ្រួសារកសិករ ដើម្បីទទួលអនុសាសន៍ និងផ្តល់ឥទ្ធិពលជាប្រាក់ចំណូល។ |
| **សកម្មភាព ១.១**<br><br>អនុវត្តការវិភាគក្បែត្រប្រព័ន្ធក្នុងឃុំ។ | • ការវិភាគក្បែត្រប្រព័ន្ធដោយមានការចូលរួមក្នុងឃុំចំនួនបួនដឹកនាំដោយក្រុមចម្រុះ | • របាយការណ៍ក្បែត្រប្រព័ន្ធចំនួន ៧ | • វត្តមានមន្ត្រីដែលបានកត់សំគាល់សម្រាប់ដឹកនាំការវិភាគ |

[15] ការចងក្រងជាឯកសារនូវសមិទ្ធផលនៃវិធីសាស្ត្រសាលាស្រែកសិករនៅកម្ពុជា មានក្នុងឧបសម្ព័ន្ធ ២។ តាមធម្មតា FFS ផ្តល់ឥទ្ធិពលភ្លាមៗ ប៉ុន្តែជាការល្អគួរតែមានសកម្មភាពបន្ត និងការពង្រឹងខ្លះៗ (យោងទៅលទ្ធផល ១.៥)។ ទោះជាយ៉ាងណាក៏ដោយ ការគណនាសេដ្ឋកិច្ចបង្ហាញពីកម្រិតរឹងមាំ និងភាពធន់នឹងផលប៉ះពាល់កម្រិតទាបជាង ដោយគ្មានបាត់បង់កម្រិតផលចំណេញនៃការវិនិយោគឡើយ (យោងជំពូក ៥)។

| សេចក្តីអធិប្បាយ | សូចនាករ | ប្រភពនៃការផ្ទៀងផ្ទាត់ | ការសន្មតិ |
|---|---|---|---|
| រយៈពេល ៣ ខែ | មកពី MAFF, MoWRAM និង MoE; ដែលរួមទាំង ការបន្សាំនឹងការប្រែប្រួលអាកាសធាតុ។ កិច្ចការនេះបង្កើតជាមូលដ្ឋានសម្រាប់គិតគូរអំពីសហគមន៍នៅក្នុងវេទិកាសាលាស្រែកសិករ | | |
| **សកម្មភាព ១.២**<br>កែសម្រួលម៉ូឌុលបណ្តុះបណ្តាល និងកម្មវិធីសិក្សាឲ្យស្របនឹងលក្ខខណ្ឌក្នុងតំបន់ឆ្នេរ។ រយៈពេល ១ខែ | • កម្មវិធីបណ្តុះបណ្តាលដែលចែងច្រើនជាងមុនអំពីការនេសាទ និងការចិញ្ចឹមសត្វ<br>• ម៉ូឌុលដែលគិតគូរជាពិសេសអំពីការគំរាមកំហែងពីទឹកប្រៃនិងព្យុះនៅតំបន់ឆ្នេរ<br>• រួមបញ្ចូលវិធានការអភិរក្សទឹកក្នុងកសិដ្ឋាន ការថែទាំទំនប់ និងវិធានការគ្រប់គ្រងប៉ូលឌែរ | • របាយការណ៍ទីប្រឹក្សាក្នុងស្រុកដែលចែងអំពីការកែសម្រួលទាំងនេះ<br>• សម្ភារៈបង្រៀនដែលផលិតជាស្រេចសម្រាប់អនុវត្តសាលាស្រែកសិករដោយផ្ទាល់ | • វត្តមានទីប្រឹក្សាក្នុងស្រុកដែលមានជំនាញគ្រប់គ្រាន់ |
| **សកម្មភាព ១.៣**<br>ការអនុវត្តកម្មវិធីបណ្តុះបណ្តាលគ្រូបង្គោល (សម្រាប់ភ្នាក់ងារផ្សព្វផ្សាយដែលពាក់ព័ន្ធបំផុតនៅពេលបច្ចុប្បន្ននេះ ទាំងភ្នាក់ងារក្នុងរដ្ឋាភិបាល, NGOនិងវិស័យឯកជន ប្រសិនបើពាក់ព័ន្ធ)។ រយៈពេល៖ ៣ខែ | • ការបណ្តុះបណ្តាលគ្រូបង្គោលសម្រាប់ភ្នាក់ងារផ្សព្វផ្សាយ ២៨នាក់មកពីខេត្តព្រះសីហនុ និងកោះកុង នៅក្នុងវគ្គបណ្តុះបណ្តាលចំនួន១៦លើក ដែលវគ្គនីមួយៗមាន ៨ម៉ោង | • របាយការណ៍បណ្តុះបណ្តាល | • វត្តមានគ្រូបង្វឹកមកពី DAE, CARDI, MoWRAM & MoE |

| សេចក្តីអធិប្បាយ | សូចនាករ | ប្រភពនៃការផ្ទៀងផ្ទាត់ | ការសន្មតិ |
|---|---|---|---|
| **សកម្មភាព ១.៤**<br>ការអនុវត្តកម្មវិធីបណ្តុះបណ្តាលកសិករដោយប្រើប្រាស់គោលគំនិតសាលាស្រែកសិករ <u>យ៉ាងហោចណាស់១ឆ្នាំ</u>វែងជាងនេះបើអាច។ វគ្គនេះអាចរាប់បញ្ចូលទស្សនកិច្ចទៅតំបន់ដែលមានបញ្ហាប្រហែលគ្នា ប្រសិនបើអាចធ្វើបាន<br>រយៈពេល៖ យ៉ាងហោចណាស់១២ខែ | • សាលាស្រែកសិករពេញវដ្តចំនួន៤៨លើកដោយមានអ្នកចូលរួម ១២០០នាក់អំពីការបន្សាំនឹងការប្រែប្រួលអាកាសធាតុ និងការដាំដំណាំចម្រុះក្នុង៧ឃុំ នៅឆ្នាំ ២០១៣<br>• ទិវាស្រែកសិករ ៤៩លើកសម្រាប់អ្នកភូមិជិតខាង (អ្នកចូលរួម ៦០០០នាក់)<br>• ទស្សនកិច្ចសិក្សា | • ការពិនិត្យតាមដានសកម្មភាព និងលទ្ធផលគម្រោង<br>• ការវាយតម្លៃឥទ្ធិពលក្រោយចប់គម្រោង<br>• របាយការណ៍ FFS និង FFD<br>• របាយការណ៍ទស្សនកិច្ចសិក្សា | • កសិករមានចំណាប់អារម្មណ៍ចូលរួម |
| **សកម្មភាព ១.៥**<br>ការបង្កើតមូលដ្ឋានដើម្បីបន្តនិរន្តរភាពនៃការបណ្តុះបណ្តាលម្លឹកឡើងវិញ និងអាចការគាំទ្រដល់ការផ្សព្វផ្សាយតាមបែបផ្សេង ស្របជាមួយវិធីខាងលើ(ប៉ុន្តែមិនសូវខ្លាំងក្លា) ដើម្បីបន្តនៅក្រោយបញ្ចប់គម្រោងនេះ<br>រយៈពេល ១ខែ | • ការចាតចែងកិច្ចសន្យាជាមួយ PDA, ក្រុមប្រឹក្សាស្រុក និងឃុំ<br>• អាចពាក់ព័ន្ធជាមួយមូលនិធិសម្រាប់ឃុំនីមួយៗ ដើម្បីបំពេញដោយវិភាគទានពីមូលដ្ឋាន និងពីថ្នាក់ជាតិ | • ការចាត់ចែងកិច្ចសន្យា និងការពិនិត្យតាមដាន | • អាជ្ញាធរមានចំណាប់អារម្មណ៍ក្នុងការចាត់ចែងនានា |
| **សកម្មភាព ១.៦**<br>ការតាមដាននិងចងក្រងជាឯកសារអំពីឥទ្ធិពលនិងបទពិសោធន៍តាមជំហានi-v ។ (សកម្មភាពបន្ត) | • ការពិនិត្យតាមដានដោយបុគ្គលិកគម្រោង និងពីអ្នកពិនិត្យពីខាងក្រៅ | របាយការណ៍ពិនិត្យតាមដាននិងពិនិត្យ | ផ្នែកពិនិត្យតាមដានគម្រោងនៃកិច្ចការគ្រប់គ្រងជាធម្មតា ដោយគ្មានការចំណាយបន្ថែម |

## តារាង ១. ការប៉ាន់ស្មានតម្លៃចំណាយ

| ជំហាន | ការប៉ាន់ស្មានថ្លៃចំណាយ(លំអិត) | ចំនួន ($) |
|---|---|---|
| **សកម្មភាព ១.១** | $ ៣០០០ ក្នុង ១ឃុំ ៖ $២១.០០០<br>+ ភស្តុភា និងសម្ភារៈ : $ ៧.០០០<br>+ បម្រុងយថាភាព : $ ២.០០០ | ៣០.០០០ |
| **សកម្មភាព ១.២** | ថ្លៃចំណាយលើទីប្រឹក្សា<br>៣០ នាក់ ថ្ងៃ @ $២០០ = ៦.០០០<br>ភស្តុភា និងសម្ភារៈ= ២.០០០<br>បម្រុងយថាភាព= ២.០០០ | ១០.០០០ |
| **សកម្មភាព ១.៣** | អ្នកចូលរួម ២៨នាក់ x ១៦ x$២០= $៩.០០០<br>គ្រូបង្គាត់២x ១៦ x $២០០$៦.៤០០<br>ភស្តុភា និងសម្ភារៈ ៤.៦០០<br>បម្រុងយថាភាព : ២.០០០ | ២២.០០០ |
| **សកម្មភាព ១.៤** | **Cost:**<br>៤៨ FFS x $១០០០ = $៤៨.០០០<br>៤៨ FFD x$ ២៥០ $ ១២.០០០<br>ទស្សនកិច្ចសិក្សា២០.០០០<br>បម្រុងយថាភាព ៥.០០០<br><br>សរុបរង: $ ៦៥.០០០ | ៨៥.០០០ |
| **សកម្មភាព ១.៥** | ចំនួនសរុបសម្រាប់ទុនបង្វិលក្នុងឃុំ៖ $១០.០០០ក្នុងមួយឃុំ | ៧០.០០០ |
| **សកម្មភាព ១.៦** | ផ្នែកពិនិត្យតាមដានគម្រោងនៃកិច្ចការធម្មតាក្នុងការគ្រប់គ្រង ដោយមិនចំណាយបន្ថែម។<br>ការពិនិត្យដោយស្ថាប័នខាងក្រៅ៖ ៣០នាក់ ថ្ងៃ @ $២០០ = $៦០០០+ ភស្តុភា។ល។ $២.០០០ = | ៨.០០០ |
| **សរុប** | | **២២៥.០០០** |

## ២. គម្រោងសហគមន៍នេសាទនៅពាមក្រសោប ក្រោមកិច្ចសហការជាមួយរដ្ឋបាលជលផល ជាពិសេស ដើម្បីពង្រឹងវិធានការច្បាប់ និងពង្រឹងការអនុវត្ត។[16]

សកម្មភាពនេះជម្រុញការអភិវឌ្ឍការនេសាទជាទូទៅនិងវិធានការច្បាប់ ដែលរួមទាំងការកែលម្អស្តុកមច្ឆជាតិ ។ សកម្មភាពនេះទំនងជាត្រូវការឲ្យសម្របទៅតាមលក្ខខណ្ឌនៃការប្រែប្រួលអាកាសធាតុ និងបង្កើនលទ្ធភាពនៃរបរចិញ្ចឹមជីវិតសម្រាប់រយៈពេលវែង (សូមអានខាងក្រោមបន្ថែម)។

"មានករណីជាច្រើននៃការនេសាទល្មើសច្បាប់ គ្មានរបាយការណ៍ និងគ្មានការទប់ស្កាត់ (IUU) ដែលគេមិនដឹងអំពីផលប៉ះពាល់ទាំងនេះមកលើស្តុកមច្ឆជាតរបស់កម្ពុជាឡើយ ហើយជាលទ្ធផលផលប៉ះពាល់មកលើផលប្រយោជន៍នៃផលនេសាទសមុទ្រដែលបច្ចុប្បន្ននេះប្រជាជនកម្ពុជាមិនបានទទួលឡើយ។ ការរេចរឹលទីជម្រកគឺជាកង្វល់ចំបងមួយដោយសារតែការនេសាទដោយប្រើគ្រឿងផ្ទុះ/គ្រឿងបំពុលការនេសាទល្មើសច្បាប់ដោយប្រើអួសអូសនៅក្នុងតំបន់ដែលមច្ឆជាតលូតលាស់ ការបំផ្លាញព្រៃកោងកាង (ដើម្បីផលិតអុសចិញ្ចឹមបង្គារ) ការធ្លាក់ចុះនៃកំទេចកំណកនិងការបំពុលពីទីក្រុង/ឧស្សាហកម្ម ។ ទំនាស់រវាងអ្នកនេសាទកើតមានជាទូទៅទាក់ទងនឹងសិទ្ធិចូលនេសាទនិងការត្រួតត្នានៃដែននេសាទ។ ការតាមដានត្រួតពិនិត្យនិងការឃ្លាំមើល ត្រូវបានចាត់ទុកថាគ្មានប្រសិទ្ធភាព។ កិច្ចប្រឹងប្រែងដើម្បីបង្ក្រាប/កាត់បន្ថយការនេសាទ និងស្វែងរកជម្រើស ផ្សេងនៃរបរចិញ្ចឹមជីវិតសម្រាប់អ្នកនេសាទត្រូវបានទទួលស្គាល់ប៉ុន្តែបង្ហាញជាការប្រឈមដ៏ធំសម្រាប់រាជរដ្ឋាភិបាលកម្ពុជា" (RGC 2010)។

"មានការជម្រុញយ៉ាងខ្លាំងក្លានូវសហគ្រប់គ្រង/សហគមន៍នេសាទនៅក្នុងបណ្តាឆ្នាំកន្លងទៅថ្មីៗនេះ ទោះបីកិច្ចផ្តួចផ្តើមទាំងនោះជាច្រើននៅត្រូវការឲ្យមានការគាំទ្រខាងហិរញ្ញវត្ថុ និងបច្ចេកទេសដើម្បីប្រតិបត្តិការដោយប្រសិទ្ធភាពក៏ដោយ។ ព្រះរាជក្រឹត្យនិងអនុក្រិត្យស្តីពីការគ្រប់គ្រងសហគមន៍នេសាទ ត្រូវបានប្រកាសឲ្យប្រើប្រាស់នៅឆ្នាំ២០០៥។ ដើម្បីកាត់បន្ថយការនេសាទល្មើសច្បាប់ ច្បាប់អនុញ្ញាតឲ្យមានការដាក់ទណ្ឌកម្មធ្ងន់ធ្ងរចំពោះជនល្មើសដែលរួមទាំងមន្ត្រីរដ្ឋាភិបាល។ ដើម្បីស៊ើបអង្កេតទប់ស្កាត់ និងបង្ក្រាបសកម្មភាពល្មើសច្បាប់ និងប្រមូលឯកសារសម្រាប់តុលាការមន្ត្រីរដ្ឋបាលជលផលត្រូវបានផ្តល់អំណាចជានគរបាលយុត្តិធម៌ ។ ទោះជាយ៉ាងណាក៏ដោយ មានកង្វល់ដែលទាក់ទងនឹងប្រសិទ្ធភាពនៃការអនុវត្តច្បាប់ ។ ធនធានមនុស្សហិរញ្ញវត្ថុ និងសម្ភារៈដែលផ្តល់សម្រាប់កសាងផែនការ/គ្រប់គ្រងមិនទំនងជាស្របជាមួយតម្លៃសេដ្ឋកិច្ចសង្គមនៃវិស័យនេះឡើយ។" (EU2011)

ដូច្នេះសកម្មភាពអនុវត្តបង្ហាញនេះអាចមានគោលបំណងពង្រឹងសមត្ថភាពសហគមន៍នេសាទនៅពាមក្រសោប ដើម្បីចូលរួមពេញលេញនៅក្នុងដំណើរការធ្វើសេចក្តីសម្រេចដែលនាំទៅរកនិរន្តរភាពនៃធនធានជលផលតាមរយៈកំណែលម្អការគ្រប់គ្រងនិងការផ្តល់សេវាប្រកបដោយគុណភាពដល់សមាជិករបស់ខ្លួន។

[16]បច្ចុប្បន្នេះFiA មានសហគមន៍នេសាទដែលចុះបញ្ជីរួចចំនួន ២១ នៅក្នុងតំបន់ឆ្នេរ។ ការចុះបញ្ជីជាផ្លូវការនៅ FiA ដើម្បីឲ្យក្លាយជាសហគមន៍នេសាទស្របច្បាប់គួរតែជាសកម្មភាពដែលត្រូវប្រឹងប្រែងអនុវត្ត ដូចដែលមានចែងនៅក្នុងអនុក្រឹត្យស្តីពីការគ្រប់គ្រងសហគមន៍នេសាទ។ នេះជាការបន្ថែមលើការចុះបញ្ជីជាមួយក្រសួងបរិស្ថានជា"សហគមន៍តំបន់ការពារធម្មជាតិ"។

សំណើបច្ចុប្បន្នបានផ្អែកលើការសង្កេតមួយចំនួនដូចតទៅៈ

១. សហគមន៍ពាមក្រសោបបានកំណត់ច្បាស់រួចមកហើយនូវសកម្មភាពបែបនេះថាមានអាទិភាពខ្ពស់សម្រាប់ពួកគេ ដូចគ្នានឹងការថែទាំទំនប់ដែរ។ ដូច្នេះជាការច្បាស់ណាស់ថាវាមានភាពស្របគ្នាជាមួយការថែរក្សានិងបង្កើនផលិតភាពនៃមូលដ្ឋានធនធានរបស់ពួកគេ។ ចំណុចនេះត្រូវបានអះអាងនៅក្នុងសិក្ខាសាលាតូចមួយជាមួយក្រុមប្រឹក្សាឃុំ ក្នុងខែមេសាឆ្នាំ ២០១២ (ចងក្រងនៅក្នុង "ការវាយតម្លៃភាពងាយរងគ្រោះនិងហានិភ័យ" ឧបសម្ព័ន្ធ ៣, CARP, ខែកក្កដា ២០១២)។

២. ក្របខ័ណ្ឌយុទ្ធសាស្ត្រជាតិសម្រាប់វិស័យជលផល ២០១០-២០១៩ សង្កត់ធ្ងន់លើគោលគំនិតនៃសហគមន៍នេសាទថាជាអាទិភាពរបស់ខ្លួន (RGC 2010, ទំព័រ 19)។

៣. ស្ថាប័នម្ចាស់ជំនួយភាគច្រើនដែលគាំទ្រវិស័យជលផលបានឯកភាពនិងផ្តល់មូលនិធិគាំទ្រយ៉ាងសកម្មដល់សហគមន៍នេសាទនៅកម្ពុជា។ ក្នុងចំណោមទីភ្នាក់ងារទាំងនេះរួមមានDanida, EU, JICA, និងស្ថាប័នដទៃទៀត។[17]

៤. នៅឆ្នាំ២០១០ មានសហគមន៍នេសាទសរុបមិនតិចជាង៤៦៩ នៅទូទាំងប្រទេសប៉ុន្តែមានតែ ៣២៤ ដែលបានចុះបញ្ជីជាផ្លូវការនៅរដ្ឋបាលជលផល FiA (៣០៣ ដែនទឹកសាបនិង ២១ តំបន់ឆ្នេរ)[18] ទៅតាមលក្ខខណ្ឌដែលមានចែងនៅក្នុងអនុក្រិត្យស្តីពីការគ្រប់គ្រងសហគមន៍នេសាទ។

តាមរយៈយោបល់ដែលទទួលបានយើងយល់ថាសកម្មភាពគ្រប់គ្រងធនធានធម្មជាតិបែបនេះបានសាកល្បងនៅក្រោមគម្រោងគ្រប់គ្រងតំបន់ឆ្នេរ ១៩៩៧-២០០៧ ដែលគាំទ្រដោយ Danida ដោយទទួលបានជោគជ័យក្នុងកម្រិតកំណត់ប៉ុណ្ណោះ។[19]ទោះជាយ៉ាងណាក៏ដោយកត្តាសំខាន់នៃជោគជ័យស្ថិតនៅត្រង់ ថាក្រុមប្រឹក្សាឃុំដែលពាក់ព័ន្ធត្រូវបានអនុញ្ញាតឲ្យទទួលខុសត្រូវពេញលេញពីស្ថាប័នគ្រប់គ្រងឧទ្យានជាតិ។ ប្រការនេះអាចមិនអនុវត្តទៅបាននៅក្នុងអំឡុងពេលនោះ ដោយសារក្រុមប្រឹក្សាឃុំនៅក្នុងដំណាក់កាលនោះស្ថិតក្នុងការបង្កើតនៅឡើយ។

សក្តានុពលខាងបរបិញ្ចឹមជីវិតនៃសកម្មភាពអនុវត្តបង្ហាញដែលលើកស្នើឡើងនេះគឺការបង្កើនឱកាសធ្វើការនេសាទសម្រាប់គ្រួសារនានាក្នុងឃុំពាមក្រសោបដោយសារតែត្រូវពង្រឹងការអនុវត្តច្បាប់ការបង្កើតដែនបម្រុងនិងជម្រកសម្រាប់ត្រីក៏ដូចជាបង្កើនប្រាក់ចំណូលពីអេកូទេសចរណ៍ផងដែរ។ល។ របាយការណ៍វាយតម្លៃសេដ្ឋកិច្ចគណនាប្រការនេះថា ជាផលប្រយោជន៍ជាប្រាក់ចំណូលដែលអាចទទួលបានសរុប ៣ ០២០ ដុល្លាអាមេរិក ក្នុងគ្រួសារនីមួយៗនៅក្នុងមួយឆ្នាំនៅក្រោយឆ្នាំទី ៥។

---

[17]ឯកសារយោង៖ ផែនការការងារប្រចាំឆ្នាំ ២០១២ សម្រាប់ក្របខ័ណ្ឌយុទ្ធសាស្ត្រវិស័យជលផល

[18]ក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រ ២០១០-១៩ ភាគ ២ សារតា(RGC 2010)

[19]ទោះជាយ៉ាងណាក៏ដោយ "ជោគជ័យក្នុងកម្រិតកំណត់"នេះមិនបានលើកឡើងនៅក្នុង"គម្រោងវាយតម្លៃការគ្រប់គ្រងធនធានតំបន់ឆ្នេរនៅមូលដ្ឋានឡើយ" ខែមិថុនា ២០០៧ ទាក់ទងនឹងតំបន់នានាក្នុងខេត្តកោះកុង។

លទ្ធផលនេះអាចសម្រេចបានតាមរយៈ

១. ការសង្កត់ធ្ងន់អំពីតម្រូវការឲ្យមានអង្គភាពគ្រប់គ្រងប្រកបដោយការទទួលខុសត្រូវពេញលេញសម្រាប់ដែននេសាទបម្រុងទុកនៅពាមក្រសោប និងដើម្បីកៀងគរធនធានស្របជាមួយចំណុចពិស្តារក្នុងផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ប្រសិនបើនៅពុំទាន់មានភាពស្របគ្នាបែបនេះនៅឡើយ។

២. ធ្វើឲ្យការនេសាទមានកម្រិតស្របគ្នាជាមួយសមត្ថភាពផលិត នៃស្តុកធម្មជាតិតាមរយៈការគាំទ្រដល់ការកសាងផែនការគ្រប់គ្រងប្រព័ន្ធអេកូឡូស៊ីដោយមានការចូលរួមពេញលេញរបស់អ្នកនេសាទ និងអ្នកពាក់ព័ន្ធដទៃទៀតស្របជាមួយកិច្ចប្រឹងប្រែង ដើម្បីបង្កើត និងពង្រីកវិធីបង្កើនផលស្តុក ដូចជា កិច្ចការពារព្រៃកោងកាង និងការស្តារព្រៃកោងកាងឡើងវិញ ការកំណត់ព្រំប្រទល់សម្រាប់តំបន់អភិរក្ស និងការគ្រប់គ្រងទីជម្រកសម្រាប់ត្រី។

៣. ពង្រឹងការតាមដានលើការនេសាទ ការត្រួតពិនិត្យ និងការឃ្លាំមើល (MCS) តាមរយៈការកសាងសមត្ថភាពរបស់សមាជិកសហគមន៍នេសាទ ដើម្បីអនុវត្ត MCS និងពង្រឹងការអនុវត្តច្បាប់ រួមជាមួយការពង្រីកសេវាផ្សព្វផ្សាយ ដើម្បីបំពេញបន្ថែម និងគាំទ្រដល់សេវា ដែលផ្តល់ដោយ FiA នៅថ្នាក់ខេត្ត និងស្រុក។

សកម្មភាពនានាអាចរួមបញ្ចូល (ភាគច្រើននៃសកម្មភាពទាំងនេះបានលើកស្នើដោយសមាជិកក្រុមប្រឹក្សាឃុំពាមក្រសោប)៖

- ការកំណត់ព្រំប្រទល់កន្លែងនេសាទសហគមន៍ នៅក្នុងដែនទឹករាក់ៗ
- ការបង្កើតក្រុមការពារកន្លែងនេសាទសហគមន៍
- ដាំដើមកោងកាង
- បង្កើតកន្លែងភ្ញៀវទេសចរនេសាទ
- សកម្មភាពបណ្តុះបណ្តាល និងផ្សព្វផ្សាយ ដែលរួមទាំង បច្ចេកទេសចិញ្ចឹមត្រីសមុទ្រ/វារីវប្បកម្ម ដូចជា ត្រី ក្តាម សិប្បិសត្វ កង្កែបនិងការចិញ្ចឹមបង្គារ
- លទ្ធកម្មបរិក្ខារដែលចាំបាច់សម្រាប់បង្កើនការតាមដាន ត្រួតពិនិត្យ និងឃ្លាំមើលការនេសាទ
- លើកកំពស់ការកែច្នៃ និងទីផ្សារផលនេសាទ
- ការគាំទ្រដល់ការគ្រប់គ្រង។

<u>សំណើសម្រាប់ការវាយតម្លៃសេដ្ឋកិច្ច</u>៖ ការបង្កើតនិងកំណត់ថ្លៃនៅក្នុងផែនការសកម្មភាពអនុវត្តបង្ហាញសម្រាប់ពាមក្រសោបដូចមានចែងខាងលើ នៅក្រោមកិច្ចសហការជាមួយក្រុមប្រឹក្សាឃុំពាមក្រសោប សមាជិកសហគមន៍ និងខណ្ឌជលផលខេត្តកោះកុង។

សេចក្តីព្រាងឡក់ប្រហ្វេម និងការប៉ាន់ស្មានថ្លៃចំណាយមានដូចខាងក្រោម - សម្រាប់ការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធនានា។

| សេចក្តីអធិប្បាយ | សូចនាករ | ប្រភពនៃការផ្ទៀងផ្ទាត់ | ការសន្មតិ |
|---|---|---|---|
| **សមិទ្ធផល**<br>**២៧៧ គ្រួសារកើនប្រាក់ចំណូលពីការនេសាទ និង បទប្បញ្ញត្តិ សម្រាប់ការនេសាទនៅតាមក្រសោបត្រូវបានកែប្រែ** | • បង្កើនប្រាក់ចំណេញជាមធ្យមប្រចាំគ្រួសារបាន ៣២០ដុល្លា (កើន២០%) ក្នុងរយៈពេល ៥ឆ្នាំ | • របាយការណ៍សកម្មភាព ការពិនិត្យ និងការវាយតម្លៃ | |
| **លទ្ធផល**<br>២.ការបង្កើតគម្រោងសហគមន៍នេសាទនៅតាមក្រសោប | • ការអនុវត្តសកម្មភាពសហគន៍នេសាទដោយផ្ទាល់ជាមួយ ២៧៧គ្រួសារនៅតាមក្រសោ៦ រហូតដល់ឆ្នាំ ២០១៤ | • តាមដាន ពិនិត្យ និងវាយតម្លៃសកម្មភាព | • សកម្មភាពដែលបានទទួលការគាំទ្រ នឹងបន្ថែមអត្ថប្រយោជន៍គ្រប់គ្រាន់ដល់គ្រួសារគោលដៅដើម្បីមានឥទ្ធិពលមកលើផលចំណូល |
| **សកម្មភាព ២.១**<br>ការចុះបញ្ជីសហគមន៍នេសាទតាមក្រសោបជាផ្លូវការនៅ FiA | • បានបង្កើតក្របខ័ណ្ឌច្បាប់ចាំបាច់ (លក្ខន្តិកៈ ។ល។)<br>• ការបោះឆ្នោត និង AGM<br>• ការពង្រឹងអាណត្តិ និងការព្រមព្រៀង | • ការចុះបញ្ជីនៅ FiA<br>• លក្ខន្តិកៈ ការព្រមព្រៀង កំណត់ហេតុ | • សហគមន៍នេសាទស្ថិតនៅក្នុងឧទ្យានជាតិអាចចុះបញ្ជីជាផ្លូវការជាសហគមន៍នេសាទ |

| | | | |
|---|---|---|---|
| **សកម្មភាព ២.២**<br>ការចែងពិស្តារផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ដែលរួមទាំងការថែទាំទំនប់ | • រៀបចំ និងអនុម័តផែនការគ្រប់គ្រងទីកន្លែងនេសាទសហគមន៍ | • របាយការណ៍ទីប្រឹក្សាក្នុងស្រុកដែលផ្សំដោយផែនការនេះ | • វត្តមានទីប្រឹក្សាក្នុងស្រុកដែលមានជំនាញគ្រប់គ្រាន់ |
| **សកម្មភាព ២.៣**<br>ការអនុវត្តវិធានការបង្កើនផលស្តុកមច្ឆជាត (ដូចជា ដាំ និងស្តារព្រៃកោងកាង កំណត់ព្រំប្រទល់កន្លែងអភិរក្ស និងគ្រប់គ្រងជម្រកត្រី) | • ការអនុវត្តផែនការ CFi, កិច្ចប្រឹងប្រែងអភិរក្ស,ការកំណត់ព្រំប្រទល់ CFi | • របាយការណ៍គម្រោង និង FiA | • អ្នកពាក់ព័ន្ធនឹងឯកភាពចំពោះវិធានការបែបនេះ |
| **សកម្មភាព ២.៤**<br>ពង្រឹងវិធានការតាមដាន ការត្រួតពិនិត្យ និងឃ្លាំមើល ដែលរួមទាំង លទ្ធកម្មបរិក្ខារ | • ការវាយតម្លៃតម្រូវការបរិក្ខារ (ដូចជា ទូកតូចៗសម្រាប់ពង្រឹងការអនុវត្តច្បាប់និង/ឬ ម៉ាស៊ីន)<br>• ចាត់ចែងការបណ្តុះបណ្តាល និងបណ្តុះបណ្តាលអ្នកប្រើប្រាស់<br>• ទស្សនកិច្ចសិក្សា និងបង្កើតបណ្តាញជាមួយសហគមន៍ប្រហែលគ្នា | • ការតាមដានសកម្មភាពនិងលទ្ធផលគម្រោង<br>• របាយការណ៍ទស្សនកិច្ចសិក្សា | • គ្រួសារក្នុងសហគមន៍មានចំណាប់អារម្មណ៍ចូលរួម |

| | | | |
|---|---|---|---|
| **សកម្មភាព ២.៥**<br>ពង្រីកសេវាផ្សព្វផ្សាយដើម្បីបំពេញបន្ថែម និងគាំទ្រសេវាដែលផ្តល់ដោយ FiA នៅថ្នាក់ស្រុក និងខេត្ត ដែលរួមទាំង ជម្រុញការកែច្នៃ និងទីផ្សារផលិតផលនេសាទ | • ការវិភាគតម្រូវការបណ្តុះបណ្តាល<br>• បង្កើតនិងចាត់ចែងការបណ្តុះបណ្តាល និងសកម្មភាពផ្សព្វផ្សាយ<br>• ការបង្កើតទំនាក់ទំនងនិងកិច្ចសន្យាពាណិជ្ជកម្ម | • របាយការណ៍បណ្តុះបណ្តាល និងសកម្មភាពផ្សព្វផ្សាយ | • សហគមន៍និងគ្រូបង្ហាត់មានចំណាប់អារម្មណ៍ក្នុងការគាំទ្របែបនេះ |
| **សកម្មភាព ២.៦**<br>ការបង្កើតមូលដ្ឋានសម្រាប់បន្តនិរន្តរភាពនៃការបណ្តុះបណ្តាលរម្លឹក និងអាចជាការគាំទ្របែបផ្សេងសម្រាប់ការផ្សព្វផ្សាយស្របជាមួយវិធានការខាងលើ (មិនសូវខ្លាំងក្លា)ត្រូវបន្តក្រោយចប់គម្រោង | • ការចាត់ចែងកិច្ចសន្យាជាមួយ PFiA, ក្រុមប្រឹក្សាស្រុក និងឃុំ<br>• អាចពាក់ព័ន្ធនឹងមូលនិធិឃុំ ដែលត្រូវបំពេញឡើងវិញតាមរយៈវិភាគទានពីមូលដ្ឋាន និងថ្នាក់ជាតិ | • ការចាត់ចែងកិច្ចសន្យា និងតាមដាន | • អាជ្ញាធរមានចំណាប់អារម្មណ៍លើការចាត់ចែងបែបនេះ |
| **សកម្មភាព ២.៧**<br>ការតាមដាននិងចងក្រងជាឯកសារអំពីឥទ្ធិពល និងបទពិសោធន៍ពីជំហាន i-vi. (បន្តជាហូរហែរ) | • ការតាមដានដោយបុគ្គលិកគម្រោង និងអ្នកពិនិត្យពីស្ថាប័នខាងក្រៅ | របាយការណ៍តាមដាន និងពិនិត្យ | |

## តារាង ២៖ ការប៉ាន់ស្មានថ្លៃចំណាយ

| ជំហាន | <u>ការប៉ាន់ស្មានថ្លៃចំណាយ(លំអិត)</u> | ចំនួន ($) |
|---|---|---|
| **សកម្មភាព ២.១** | ការចុះបញ្ជីសហគមន៍ពាមក្រសោបជាផ្លូវការនៅFiAដើម្បីក្លាយជាសហគមន៍នេសាទ (ប្រសិនបើនៅពុំទាន់បានធ្វើបែបនេះ) | ១.០០០ |
| **សកម្មភាព ២.២** | ផែនការគ្រប់គ្រងកន្លែងសហគមន៍នេសាទ<br><u>ថ្លៃទីប្រឹក្សា</u><br>២០នាក់ ថ្ងៃ @ $២០០ = ៤.០០០<br>ភស្តុភា និងសម្ភារៈ = ១.០០០ | ៥.០០០ |
| **សកម្មភាព ២.៣** | ការអនុវត្តវិធានការបង្កើនផលស្តុកមច្ឆជាត (ដូចជា ការពារ និងស្តារកោងកាងឡើងវិញ កំណត់ព្រំប្រទល់កន្លែងអភិរក្ស និងគ្រប់គ្រងជម្រកត្រី)<br>ភស្តុភា២.០០០<br>សម្ភារៈ ៨.០០០ | ១០.០០០ |
| **សកម្មភាព ២.៤** | ពង្រឹងវិធានការតាមដាន ការត្រួតពិនិត្យ និងឃ្លាំមើលការនេសាទដែលរួមទាំង លទ្ធកម្មបរិក្ខារ<br>វាយតម្លៃតម្រូវការ ១.០០០<br>បរិក្ខារ១៩.០០០ | ២០.០០០ |
| **សកម្មភាព ២.៥** | ពង្រីកសេវាផ្សព្វផ្សាយដើម្បីបំពេញបន្ថែម និងគាំទ្រសេវាដែលផ្តល់ដោយ FiA នៅថ្នាក់ស្រុក និងខេត្ត ដែលរួមទាំង ជម្រុញ *ការកែច្នៃ និងទីផ្សារផលិតផលនេសាទ*<br>វាយតម្លៃតម្រូវការបណ្តុះបណ្តាល១.០០០<br>ការបណ្តុះបណ្តាល និងផ្សព្វផ្សាយ ១០.០០០<br>ទស្សនកិច្ចសិក្សា១០.០០០ | ២១.០០០ |
| **សកម្មភាព ២.៦** | ការបង្កើតមូលដ្ឋានសម្រាប់បន្តនិរន្តរភាពនៃការបណ្តុះបណ្តាលរម្លឹក និងអាចជាការគាំទ្របែបផ្សេងសម្រាប់ការផ្សព្វផ្សាយ ស្របជាមួយវិធានការខាងលើ (មិនសូវខ្លាំងក្លា) ត្រូវបន្តក្រោយចប់គម្រោង | ២០.០០០ |
| **សកម្មភាព ២.៧** | ការតាមដានគម្រោងដែលជាផ្នែកមួយនៃ កិច្ចការគ្រប់គ្រងជាធម្មតា។ ការពិត្យដោយស្ថាប័នខាងក្រៅ៖ ១០នាក់ថ្ងៃ @ $២០០ = $ ២០០០ + ភស្តុភា។ល។ $១០០០ | ៣.០០០ |
| **សរុប** | | $៨០.០០០ |

ក្រុមប្រឹក្សាសហគមន៍ពាមក្រសោបប្រហែលអាចចូលរួមក្នុងការផ្តល់មូលនិធិសម្រាប់សកម្មភាពទាំងនេះ។ ការធ្វើបែបនេះ ដើម្បីបង្កើនភាពជាម្ចាស់ និងការប្តេជ្ញារបស់សហគមន៍។ ដូច្នេះ គួរពិចារណាអំពីថ្លៃបម្រុងយថាភាពនៅក្នុងថ្លៃចំណាយខាងលើ។

**៣. ការលើកកំពស់ និងបង្កើនវត្តមានពូជដំណាំដែលឆាប់ផ្តល់ផល ជាពិសេស ស្រូវស្រាលវស្សា អាចសម្រួលដល់ការប្រមូលផលមុនពេលទឹកជំនន់ធំមកដល់ និងការឡើងកំពស់ទឹកសមុទ្រនៅក្នុងឃុំគោលដៅ។ គេត្រូវសាកល្បងពូជដំណាំបែបនេះ(ដោយកសិករមិនមែនជាអ្នកត្រូវប្រឈមហានិភ័យ ឬបង់ខាតឡើយ) នៅក្នុងទីតាំងជាក់លាក់ ដែលទំនងជាមានប្រសិទ្ធភាព។ កិច្ចការនេះអាចរាប់បញ្ចូលការសាកល្បងពូជដំណាំដទៃទៀតជាបន្ថែម ដូចជា បន្លែ។**

ដោយសារសកម្មភាពនេះអាចជាផ្នែកមួយនៃសកម្មភាព ១ វាក៏អាចអនុវត្តជាសកម្មភាពដាច់ដោយឡែកផងដែរ។ នេះក៏ដោយសារលក្ខណៈពិសេសនៃការសាកល្បងពិសោធន៍ ឬការស្រាវជ្រាវបែបបន្សាំ ដែលទំនងជាត្រូវការឲ្យមានការចូលរួមពីអង្គភាពស្រាវជ្រាវដែលមានបទពិសោធន៍នៅក្នុងសកម្មភាពបែបនេះ (ដូចជា វិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្ម (CARDI))។

មន្ទីរកសិកម្មខេត្ត និងក្រុមប្រឹក្សាឃុំ អាចនិងគួរតែចូលរួម និងបានទទួលតួនាទីនៅក្នុងបរិបទនេះ។ ទោះជាយ៉ាងណាក៏ដោយ បច្ចុប្បន្ននេះ ទាំងមន្ទីរកសិកម្មខេត្ត និងក្រុមប្រឹក្សាឃុំប្រហែលជាពុំមានសមត្ថភាពដើម្បីដឹកនាំសកម្មភាពបែបនេះឡើយ។ ប៉ុន្តែ នៅក្នុងអំឡុងពេលនៃគម្រោង CARP សកម្មភាពនេះអាចបង្កើតសមត្ថភាពបែបនេះនៅក្នុងមន្ទីរកសិកម្មខេត្ត។

គម្រោង NAPA ដំបូងបានចុះកិច្ចសន្យាជាមួយវិទ្យាស្ថាន CARDI សម្រាប់សកម្មភាពប្រហែលគ្នានេះ។ កិច្ចសន្យានេះចែងអំពីផ្នែកដ៏ទៃ នៃការស្រាវជ្រាវកសិកម្មបែបបន្សាំ។

**<u>សំណើ</u>៖** បង្កើត និងចរចាកិច្ចសន្យាជាមួយវិទ្យាស្ថាន CARDI សម្រាប់គោលបំណងខាងលើ។ កិច្ចការនេះអាចរួមបញ្ចូលសកម្មភាពដទៃទៀត ដូចជា ការសាកល្បងបន្លែនៅតាមច្បារ ទិវាស្រែកសិករ និងការបណ្តុះបណ្តាលអំពីការជ្រើសរើសពូជ។

សកម្មភាពនេះគួរតែបានទទួលការសម្របសម្រួល ជាពិសេស ជាមួយសកម្មភាព ១៖ ការប្រែប្រួលអាកាសធាតុ និងការដាំដំណាំចម្រុះ។

| សេចក្តីអធិប្បាយ | សូចនាករ | ប្រភពនៃការផ្ទៀងផ្ទាត់ | ការសន្មតិ |
|---|---|---|---|
| **សមិទ្ធផល**<br>***ជានា និងបង្កើនប្រាក់ចំណូលប្រចាំគ្រួសារពីស្រែ និងបន្លែ ឲ្យដល់ ៦០០០ គ្រួសារកសិករ*** | • គ្រួសារចំនួន ២០% ទទួលយក ដោយ បានលទ្ធផលជាកំណើនប្រាក់ចំណូល ២០០ដុល្លាក្នុងមួយហិកតា | • របាយការណ៍ ការពិនិត្យ និងការវាយតម្លៃសកម្មភាព | |
| **លទ្ធផល**<br>ការជម្រុញ និងការសាកល្បងតាមវាលស្រែនូវពូជស្រូវស្រាដែលផ្តល់ទិន្នផលខ្ពស់ ក្នុងរដូវ វស្សានៅព្រៃនប់និងទួលគរគី | • ការអនុវត្តសាកល្បងតាមវាលស្រែ ទិវាស្រែកសិករ និងការបណ្តុះបណ្តាល អំពីពូជស្រូវដល់ប្រមាណ៦០០០គ្រួសារកសិករ ក្នុងឃុំចំនួន ៧ រហូតដល់ឆ្នាំ ២០១៤ | • ការតាមដាន ការពិនិត្យ និងវាយតម្លៃសកម្មភាព | • សកម្មភាពដែលបានគាំទ្រនឹងបន្ថែមទំនុកចិត្តគ្រប់គ្រាន់ដល់គ្រួសារកសិករ ដើម្បីទទួលយកអនុសាសន៍ និងទទួលបានឥទ្ធិពលជាផលចំណូល |
| **សកម្មភាព ៣.១**<br>អនុវត្តសាកល្បងបែបបន្សាំនៅតាមវាលស្រែក្នុងរដូវវស្សា (OFAT) លើពូជស្រូវស្រាល | • ការសាកល្បងត្រូវបានអនុវត្ត និងចងក្រងជាឯកសារអំពីទីតាំងចំនួន ២០ ក្នុងឃុំចំនួន ៧ នៅក្នុងឆ្នាំ ២០១៣ | • របាយការណ៍អំពីការសាកល្បង | • CARDI និង PDA មានសមត្ថភាពគ្រប់គ្រាន់ដើម្បីអនុវត្តការសាកល្បង |

| | | | |
|---|---|---|---|
| **សកម្មភាព ៣.២**<br>អនុវត្តសាកល្បងបែបបន្សាំនៅតាមវាលស្រែក្នុងរដូវវស្សា(OFAT) លើពូជបន្ថែមមួយចំនួន | • ការសាកល្បងអនុវត្ត និងចងក្រងជាឯកសារលើទីតាំងចំនួន ២០ ក្នុង៧ឃុំ រវាងឆ្នាំ ២០១២-១៤ | • របាយការណ៍អំពីការសាកល្បង | • CARDI និង PDA មានសមត្ថភាពគ្រប់គ្រាន់ដើម្បីអនុវត្តការសាកល្បង |
| **សកម្មភាព ៣.៣**<br>អនុវត្តទិវាសាលាស្រែកសិករ (FFD) ជាមួយឃុំមួយចំនួន | • បានរៀបចំទិវាស្រែកសិករចំនួន ១០លើក | • របាយការណ៍អំពីការសាកល្បង | • កសិករមានចំណាប់អារម្មណ៍ចូលរួម |
| **សកម្មភាព ៣.៤**<br>អនុវត្តបង្ហាញអំពីការបន្សុទ្ធពូជ (មួយក្នុងមួយឃុំ) និងបណ្តុះបណ្តាលក្រុមកសិករអំពីបច្ចេកទេសបន្សុទ្ធពូជ | • ការអនុវត្តបង្ហាញវិធីបន្សុទ្ធពូជចំនួន៧<br>• កសិករ ២៨នាក់បានទទួលការបណ្តុះបណ្តាលអំពីការបន្សុទ្ធពូជ | • របាយការអំពីការបន្សុទ្ធពូជ | • កសិករមានចំណាប់អារម្មណ៍ចូលរួម |
| **សកម្មភាព ៣.៥**<br>ការតាមដាននិងចងក្រងជាឯកសារអំពីឥទ្ធិពលនិងបទពិសោធន៍ពីជំហានi-vi. (បន្តជាហូរហែរ) | • ការតាមដានដោយបុគ្គលិកគម្រោង និងដោយអ្នកពិនិត្យពីស្ថាប័នខាងក្រៅ | • របាយការណ៍តាមដាន និងពិនិត្យ | ថ្លៃចំណាយ៖<br>ការតាមដានគម្រោងជាផ្នែកមួយនៃកិច្ចការជាធម្មតានៃការគ្រប់គ្រងដោយគ្មានការចំណាយបន្ថែមឡើយ |

## តារាង ៣៖ ការប៉ាន់ស្មានថ្លៃចំណាយ

| ជំហាន | ការប៉ាន់ស្មានថ្លៃចំណាយ(លំអិត) | ចំនួន ($) |
|---|---|---|
| **សកម្មភាព ៣.១** | OFAT ចំនួន ២០ សម្រាប់ស្រូវ @ $ ៦០០ | ១២.០០០ |
| **សកម្មភាព ៣.២** | OFAT ចំនួន ២០ សម្រាប់បន្លែ @ $ ៦០០ | ១២.០០០ |
| **សកម្មភាព ៣.៣** | ទិវាសាលាស្រែកសិករចំនួន ១០លើក | ៥.០០០ |
| **សកម្មភាព ៣.៤** | អនុវត្តបង្ហាញ និងការបណ្ដុះបណ្ដាលអំពីការបន្សុទ្ធពូជ | ២.៥០០ |
| | បម្រុងយថាភាព | ២.០០០ |
| **សរុប** | | ៣៥.០០០ |

**៤. លើកកំពស់ការចិញ្ចឹមសត្វនៅក្នុងឃុំចំនួន ៥ ដោយប្រើប្រាស់ប្រព័ន្ធទុនបង្វិលនិងកែលម្អពូជជាបន្តបន្ទាប់ - បានសាកល្បងដោយជោគជ័យនៅកម្ពុជា ឡាវ និងកន្លែងដទៃ។ នេះជាវិធានការឆ្លើយតប ទៅនឹងបញ្ហាទឹកជំនន់ ដោយសារគេអាចចល័តសត្វចិញ្ចឹមបាន ក៏ដូចជា ឆ្លើយតបនឹងវត្តមានដើមទុន និងប្រាក់ចំណូលរបស់កសិករដែលចូលរួមផងដែរ។ ទោះបីសត្វចិញ្ចឹមត្រូវការទឹក និងចំណី នៅក្នុងរដូវប្រាំងក៏ដោយ បរិមាណទឹកដែលត្រូវការក៏តិចជាងសម្រាប់ ដូចជា ដីស្រែមួយហិកតា ចំណែកការអភិរក្សចំណីសត្វ អាចជួយបំពេញតម្រូវការក្នុងរដូវប្រាំងផងដែរ។**

"កំណើនព្រឹត្តិការណ៍ធាតុអាកាសមិនប្រក្រតី ដូចជា គ្រោះរាំងស្ងួត និងទឹកជំនន់ ទំនងជាបង្កើនសារៈសំខាន់នៃសត្វចិញ្ចឹមសម្រាប់គ្រួសារនៅជនបទ ជាពិសេស គ្រួសារក្រីក្រនិងដែលរស់នៅដាច់ស្រយាល។ សត្វចិញ្ចឹមមានភាពធន់នឹងអាកាសធាតុ និងការប្រែប្រួលតាមធម្មជាតិ ឬ គ្រោះមហន្តរាយ ធៀបនឹងដំណាំកសិកម្ម ដោយសារតែគេអាចជម្លៀសសត្វ និងអាចរកវិធីដើម្បីសង្គ្រោះពីព្រឹត្តិការណ៍នានា សូម្បីតែព្រឹត្តិការណ៍នោះអាចបំផ្លាញដំណាំក៏ដោយ។ សម្រាប់គ្រួសារនៅជនបទ ជាពិសេសគ្រួសារក្រីក្រនៅជនបទ សត្វចិញ្ចឹមមានសារៈសំខាន់ជាបឋម មិនត្រឹមតែជាកម្លាំងអូសទាញឬសម្រាប់ពិធីតាមប្រពៃណី និងការលក់យកប្រាក់ក្នុងគ្រាអាសន្នប៉ុណ្ណោះទេ ប៉ុន្តែក៏សម្រាប់ផ្តល់ជាប្រភពប្រាក់ចំណូល ការសន្សំ និងការបន្សុាំនឹងការប្រែប្រួលអាកាសធាតុផងដែរ" (EU 2012, ទំព័រ 12)។

ជំពូកបញ្ហាចំបងៗដែលកើតមានចំពោះផលិតកម្មសត្វនៅកម្ពុជាគឺ (ក) ជម្ងឺ (ខ) អាហារូបត្ថម្ភខ្សត់ខ្សោយ និង(គ)សក្តានុពលទាបនៃហ្សែនក្នុងចំណោមពូជក្នុងមូលដ្ឋាន។ គេអាចកាត់បន្ថយជម្ងឺទៅបានតាមរយៈការចាក់ថ្នាំបង្ការ ការធ្វើចត្តាឡីស័ក និងវិធានការគ្រប់គ្រង។ ការបង្កើនរបបអាហារូបត្ថម្ភ ទាក់ទងនឹងការគ្រប់គ្រង និងបញ្ហាវត្តមានចំណី។ ជាមួយកំណើនចំនួនសត្វ វត្តមានចំណីស្ងួត ឬ ចំណីស្រស់ក្នុងធម្មជាតិក៏កាន់តែខ្សត់ផងដែរ។ កសិករក៏ខ្វះចំណេះដឹង និងដើមទុនដើម្បីកែលម្អស្ថានភាពនេះផងដែរ។ ដូចគ្នានេះដែរមានការលើកទឹកចិត្តតិចតួចប៉ុណ្ណោះដើម្បីកែលម្អសក្តានុពលហ្សែននៃពូជសត្វ។

ទោះជាយ៉ាងណាក៏ដោយ មានការយល់ឃើញថា ប្រព័ន្ធចិញ្ចឹមសត្វដើម្បីកែលម្អពូជ អាចដោះស្រាយបញ្ហាដូចបានកត់សំគាល់ខាងលើ។ លើសពីនេះ វានឹងបង្កើនដើមទុន ប្រាក់ចំណូល និងមូលដ្ឋានសម្រាប់អាហារូបត្ថម្ភនៃក្រុមគ្រួសារដែលពាក់ព័ន្ធដូច្នេះវាអាចជួយលើកកំពស់របរចិញ្ចឹមជីវិតទៅអនាគតផងដែរ។ ប្រព័ន្ធនេះអាចដំណើរការដូចតទៅ៖

១. ត្រូវជ្រើសរើសកសិករមួយចំនួននៅក្នុងឃុំនីមួយៗដើម្បីទទួល (ជំនួយឥតសំណង និងជាប់កាតព្វកិច្ច) សត្វញីដែលជាពូជកែលម្អ។ ពូជដែលបានជ្រើសរើស ត្រូវតែមានអំណះអំណាងគ្រប់គ្រាន់អំពីផលិតភាពនៅក្នុងលក្ខខណ្ឌនៃប្រទេសកម្ពុជា។ <u>វាអាចជាជ្រូក ឬ សត្វស្លាបតូចៗ ដូចជា ទា ឬ មាន់</u> អាស្រ័យលើការនិយម និងលក្ខខណ្ឌនៅមូលដ្ឋាន។

២. លក្ខខណ្ឌដំបូងគឺថា សត្វញីដំបូង[20] (និងអាច) កូនដែលកើតចេញពីសត្វដែលជាពូជកែលម្អទាំងនេះត្រូវបញ្ជូនបន្ត (ជាជំនួយឥតសំណងជាប់កាតព្វកិច្ច) ទៅកសិករផ្សេងទៀតនៅក្នុងឃុំ ឬ ភូមិតែមួយ។ លក្ខខណ្ឌដើមមួយទៀតគឺថា កសិករនោះត្រូវយល់ព្រមទទួលយោបល់ណែនាំ និងអនុវត្តតាមគោលការណ៍ណែនាំមួយចំនួនអំពីការថែទាំសត្វទាំងនេះ។ ត្រូវមានការចុះកិច្ចសន្យារវាងកសិករនោះ និងក្រុមប្រឹក្សាឃុំប្រសិនបើសមស្រប។ តាមរបៀបនេះ គេ"ត្រូវបញ្ជូន"អំណោយនេះជាបន្តតាមគោលការណ៍នេះ ទៅអ្នកដទៃទៀត ដោយគ្មានកាលកំណត់ ឬ យ៉ាងហោចណាស់រហូតដល់គ្រួសារដែលមានចំណាប់អារម្មណ៍សុទ្ធតែបានទទួលពូជកែលម្អនេះ។

៣. ត្រូវមានសេវាគាំទ្រលើការងារផ្សព្វផ្សាយនិងកំចាត់ជម្ងឺ តាមរយៈបុគ្គលិកសុខភាពសត្វ ភូមិ (VAHW)[21] ក៏ដូចជា ពីមន្ទីរផលិតកម្មនិងបសុព្យាបាលខេត្តផងដែរ។ ការបណ្តុះបណ្តាលសមស្របដល់ភ្នាក់ងារផ្សព្វផ្សាយទាំងនេះអាចរួមបញ្ចូលទៅក្នុងសកម្មភាព ១ ប្រសិនបើអាចធ្វើបាន (នៅត្រូវធ្វើការសម្រេច)។

៤. ត្រូវបង្កើតក្រុមកសិករ ឬ អង្គការសហគមន៍មួយ នៅក្នុងភូមិនីមួយៗដែលចូលរួមក្នុងសកម្មភាពនេះ ដើម្បីទទួលខុសត្រូវលើវិធានការសមស្របនៅក្នុងបរិបទនេះ[22]និងផ្តល់មូលដ្ឋានសម្រាប់ការកត់ត្រា និងដំណើរការជ្រើសរើស ដែលប្រសិនបើគ្មានមូលដ្ឋានបែបនេះទេ ការផ្តល់ពូជសត្វបែបនេះនឹងត្រូវធ្លាក់ក្នុងស្ថានភាពដែលមិនអាចតាមដានបានឡើយ។

៥. ការបែងចែកពូជសត្វគួរតែធ្វើឡើងជាក្រុម ដែលមានភូមិ ឬ ក្រុមកសិករចំនួន ១០ដែលអាច (ក)ផ្តល់ការគាំទ្រគ្នាទៅវិញទៅមក និង (ខ)កាត់បន្ថយថ្លៃចំណាយភស្តុភា។

ការអនុវត្តសកម្មភាពបង្ហាញនេះ អាចធ្វើឡើងតាមរយៈអង្គការមិនមែនរដ្ឋាភិបាល ឬអង្គការប្រហែលគ្នានេះដែលមានបទពិសោធន៍ប្រតិបត្តិការប្រព័ន្ធបែបនេះ ឬយ៉ាងហោចណាស់មានបទពិសោធន៍ជម្រុញផលិតកម្មសត្វ។ ក្រុមប្រឹក្សាឃុំត្រូវតែចូលរួមជាភាគីមួយនៅក្នុងកិច្ចសន្យានេះ ប៉ុន្តែខ្លួនឯងពុំមានបទពិសោធន៍ និងសមត្ថភាពគ្រប់គ្រាន់ ដើម្បីដើរតួជាអ្នកគ្រប់គ្រងសកម្មភាពនេះទេ។

ដូច្នេះ សកម្មភាពបង្ហាញនេះអាចផ្តល់ជាពូជសម្រាប់កសិករចាប់ផ្តើម ក៏ដូចជា ការចាក់ថ្នាំបង្ការ ចំណីថ្នាំទម្លាក់ព្រូន និងក្នុងការចាត់ចែងកត់ត្រានៅក្នុងក្រុមកសិករផងដែរ។ កិច្ចការនេះនឹងត្រូវភ្ជាប់ជាមួយការណែ

---

[20]ឬសមមូលជាសាច់ប្រាក់។

[21]នាយកដ្ឋានផលិតកម្មនិងបសុព្យាបាលនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានបញ្ជាក់អំពីវត្តមានច្រើនជាង ១៤.០០០ VAHW នៅកម្ពុជា។ VAHW ទាំងនេះបានទទួលការបណ្តុះបណ្តាលងាយៗ និងអាចអនុវត្តកិច្ចការងាយៗសម្រាប់ការពារជម្ងឺ ការឃ្លាំមើល និងផលិតកម្មសត្វ។ នេះជាគោលនយោបាយរបស់ក្រសួងនេះ ក្នុងការបម្លែងVAHWភាគច្រើនឲ្យទៅជាបុគ្គលិកផ្សព្វផ្សាយកសិកម្មទូទៅនៅក្នុងភូមិ និងប្រមាណ ៥០% បានទទួលការបណ្តុះបណ្តាលអំពីការផ្សព្វផ្សាយទូទៅនៅក្នុងបរិបទនេះ នៅក្នុងឆ្នាំ ២០១២។VAHWគឺជាភ្នាក់ងារឯកជន និងមិនទទួលប្រាក់បៀវត្សរ៍ពីរដ្ឋាភិបាលឡើយ។ វត្តមានរបស់ពួកគេនៅក្នុងឃុំគោលដៅត្រូវបានក្រុមការងារនៅទួលគរគី បញ្ជាក់ ប៉ុន្តែមិនមាននៅព្រៃនប់ឡើយ។

[22]ក្រុមប្រឹក្សាឃុំអាចដើរតួនៅក្នុងកិច្ចការនេះផងដែរ ប៉ុន្តែមិនអាចជំនួសក្រុមគាំទ្រថ្នាក់ភូមិ ដែលមានឯកទេសផលិតកម្មសត្វឡើយ នៅក្នុងបរិបទនេះ។

នាំជាទៀងទាត់លើការគ្រប់គ្រងសត្វចិញ្ចឹម អាហារូបត្ថម្ភ ការកត់ត្រា ការកែលម្អវាលស្មៅ ការអភិរក្សចំណីស្ងួត ។ល។ ការលើកទឹកចិត្តសម្រាប់កត់ត្រា ការជ្រើសរើសពូជ និងកែលម្អការគ្រប់គ្រងអាចផ្ដល់តាមរយៈការចាត់ចែងឲ្យមានពិពណ៌ជនបទ ដែលក្នុងនោះ អាចមានការផ្ដល់រង្វាន់ដល់កសិករដែលអនុវត្តបានល្អជាងគេ។ រង្វាន់ជាប្រាក់ (ឬមិនមែនជាសាច់ប្រាក់) អាចផ្ដល់ទៅឲ្យវិស័យឯកជន ជាសកម្មភាពផ្សព្វផ្សាយ (ក្រុមហ៊ុនចំណីសត្វ ស៊ីភី ហ្វាម៉ា វ៉ាក់ស៊ីន...)។

ការធ្វើបែបនេះនឹងផ្ដល់ឲ្យកសិករនូវឧបករណ៍ដើម្បីបង្កើនប្រាក់ចំណេញពីផលិតកម្មសត្វ ទន្ទឹមនឹងដោះស្រាយកង្វល់ចំបងៗ ពោលគឺកសិករខ្វះដើមទុនសម្រាប់ការវិនិយោគ។ កិច្ចការនេះត្រូវអនុវត្តដោយពុំចាំបាច់ផ្ដល់ជាជំនួយដោយផ្ទាល់ឡើយ ដែលជាការបាត់បង់ភាពម្ចាស់ការ និងទឹកចិត្ត។

គោលគំនិតនេះ បានផ្អែកលើបទពិសោធន៍ពីគម្រោងទ្រទ្រង់កសិករចិញ្ចឹមសត្វនៅប្រទេសឡាវ កម្មវិធីផលិតកម្មសត្វសម្រាប់គ្រួសារតូចតាច (SLPP) នៅកម្ពុជា ឆ្នាំ ២០០៥-១០ ដែលទទួលមូលនិធិពីសហភាពអឺរ៉ុប និងគម្រោងប្រហែលគ្នានេះនៅកន្លែងដទៃទៀត។ គម្រោងគ្រប់គ្រងតំបន់ឆ្នេ១៩៩៧-២០០៧ ក៏បានប្រើប្រាស់គោលការណ៍នេះផងដែរ។ បទពិសោធន៍នេះបានបង្ហាញថា ប្រព័ន្ធនេះ"បញ្ជូនអំណោយជាបន្ត"(អនុវត្តដោយអង្គការ Heifer International[23]អស់រយៈពេលជាច្រើនឆ្នាំ) ជាវិធីដែលមានប្រសិទ្ធភាពសម្រាប់ណែនាំអំពីការគ្រប់គ្រងសត្វចិញ្ចឹមឲ្យបានល្អ។ បច្ចុប្បន្នវាក្លាយជាផ្នែកមួយផងដែរនៃកម្មវិធីអនុវិស័យចិញ្ចឹមសត្វដែលទទួលមូលនិធិពីសហភាពអឺរ៉ុប សម្រាប់ប្រទេសកម្ពុជា ដែលនឹងត្រូវចាប់ផ្ដើមនៅដើមឆ្នាំ២០១៣។

**<u>សំណើ</u>៖** គួរបង្កើត និងកំណត់ថ្លៃចំណាយសម្រាប់អនុវត្តផែនការផ្ដល់សត្វចិញ្ចឹមដូចអធិប្បាយខាងលើ។ នៅក្នុងកិច្ចការនេះ ត្រូវសង្កត់ធ្ងន់លើការ(១)ដាក់ឲ្យប្រព័ន្ធនេះចាប់ដំណើរការ និងបញ្ចប់ជុំដំបូងនៅមុនការបញ្ចប់ CARP ក្នុងដើមឆ្នាំ ២០១៤ និង(២) បង្កើតក្រុមកសិករដែលមាននិរន្តរភាព និងយន្តការគាំទ្រឲ្យបានមុនបញ្ចប់ CARP នៅឆ្នាំ ២០១៤ – ដែលអាចធានាថា ជុំនៃការផ្ដល់ពូជអាចបន្តដោយផ្អែកលើសត្វដែលបានផ្ដល់នៅក្នុងជុំដំបូង។

---

[23] Heifer International ក៏ធ្លាប់បានអនុវត្តសកម្មភាពប្រហែលគ្នានេះដែរនៅក្រោមគម្រោងគ្រប់គ្រងតំបន់ឆ្នេរ ១៩៩៧-២០០៧។

| សេចក្តីអធិប្បាយ | សូចនាករ | ប្រភពនៃការផ្ទៀងផ្ទាត់ | ការសន្មតិ |
|---|---|---|---|
| **សមិទ្ធផល**<br>***បង្កើនទ្វេដងនូវប្រាក់ចំណូលរបស់គ្រួសារដែលចូលរួមក្នុងសកម្មភាពចិញ្ចឹមសត្វ*** | • បង្កើនប្រាក់ចំណេញមធ្យមប្រចាំគ្រួសារ $២០០ ក្នុងមួយឆ្នាំ[24]សម្រាប់គ្រួសារចូលរួមទាំង ១០០ នៅក្រោយឆ្នាំទី ១ – ដោយមាន ៥០ គ្រួសារបន្ថែមទៀតក្នុងមួយឆ្នាំ ជាបន្តបន្ទាប់ | • របាយការណ៍ ការពិនិត្យ និងវាយតម្លៃសកម្មភាព | |
| **លទ្ធផល ៤**<br>ប្រព័ន្ធបង្វិលពូជសម្រាប់កែលម្អការចិញ្ចឹមសត្វ | • ការអនុវត្តប្រព័ន្ធផ្តល់ពូជជាបន្តបន្ទាប់ដល់គ្រួសារចំនួន១០០ ដោយផ្ទាល់ នៅក្នុងជុំទីមួយនៃការផ្តល់ក្នុង៧ឃុំរហូតដល់ឆ្នាំ ២០១៤ | • របាយការណ៍ ការពិនិត្យ និងវាយតម្លៃសកម្មភាព | • សកម្មភាពដែលគាំទ្រ នឹងបន្ថែមទំនុកចិត្តគ្រប់គ្រាន់សម្រាប់គ្រួសារកសិករ ដើម្បីទទួលយកអនុសាស្ត្រ និងទទួលបានឥទ្ធិពលជាប្រាក់ចំណូល |

[24]យោង ឧបសម្ព័ន្ធ ២ ដែលថវិកាសម្រាប់សត្វចិញ្ចឹម (មួយផ្នែក) បង្ហាញថា កម្រិតនៃកំណើនប្រាក់ចំណូលបែបនេះ អាចទទួលបានសម្រាប់គ្រប់ប្រភេទសត្វទាំងអស់ដែលចិញ្ចឹមនៅក្នុងតំបន់ឆ្នេរ។

| | | | |
|---|---|---|---|
| **សកម្មភាព ៤.១**<br>បង្កើតផែនការសម្រាប់ប្រព័ន្ធផ្តល់ពូជ ដែលរួមទាំង៖<br>• សកម្មភាពពិស្តារនិងគំរូដែលបានកំណត់ (ពោលគឺ ពូជ ការចែកចាយ ការផ្តល់ថ្នាំបង្ការ ការបណ្តុះបណ្តាលកសិករ ការជម្រុញផលិតកម្មចំណីស្ងួត ការផលិតចំណីតាមកសិដ្ឋាន ការអភិរក្សចំណីសត្វ។ល។)<br>• កំណត់រកអ្នកទទួលផល និងដៃគូ<br>• បង្កើតនីតិវិធីចុះកិច្ចសន្យា | • ផែនការ និងការអនុម័ត<br>• ការធ្វើឲ្យ DAHP, PDA និងបុគ្គលិកសុខភាពសត្វភូមិ (VAHW)បានចូលរួម | • ឯកសារផែនការ និងរបាយការណ៍គម្រោង | • វត្តមានជំនាញសម្រាប់កសាងផែនការ |
| **សកម្មភាព ៤.២**<br>ចុះកិច្ចសន្យាជាមួយCBO/FO/NGOសម្រាប់អនុវត្តប្រព័ន្ធផ្តល់ពូជកែលម្អ មិនឲ្យយឺតជាងខែធ្នូ ឆ្នាំ ២០១២ | • ការចរចា និងចាត់ចែងចុះកិច្ចសន្យា | • កិច្ចសន្យាបានចុះហត្ថលេខា<br>• របាយការណ៍គម្រោង | • អ្នកម៉ៅការដែលមានគុណវុឌ្ឍិចាប់អារម្មណ៍ក្នុងការដេញថ្លៃយកកិច្ចសន្យាអនុវត្ត |

| | | | |
|---|---|---|---|
| **សកម្មភាព ៤.៣**<br>ការអនុវត្តប្រព័ន្ធផ្តល់ពូជបន្ត នៅឆ្នាំ ២០១៤ – ភាគច្រើនជាការផ្តល់ និងតម្លើងជុំទីមួយនៃសត្វចិញ្ចឹម - និងកិច្ចព្រមព្រៀងជាមួយកសិករដែលចូលរួមដើម្បីបន្តអនុវត្តប្រព័ន្ធនេះ | • កសិករ ១០០ គ្រួសារបានចុះឈ្មោះនិងទទួលការបណ្តុះបណ្តាល<br>• ក្រុមចំនួន ១០ បានទទួលសត្វសម្រាប់ចិញ្ចឹម | • ការណែនាំ និងតាមដានដោយ CARP<br>• របាយការណ៍គម្រោង | • ចំណាប់អារម្មណ៍របស់កសិករត្រូវបានអះអាង |
| **សកម្មភាព ៤.៤**<br>គាំទ្រកម្មវិធីសម្រាប់បន្តប្រព័ន្ធផ្តល់ពូជសត្វនៅក្នុងភូមិ - ដែលពាក់ព័ន្ធជាមួយ VAHW, ក្រុមប្រឹក្សាឃុំ ការិយាល័យស្រុក និងមន្ទីរខេត្ត នៅក្រោយឆ្នាំ ២០១៤ | • ចំនួន និងប្រភេទនៃការចាត់ចែងនៅមូលដ្ឋានត្រូវបានចាត់ចែង<br>• ការរួមបញ្ចូលទៅក្នុងផែនការអភិវឌ្ឍន៍ឃុំ | • ការតាមដានសកម្មភាពនិងលទ្ធផលគម្រោង<br>• ការវាយតម្លៃឥទ្ធិពលនៅក្រោយបញ្ចប់គម្រោង<br>• ផែនការឃុំ | • ការប្តេជ្ញារបស់ក្រុមប្រឹក្សាឃុំ និងមន្ទីរខេត្ត |
| **សកម្មភាព ៤.៦**<br>តាមដាន និងចងក្រងជាឯកសារនូវឥទ្ធិពល និងបទពិសោធន៍ពីជំហាន i-v. (បន្ត) | • ការតាមដានដោយបុគ្គលិកគម្រោង និងអ្នកពិនិត្យពីស្ថាប័នខាងក្រៅ | • របាយការណ៍អំពីការតាមដាន និងការពិនិត្យ | • ការតាមដានគម្រោងគឺជាផ្នែកមួយនៃការងារគ្រប់គ្រងគម្រោង និងមិនត្រូវចំណាយបន្ថែមឡើយ |

## តារាង ៤៖ ការប៉ាន់ស្មានថ្លៃចំណាយ

| ជំហាន | ការប៉ាន់ស្មានថ្លៃចំណាយ(លំអិត) | ចំនួន ($) |
|---|---|---|
| សកម្មភាព ៤.១ | ថ្លៃទីប្រឹក្សា<br>៣០នាក់ ថ្ងៃ @ $២០០ = ៦.០០០<br>កសុ្កភា និងសម្ភារៈ = ២.០០០<br>បម្រុងយថាភាព= ២.០០០ | ១០.០០០ |
| សកម្មភាព ៤.២ | ថ្លៃទីប្រឹក្សា<br>៣០នាក់ ថ្ងៃ @ $២០០ = ៦.០០០<br>កសុ្កភា និងសម្ភារៈ = ២.០០០<br>បម្រុងយថាភាព= ២.០០០ | ១០.០០០ |
| សកម្មភាព ៤.៣ | ថ្លៃចំណាយ<br>១០ ក្រុម (ក្រុមនីមួយៗសត្វ ១០ក្បាល) x ៥.០០០ = ៥០.០០០<br>កសុ្កភា @ ១០០០ក្នុងមួយក្រុម : ១០.០០០<br>ការផ្តល់ថ្នាំបង្ការ @១០០ក្នុង១ក្រុម?=១.០០០<br>សេវាផ្តល់យោបល់ណែនាំ[25]: ១២.០០០<br>បណ្តុះបណ្តាល៖ ២វគ្គងាយៗ៖២.០០០<br>កសុ្កភានិងចំណាយរដ្ឋបាលសម្រាប់អ្នកម៉ៅការ (៧%)៖ ៥.០០០ | ៨០.០០០ |
| សកម្មភាព ៤.៤ | សរុបសម្រាប់ទុនបង្វិល៖ $១០.០០០ ក្នុងមួយឃុំ | ៧០.០០០ |
| សកម្មភាព ៤.៥ | ការតាមដានគម្រោងជាផ្នែកមួយនៃការងារគ្រប់គ្រងជាធម្មតា ដោយមិនចំណាយបន្ថែម។<br>ការពិនិត្យពីស្ថាប័នខាងក្រៅ៖ ១៥នាក់ ថ្ងៃ @ $២០០ = $ ៣.០០០ + កសុ្កភា។ល។$ ១.០០០ = | ៤.០០០ |
| | បម្រុងយថាភាព | ១.០០០ |
| សរុប | | ១៧៥.០០០ |

[25]ទស្សនកិច្ចផ្តល់ការណែនាំដោយអ្នកជំនាញការនៅមូលដ្ឋាន៖ អប្បបរមា ២លើក ក្នុង ១ ខែ នៅក្នុងឆ្នាំដំបូង @ $ ៥០ ក្នុងមួយក្រុម (២ x ១២ x ៥០ = ១.២០០ ក្នុងមួយក្រុម)

**៥. ការអភិរក្សទឹកក្នុងកសិដ្ឋាន និងវិធីត្រងទឹកភ្លៀង។ នេះជាការឆ្លើយតបទៅនឹងការជ្រាបចូលពីក្រោមដីនៃទឹកប្រៃទៅក្នុងដង្ហើមទឹកក្រោមដី - ដូច្នេះអាចបង្កើនប្រភពទឹកសាបនៅក្រោមដី**

សម្ពាធពីការប្រែប្រួលអាកាសធាតុទៅអនាគតអាចបង្កើនភាពខ្វះខាតទឹកដូចជាបញ្ហាដែលសហគមន៍គោលដៅនានាបានជួបប្រទះរួចមកហើយ ពោលគឺ ភាពខ្វះទឹក។ ការត្រងទឹកភ្លៀងអាចបង្កើនប្រភពទឹក (ដូចជាសម្រាប់ការប្រើប្រាស់ផ្ទាល់ខ្លួន) ឬ បង្កើនការផលិតដំណាំ។

ការត្រងទឹកភ្លៀងនៅតាមមូលដ្ឋាន គឺជាការប្រមូលនិងរក្សាទុកទឹកភ្លៀង តាមរយៈបច្ចេកវិទ្យាខុសៗគ្នា។ នៅក្នុងគំរូដែលលើកស្នើឡើង ពោលគឺ ប្រព័ន្ធត្រងទឹកភ្លៀងនៅក្នុងមូលដ្ឋាន បច្ចេកវិទ្យាត្រងទឹកភ្លៀងរួមមានយុទ្ធសាស្ត្រគ្រប់គ្រងដី និងទឹក ដែលបង្កើនជម្រាបទឹកទឹកភ្លៀងចូលក្នុងដី និងកាត់បន្ថយទឹកហូរលើផ្ទៃដី។ ដូច្នេះ ទឹកភ្លៀងត្រូវបានប្រើប្រាស់ដោយប្រសិទ្ធភាព និងទប់ស្កាត់ការហូរច្រោះដី។ ឧទាហរណ៍ អំពីប្រព័ន្ធបែបនេះ គឺការបង្កើតទីលានរាបស្មើ ការជីកស្រះ និងទម្លាប់ភ្ជួរដីបែបអភិរក្ស។ តាមរយៈការត្រងទឹកភ្លៀងទុកទឹកក្នុងដីត្រូវបានបំពេញមកវិញ ដើម្បីបង្កើនការលូតលាស់ដំណាំបានប្រសើរជាងមុន និងបង្កើនផលិតភាពកសិដ្ឋាន។ ប៉ុន្តែ ទឹកនេះក៏ត្រូវបានប្រើប្រាស់សម្រាប់គោលបំណងផ្សេងទៀតផងដែរ។

សកម្មភាពនេះអាចរាប់បញ្ចូលការជម្រុញឲ្យមានកំណែលម្អការស្រោចស្រព និងប្រសិទ្ធភាពខ្ពស់នៃការប្រើប្រាស់ទឹកក្នុងកសិដ្ឋានផងដែរ ឧទាហរណ៍ ការស្រោចស្រពដោយតំណក់ទឹកនៅក្នុងផលិតកម្មបន្លែ និងផ្លែឈើ។

ព័ត៌មានបន្ថែមពីគម្រោងបន្តពី NAPA ដំបូង រួមមានដូចតទៅៈ

| ការប្រើប្រាស់ទឹកប្រចាំឆ្នាំក្នុងគ្រួសារ | | | |
|---|---|---|---|
| **ការប្រើប្រាស់** | **ទំហំ** | **តម្រូវការទឹក** | **ការប្រើប្រាស់ទឹកសរុប** |
| វាលស្រែ | ១ ហ.ត | ១រដូវ = ១២.០០០ម៣ | ១២.០០០ |
| បន្លែ | ០,២ហ.ត, ៦ខែ/ឆ្នាំ | ៥ម.ម ក្នុងមួយថ្ងៃ | ១.៥០០ |
| ក្នុងគ្រួសារ | ២០ល/ម្នាក់/ថ្ងៃ | ៥នាក់ x ៣៦៥ថ្ងៃ | ៣៦,៥ |
| គោ | ៤០ល/មួយក្បាល/ថ្ងៃ | ២ក្បាល x ៣៦៥ថ្ងៃ | ២៩,២ |
| ជ្រូក | ១០ល/ក្បាល/ថ្ងៃ | ៣ក្បាល x ៣៦៥ថ្ងៃ | ១០,៩៥ |
| មាន់ | ០,៥ល/ក្បាល/ថ្ងៃ | ១០ក្បាល x ៣៦៥ថ្ងៃ | ១,៨២៥ |
| **ការប្រើប្រាស់ទឹកសរុបប្រចាំឆ្នាំ** | | | ១៣.៥៧៨ |

បរិមាណទឹកសរុបដែលគ្រួសារនីមួយៗប្រើប្រាស់គឺត្រឹមតែ៧៥% នៃទឹកភ្លៀងដែលធ្លាក់មកលើផ្ទៃដី។ ប្រសិនបើពួកគេត្រូវការទឹកបន្ថែមទៀត ពួកគេអាចបូមយកពីទន្លេ ឬ ពីអណ្តូង។ គួរកត់សំគាល់ថា ទឹកប្រើប្រាស់សម្រាប់ដំណាំស្រូវមានប្រមាណ ៩០% នៃទឹកប្រើប្រាស់សរុបនៅក្នុងការគណនានេះ។ ក្នុងគ្រួសារភាគច្រើន តម្រូវការទឹកធ្វើស្រែអាចច្រើនជាង៩០% ដោយសារ ០,២ហ.ត ជាទំហំធំណាស់សម្រាប់ច្បារបន្លែ។

**ថ្លៃទឹក**៖ យើងបង់ថ្លៃដោយផ្ទាល់ដើម្បីបានទឹកសម្រាប់ការប្រើប្រាស់ទឹកជាច្រើនបែប។ ឧទាហរណ៍ខ្លះៗគឺ៖

- ថ្លៃទឹកផឹក "ធម្មតា" នៅក្នុងហាងទំនិញមួយ តាមធម្មតាមានប្រមាណ ០,០៥ដុល្លាអាមេរិក សម្រាប់ទឹក ០,៥ល។ ២០ដុល្លាអាមេរិក/ ម៣។
- តាមស្រុកនៅជនបទដែលគ្មានអណ្តូង តាមធម្មតាគេលក់ទឹក ២០០០រៀល (០,៥០ដុល្លាអាមេរិក) សម្រាប់ទឹកមួយធុង ២០០លីត្រ។ ២,៥០ដុល្លាអាមេរិក/ម៣។

ចំពោះសេចក្តីអធិប្បាយអំពីសកម្មភាពដែលអាចមាន គេអាចដាក់បញ្ចូលទៅក្នុងក្របខ័ណ្ឌដូចខាងក្រោម។ **សំណើ៖** សកម្មភាពនេះអាចរួមបញ្ចូលនៅក្នុងកម្មវិធីសិក្សា នូវសកម្មភាព ១។ លើសពីនេះ វាអាចក្លាយជាសកម្មភាពបង្ហាញដោយផ្ទាល់។ នៅត្រូវធ្វើសេចក្តីសម្រេច។

| សេចក្តីអធិប្បាយ | សូចនាករ | ប្រភពនៃការផ្ទៀងផ្ទាត់ | ការសន្មតិ |
|---|---|---|---|
| **សមិទ្ធផល**<br>*ទឹកកាន់តែច្រើន (ដែលមានគុណភាពខ្ពស់) សម្រាប់ការប្រើប្រាស់ក្នុងគ្រួសារ និងកំណើនផលិតផលដំណាំ (បន្លែ)។ ការថយចុះផលប៉ះពាល់នៃកង្វះសំណើមដីមកលើទិន្នផល– កំណើនឱកាសសម្រាប់ដំណាំបន្ថែម នៅរដូវប្រាំង* | • បង្កើនប្រាក់ចំណេញជាមធ្យមប្រចាំថ្ងៃ ២០០ដុល្លាក្នុង ១ហិកតា<br>• បង្កើនផលិតផលបន្លែ បាន ០,១ ហ.ត ក្នុងមួយគ្រួសារ ក្នុងរដូវប្រាំង | • របាយការណ៍ ការពិនិត្យ និងវាយតម្លៃសកម្មភាព | |
| **លទ្ធផល ៥**<br>**វិធីអភិរក្សទឹកក្នុងវាលស្រែ និងការគ្រងទឹកក្នុងកសិដ្ឋាន និងវិធីស្រោចស្រពខ្នាតតូច** | • ការអនុវត្តសកម្មភាពបង្ហាញទាំងនេះ និងការបណ្តុះបណ្តាល | • របាយការណ៍ ការពិនិត្យ និងវាយតម្លៃសកម្មភាព | • សកម្មភាពបង្ហាញនិងបណ្តុះបណ្តាលនឹងបន្ថែមទំនុកចិត្តគ្រប់គ្រាន់ ដល់គ្រួសារកសិករ ដើម្បីទទួលយកអនុសាសន៍ និងឥទ្ធិពលជាប្រាក់ចំណូល |

| | | | |
|---|---|---|---|
| **សកម្មភាព ៥.១**<br>ការវាយតម្លៃបច្ចេកទេសដាំដំណាំ គុណភាពដី/ទឹក សក្តានុពលផលិតដំណាំនៅក្នុងបរិបទនេះ តាមរយៈការវិភាគប្រព័ន្ធក្សេត្របរិស្ថាន (AEA) ដែលជាផ្នែកមួយនៃសកម្មភាព ១ – ដោយមិនចំណាយបន្ថែម | • បច្ចេកទេសត្រងទឹកសមស្រប ការអភិរក្សទឹក និងសកម្មភាពស្រោចស្រពខ្នាតតូច ដូចដែលបានកំណត់ដោយ AEA ក្នុងឃុំចំនួន ៧ ឬ ៨ | • របាយការណ៍ AEA | • មានមន្ត្រីដែលបានកត់សំគាល់ដើម្បីដឹកនាំការវិភាគ AEA<br>• សន្មតថាគ្មានការចំណាយបន្ថែមឡើយ |
| **សកម្មភាព ៥.២**<br>ការអនុវត្តសកម្មភាពបង្ហាញក្នុងកសិដ្ឋានលើការអភិរក្សទឹក ការត្រងទឹក និងការស្រោចស្រពសមស្រប។ ឧទាហរណ៍ការស្រចស្រពដោយតំណក់ទឹកសម្រាប់ដំណាំបន្ទាប់បន្សំ(បន្លែ) នៅរដូវប្រាំង | • បានអនុវត្តការបង្ហាញ និងចងក្រងជាឯកសារអំពី ២០ទីតាំង ក្នុង៧-៨ឃុំ នៅក្នុងឆ្នាំ ២០១៣ | • ការដឹកនាំ និងតាមដានដោយ CARP<br>• របាយការណ៍ពីទីតាំង | • PDA និងស្ថាប័នដទៃទៀតមានសមត្ថភាពអនុវត្តសកម្មភាពបង្ហាញ |

| | | | |
|---|---|---|---|
| **សកម្មភាព ៥.៣**<br>អនុវត្តទិវាសាលាស្រែកសិករ (FFD) ដែលទាក់ទងនឹងទីតាំងបង្ហាញនីមួយៗ – FFD មួយ ក្នុងឃុំនីមួយៗ | • បានរៀបចំទិវាស្រែកសិករ | • របាយការណ៍ទិវាស្រែកសិករ | • កសិករមានចំណាប់អារម្មណ៍ចូលរួម |
| **សកម្មភាព ៥.៤**<br>ការបណ្តុះបណ្តាលកសិករ/គ្រួសារអំពីបច្ចេកទេសត្រងទឹកភ្លៀងនឹងនឹងកន្លែង – អាចទាក់ទងនឹងសកម្មភាព ៤។ អាចរួមបញ្ចូលទស្សនកិច្ចនៅកន្លែងផ្សេងក្នុងប្រទេសកម្ពុជា | • គ្រួសារកសិករចំនួន ២០០ ចុះឈ្មោះ និងបណ្តុះបណ្តាលក្នុង ៣២វគ្គ | • របាយការណ៍គម្រោង | • កសិករមានចំណាប់អារម្មណ៍ចូលរួម |
| **សកម្មភាព ៥.៥**<br>ការតាមដាននិងចងក្រងជាឯកសារអំពីឥទ្ធិពល និងបទពិសោធន៍តាមរយៈជំហានi-iv. (បន្ត) | • ការតាមដានដោយបុគ្គលិកគម្រោង និងដោយអ្នកពិនិត្យពីស្ថាប័នខាងក្រៅ | របាយការតាមដាន និងពិនិត្យ | ថ្លៃចំណាយ៖<br>ការតាមដានគម្រោងជាផ្នែកមួយនៃកិច្ចការគ្រប់គ្រងជាធម្មតា ដោយគ្មានថ្លៃចំណាយបន្ថែម |

**តារាង ៥៖ ការប៉ាន់ស្មានថ្លៃចំណាយ**

| ជំហាន | ការប៉ាន់ស្មានថ្លៃចំណាយ(លំអិត) | ចំនួន ($) |
|---|---|---|
| **សកម្មភាព ៥.១** | ផ្នែកមួយនៃAEA នៅក្រោមសកម្មភាព ១ | 0 |
| **សកម្មភាព ៥.២** | ការអនុវត្តបង្ហាញចំនួន ២០ @ $ ១២០០ | ៤០.០០០ |
| **សកម្មភាព ៥.៣** | ទិវាស្រែកសិករ ៧-៨លើក | ៣.៥០០ |
| **សកម្មភាព ៥.៤** | ការបណ្តុះបណ្តាលកសិករ ២០០នាក់ (៣២វគ្គ) | ៥.០០០ |
| | បម្រុងយថាភាព | ១.៥០០ |
| **សរុប** | | ៥០.០០០ |

**១. គម្រោងសហគមន៍ព្រៃឈើ ក្រោមកិច្ចសហការជាមួយរដ្ឋបាលព្រៃឈើ ដែលមានលទ្ធភាពអនុវត្តនៅទួលគរគី។ អាចរួមបញ្ចូល សិទ្ធិលែងសត្វឲ្យស៊ីស្មៅនៅក្នុងតំបន់ព្រៃឈើ។**

បច្ចុប្បន្ននេះ យើងពុំមានព័ត៌មានគ្រប់គ្រាន់អំពីលទ្ធភាពអនុវត្តសកម្មភាពនេះទេ។ ទោះជាយ៉ាងណាក៏ដោយ ការពិគ្រោះយោបល់ជាមួយខ័ណ្ឌរដ្ឋបាលព្រៃឈើខេត្តកោះកុងបានបង្ហាញថា គម្រោងសហគមន៍ព្រៃឈើមួយត្រូវបានបង្កើតឡើងក្នុងពេលថ្មីៗនេះ នៅឃុំទួលគរគី (ឥឡូវនេះខ្វះថវិកា) និងសកម្មភាពពាក់ព័ន្ធមួយផ្សេងទៀត អាចជាថ្នាលបណ្តុះកូនឈើមួយ ឬច្រើន សម្រាប់ឃុំគោលដៅ និងអាចឃុំដទៃទៀតផងដែរ។ ប្រភេទឈើ ដែលផ្តល់ជាអុសអាចសមស្របសម្រាប់ជម្រុញនៅក្នុងបរិបទនេះ។ សកម្មភាពនេះផ្សារភ្ជាប់ជិតស្និទ្ធិជាមួយរបៀបវារៈប្រែប្រួលអាកាសធាតុ តាមរយៈសក្តានុពលរបស់វាសម្រាប់ជម្រុញប្រភេទឈើសមស្របសម្រាប់សាងសង់ទីជម្រក ផ្តល់ជាអាហារ និងឥន្ទនៈ។

ដូច្នេះ សំណើសកម្មភាពបង្ហាញនេះមិនអាចចែងពិស្តារបន្ថែម និងកំណត់ថ្លៃចំណាយបានឡើយ និងមិនអាចវាយតម្លៃសេដ្ឋកិច្ចបានដែរទេនៅក្នុងដំណាក់កាលនេះ។

**<u>សំណើ</u>៖** ការពិគ្រោះយោបល់បន្ថែមនៅខែមករា ឆ្នាំ២០១៣ លើចំណុចនេះជាមួយរដ្ឋបាលព្រៃឈើ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (MAFF) ខណ្ឌរដ្ឋបាលព្រៃឈើកោះកុង និងក្រុមប្រឹក្សាឃុំ ទួលគរគី។

**២. ការពង្រឹងការងារថែទាំទំនប់សហគមន៍ ការគ្រប់គ្រងប្រព័ន្ធដោះទឹក និងប្រព័ន្ធស្រោចស្រព ក្រោមកិច្ចសហប្រតិបត្តិការជាមួយក្រសួងធនធានទឹក និងឧតុនិយម MoWRAM – សម្រាប់ព្រៃនប់ និងទួលគរគី។**

ក្រុមប្រឹក្សាសហគមន៍ផ្ទាល់បានលើកស្នើកិច្ចការភាគច្រើនដែលមានខាងក្រោម រួមទាំងយោបល់ពីរបាយការណ៍ CARP ដែលបានកត់សំគាល់ផងដែរ៖

១. សាងសង់ និងស្តារទំនប់ការពារទឹកប្រៃ
២. សាងសង់ទំនប់ការពារដីភូមិ
៣. ជួសជុលទ្វារទឹក
៤. ជួសជុល (ធ្វើឲ្យជ្រៅ) ហេដ្ឋារចនាសម្ព័ន្ធផ្សេងទៀត (ផ្លូវថ្នល់ ប្រឡាយ លូដោះទឹក អាងទឹក)
៥. បង្កើតផែនការគ្រប់គ្រងទឹកសមស្រប
៦. សាងសង់សន្ទះទឹកសម្រាប់ដំណាំកសិកម្ម និងការចិញ្ចឹមសត្វ
៧. ការអង្កេតគុណភាពដីសម្រាប់កសិកម្ម
៨. ជីកស្រះសម្រាប់ធ្វើវារីវប្បកម្ម
៩. រួមបញ្ចូលផែនការសកម្មភាពទាំងនេះទៅក្នុងកម្មវិធីវិនិយោគរបស់រដ្ឋាភិបាល/ឃុំ
១០. ការគាំទ្រដល់ការងារគ្រប់គ្រង ដែលរួមទាំង តាមដានជាលក្ខណៈប្រព័ន្ធនូវកម្រិតប្រៃ និងការស្រុតដី

**សំណើ៖** បង្កើត និងកំណត់ថ្លៃចំណាយសម្រាប់ផែនការសកម្មភាពអនុវត្តបង្ហាញសម្រាប់ព្រៃនប់ និងទួលគរគី ដូចមានចែងខាងលើ ដោយសហការជាមួយ គណៈកម្មការគ្រប់គ្រងប៉ូលឌែរ ក្រុមប្រឹក្សាឃុំ សមាជិកឃុំ អាជ្ញាធរស្រុក និងមន្ទីរធនធានទឹក។

ផែនការនេះគួរតែរាប់បញ្ចូលវិភាគទានជាច្រើនខាងហិរញ្ញវត្ថុ និងមិនមែនសាច់ប្រាក់ ពីសហគមន៍មូលដ្ឋាន ដែលពាក់ព័ន្ធ និងក្លាយជាផ្នែកមួយនៃផែនការវិនិយោគឃុំ និងផែនការប្រតិបត្តិប្រចាំឆ្នាំ។

នៅពេលនេះ យើងពុំមានព័ត៌មានគ្រប់គ្រាន់ដើម្បីកសាងផែនការ និងកំណត់ថ្លៃចំណាយសម្រាប់សកម្មភាពនេះឡើយ។ ការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធនានាកំពុងតែអនុវត្តបន្ត។

**តារាង ៦. សង្ខេបថ្លៃប៉ាន់ស្មានសម្រាប់សកម្មភាពបង្ហាញនៅក្រោម CARP**

| ជំហាន | ការប៉ាន់ស្មានថ្លៃចំណាយ(លំអិត) | ចំនួន ($) |
|---|---|---|
| **សកម្មភាព ១** | កម្មវិធីបណ្តុះបណ្តាលកសិករអំពីការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ និងការដាំដំណាំចម្រុះក្នុង៧ឃុំ | ២២៥.០០០ |
| **សកម្មភាព ២** | កម្មវិធីសហគមន៍នេសាទសម្រាប់ពាមក្រសោបក្នុងខេត្តកោះកុង | ៨០.០០០ |
| **សកម្មភាព ៣** | ការសាកល្បងពូជនានានៅតាមកសិដ្ឋាន ការអនុវត្តបង្ហាញ និងការបណ្តុះបណ្តាលលើការជ្រើសរើសពូជក្នុង ៧ ឃុំ | ៣២.០០០ |
| **សកម្មភាព ៤** | ប្រព័ន្ធចិញ្ចឹមសត្វបន្តគ្នានៅក្នុង៧ឃុំ | ១៧៥.០០០ |
| **សកម្មភាព ៥** | ការអនុវត្តបង្ហាញតាមកសិដ្ឋានអំពីការអភិរក្សទឹក ការគ្រងទឹក និងប្រព័ន្ធស្រោចស្រពខ្នាតតូច | ៥០.០០០ |
| **សរុប** | | ៥៦២.០០០ |

តួលេខនេះបង្ហាញពីថវិកាបម្រុងទុក១៣៨.០០០ដុល្លា សម្រាប់ការគាំទ្រដោយផ្ទាល់ដល់វិធានការនានាដែលទាក់ទងនឹងហេដ្ឋារចនាសម្ព័ន្ធ ដែលរួមបញ្ចូលនៅក្នុងផែនការវិនិយោគឃុំ និងសម្រាប់សកម្មភាពនានាដែលទាក់ទងនឹងការបង្កើនការយល់ដឹងអំពីការប្រែប្រួលអាកាសធាតុ និងប្រព័ន្ធជាវសាស្ត្រដែលអន់នឹងការប្រែប្រួលអាកាសធាតុ ប្រសិនបើសកម្មភាពអនុវត្តបង្ហាញទាំងអស់ខាងលើត្រូវដាក់ឲ្យអនុវត្តទាំងស្រុង។

# ៤. ការវិភាគថ្លៃចំណាយ និងផលចំណេញ

## សេចក្តីផ្តើម

ការគណនាទាំងនេះប្រើប្រាស់ម៉ូដែលដូចមានអធិប្បាយក្នុងផែនការសកម្មភាព២.៦ - ឯកសារភ្ជាប់២ ពោលគឺ ការងារអំពីភាពខុសគ្នាដែលរំពឹងទុក រវាងពីមុន និងក្រោយសកម្មភាពបង្ហាញដែលពាក់ព័ន្ធ។

ដើម្បីប្រើប្រាស់វិធីសាស្ត្រនេះ ជាចាំបាច់ត្រូវបង្កើត និងគណនាជាជំហានទី ១៖

(១) ថវិកាដុលមធ្យមសម្រាប់ប្រភេទដំណាំចំបងៗក្នុងប្រភេទនីមួយៗ សត្វចិញ្ចឹម និងសកម្មភាពនេសាទ នៅក្នុងពេលបច្ចុប្បន្ន សម្រាប់គ្រួសារទូទៅ និង

(២) ដូចគ្នានេះដែរសម្រាប់ការកែលម្អដែលរំពឹងទុក ដែលបានពីសកម្មភាពពាក់ព័ន្ធ។

ឯកសារទាំងនេះត្រូវមានពិស្តារតាមការចាំបាច់ អំពីអ្វីដែលជាការរំពឹងទុកជាក់លាក់ និងតើបានមកដោយវិធីណា។ ថវិកាដំណាំ មានក្នុងឧបសម្ព័ន្ធ ២។ ប៉ុន្តែសម្រាប់សត្វចិញ្ចឹម និងជលផល ត្រូវអនុវត្តនីតិវិធីមួយផ្សេង ដោយសារតែទិន្នន័យដែលមានក្នុងកម្រិតកំណត់។

ជំហានទី២គឺការពង្រីកការរំពឹងទុកខាងលើសម្រាប់គ្រួសារមធ្យមណាមួយនៅកម្រិតគម្រោងCARP។ ការធ្វើបែបនេះផ្តល់ជាមូលដ្ឋានសម្រាប់ការគណនាតម្លៃបច្ចុប្បន្នសុទ្ធ (NPV) និងអត្រាផលចំណូលផ្ទៃក្នុង (IRR)[26]។ ទាំងនេះគឺជាឧបករណ៍បឋមសម្រាប់វាយតម្លៃឱកាសវិនិយោគ និងសម្រាប់ជ្រើសយករវាងការវិនិយោគផ្សេងៗ - ខាងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ សេចក្តីពិស្តារនៃការគណនានេះមានក្នុងឧបសម្ព័ន្ធ ៣។

## ៤.១ ការវិភាគសេដ្ឋកិច្ចសម្រាប់សកម្មភាព ១ និង ៣

សកម្មភាពបង្ហាញទាំងពីរត្រូវបានរួមបញ្ចូលគ្នា ដោយសារវាគាំទ្រគ្នាទៅវិញទៅមក ហើយការញែកពីគ្នារវាងឥទ្ធិពលនៃសកម្មភាពទាំងពីរ គឺជាការលំបាក។

### ៤.១.១ ឥទ្ធិពលខាងសេដ្ឋកិច្ចក្នុងគ្រួសារ/ឆ្នាំ (ស្រូវ)

**សំគាល់៖** ការគណនានេះពិនិត្យមើលភាពខុសគ្នារវាងទម្លាប់ខុសគ្នាក្នុងកសិកម្ម("ចាស់"និង"ថ្មី")។ សូមយោងទៅថវិកាដាច់គ្នាសម្រាប់ដំណាំតាមវិធី "ចាស់"និង"ថ្មី" ក្នុងឧបសម្ព័ន្ធ ២។ ការគណនាដំបូងសម្រាប់គ្រួសារនីមួយៗ ត្រូវបានធ្វើឡើងជាពីរឈុត សម្រាប់ព្រៃនប់ខាងកើតនិងខាងលិច[27] ដោយសារតែភាពខុសគ្នាជាខ្លាំងនៃទិន្នផលស្រូវ និងការប្រើប្រាស់ពលកម្ម និងសេវាពីខាងក្រៅ។

[26]អត្រាចំណូលផ្ទៃក្នុង (IRR) គឺជាអត្រាដែលធ្វើឲ្យ NPV ស្មើសូន្យ ប្រសិនបើប្រើក្នុងរូបមន្ត NPV

[27]ព្រៃនប់ខាងកើតមាន ៣ឃុំគឺ ទឹកថ្លា ទឹកល្អក់ និងសាមគ្គី ហើយព្រៃនប់ខាងលិច មាន៣ឃុំគឺ ព្រៃនប់ ទួលទទឹងនិងអូរឧកញ៉ាហេង នៃស្រុកព្រៃនប់

**តារាង ៤.១៖ ឥទ្ធិពលខាងសេដ្ឋកិច្ចមកលើគ្រួសារ/ឆ្នាំ (ស្រូវ)**

**<u>ព្រៃនប់(ខាងកើត)</u>[28]**

**<u>សំគាល់</u>៖** ការគណនានេះ ពិនិត្យមើលភាពខុសគ្នារវាងទម្លាប់ខុសៗគ្នាក្នុងកសិកម្ម ("ចាស់"និង"ថ្មី") តែមិនមែនថ្លៃចំណាយ និងផលចំណេញសរុបឡើយ (សូមយោងទៅថវិកាដាច់គ្នាសម្រាប់ដំណាំតាមបែប˝ចាស់˝ និង ˝ថ្មី˝ ក្នុងឧបសម្ព័ន្ធ ២)។

| **ឥទ្ធិពលលើគ្រួសារនីមួយៗសម្រាប់ម្ចាស់ស្រែជាមធ្យម ដែលបានពីការចូលរួមក្នុងសាលាស្រែកសិករ (FFS)** | ឯកត្តា (គ.ក) | $ /ឯកត្តា | តម្លៃ | សរុប$ |
|---|---|---|---|---|
| **ផលចំណេញ/ទំហំស្រែជាមធ្យម**[29] | | | | |
| ១. កំណើនទិន្នផលស្រូវ | ៩០៤ | ០,២៣៥ | ២១៦ | |
| ២. កំណើនតម្លៃជញ្ជាំងស្រូវ | | | ១១ | ២២៧ |
| **<u>ថ្លៃចំណាយ</u>** | | | | |
| ៣. កំណើនថ្លៃអថេរ/គ្រួសារ | | | -៧០ | |
| ៤. កំណើនថ្លៃចំណាយលើឧបករណ៍រយៈពេលវែង (ដូចជា បរិក្ខារ ជួល ការប្រាក់។ល។) | | | -១៥ | |
| ៥. ថ្លៃឱកាស (ចំណូលប្រចាំឆ្នាំដែលបាត់បង់ បើមាន) | | | <u>០</u> | -៨៥ |
| **កំណើនសុទ្ធក្នុងគ្រួសារនីមួយៗ** | | | | ១៤២ |

ភាពខុសគ្នាជាចំបងរវាង ˝មុននិងក្រោយគម្រោង˝ កើតឡើងដោយសារការប្រើប្រាស់ពូជកែលម្អ ជីច្រើនជាងមុន ៤០% និងជួលកម្លាំងពលកម្ម ២០ថ្ងៃច្រើនជាង។ កំណើនការប្រើប្រាស់ជីត្រូវបានគិតបញ្ចូលដើម្បីអនុវត្តវិធានការអេតិរក្ស ប៉ុន្តែ វាអាចមិនចាំបាច់។ ជារួម ឥទ្ធិពលចំបងនឹងបង្កើតបានតាមរយៈកំណែលម្អការថែទាំដំណាំ និងការគ្រប់គ្រងជារួម ដែលអាចកាត់បន្ថយកម្រិតប្រើប្រាស់ជីដែលបានស្នើឡើង។

[28]ព្រៃនប់ខាងកើត មាន៣ ឃុំ គឺ ឃុំទឹកថ្លា ទឹកល្អក់ និងសាមគ្គី

[29]ទំហំស្រែជាមធ្យមនៅព្រៃនប់ខាងកើតគឺ ០,៨ ហ.ត (ស្រែវស្សាតែប៉ុណ្ណោះ)

## ព្រៃនប់(ខាងលិច)[30]

**សំគាល់៖** ការគណនានេះ ពិនិត្យមើលភាពខុសគ្នារវាងទម្លាប់ខុសគ្នាក្នុងកសិកម្ម ("ចាស់" និង"ថ្មី") តែមិនមែនថ្លៃចំណាយ និងផលចំណេញសរុបឡើយ (សូមយោងទៅ ថវិកាដាច់គ្នាសម្រាប់ដំណាំតាមបែប"ចាស់" និង"ថ្មី" ក្នុងឧបសម្ព័ន្ធ ២)។

| **ឥទ្ធិពលលើគ្រួសារនីមួយៗសម្រាប់ម្ចាស់ស្រែជាមធ្យម ដែលបានពីការចូលរួមក្នុងសាលាស្រែកសិករ (FFS)** | ឯកត្តា (គ.ក) | $/ឯកត្តា | តម្លៃ | សរុប$ |
|---|---|---|---|---|
| **ផលចំណេញ/ទំហំស្រែជាមធ្យម**[31]. | | | | |
| ១. កំណើនទិន្នផលស្រូវ៖ ៦០០គ.កx១.៥ហ.ត | ៩០០ | ០,២៣៤ | ២០៩ | |
| ២. កំណើនតម្លៃជញ្ជាំងស្រូវ | | | ១២ | ២២១ |
| **ថ្លៃចំណាយ** | | | | |
| ៣. កំណើនថ្លៃអថេរ/គ្រួសារ | | | - ១១ | |
| ៤. កំណើនថ្លៃចំណាយលើឧបករណ៍រយៈពេលវែង (ដូចជា បរិក្ខារ ជួល ការប្រាក់។ល។) | | | - ១៥ | |
| ៥. ថ្លៃឱកាស (ចំណូលប្រចាំឆ្នាំដែលបាត់បង់ បើមាន) | | | 0 | - ២៦ |
| **កំណើនសុទ្ធក្នុងគ្រួសារនីមួយៗដែលមានដីស្រែមធ្យម ១,៥ហិកតា** | | | | **១៩៥** |

ភាពខុសគ្នាជាចំបងរវាង "មុន និង ក្រោយគម្រោងកើតឡើងដោយសារការប្រើប្រាស់ពូជល្អជាងមុនដាក់ជី ១០%ច្រើនជាង និងកាត់បន្ថយការប្រើប្រាស់ថ្នាំកំចាត់កត្តាចង្រៃ។ កំណើនការប្រើប្រាស់ជីត្រូវបានគិតបញ្ចូល ដើម្បីអនុវត្តវិធានអភិរក្ស ប៉ុន្តែ វាអាចមិនចាំបាច់។ ជារួម ឥទ្ធិពលចំបងនឹងបង្កើតបានតាមរយៈកំណែលម្អការថែទាំដំណាំ និងការគ្រប់គ្រងជារួម ដែលអាចកាត់បន្ថយកម្រិតប្រើប្រាស់ជីដែលបានស្នើឡើង ក៏ដូចជាកាត់បន្ថយថ្លៃជួលពលកម្ម និងសេវាផងដែរ។

[30]ព្រៃនប់ខាងលិច មាន "ឃុំថ្មី" ចំនួន៣ គឺ ព្រៃនប់ ទទួលទទឹង និងអូរឧកញ៉ាហេង នៃស្រុកព្រៃនប់

[31]ទំហំស្រែជាមធ្យមក្នុងគ្រួសារនីមួយៗ សម្រាប់ព្រៃនប់ខាងលិច (នៅក្នុងប៉ូលឌែរផ្ទាល់) គឺ ១,៥ហ.ត

*ការប្រៀបធៀបជាមួយការវាយតម្លៃផ្សេងទៀតអំពីឥទ្ធិពលនៃសាលាស្រែកសិករ៖* គោលគំនិត FFS ត្រូវបានអនុវត្តក្នុងគម្រោងខុសៗគ្នាជាច្រើននៅកម្ពុជា អស់រយៈពេលជាងមួយទសវត្សរ៍មកហើយ។ ចំពោះកំណើនទិន្នផលស្រូវ ជាទូទៅលទ្ធផលនៃការវាយតម្លៃមានភាពខុសគ្នាពីប្រមាណ ៧៥០គ.ក/ហ.ត ដល់ប្រមាណ ១ ៤០០គ.ក (ចងក្រងក្នុងឧបសម្ព័ន្ធ២) ប៉ុន្តែក៏មានលទ្ធផលនៅក្រៅបេត់នេះផងដែរគឺកើនរហូតដល់ ៣ ៥០០គ.ក ក្នុងមួយហិកតា។[32]

ដោយហេតុថា សកម្មភាពអនុវត្តបង្ហាញសាលាស្រែកសិករបច្ចុប្បន្ននេះបានទទួលការគាំទ្របន្ថែមតាមរយៈការប្រើប្រាស់ពូជស្រូវខុសៗគ្នា ការវាយតម្លៃបង្ហាញថាទំនងជាមានកំណើនទិន្នផលដូចរំពឹងទុក។

### ៤.១.២ ឥទ្ធិពលខាងសេដ្ឋកិច្ចប្រចាំគ្រួសារ/ឆ្នាំ (បន្លែ)

បន្ថែមលើស្រូវ គ្រួសារនានានៅព្រៃនប់ដាំបន្លែលើផ្ទៃដីជាមធ្យម ០,១ហ.ត ក៏ដូចជាដំណាំបន្ទាប់បន្សំផងដែរ។ មានការសន្មតិជាបន្ថែមថា កំណើនសុទ្ធនៃការដាំបន្លែទាំងនេះក្នុងមួយគ្រួសារយ៉ាងហោចណាស់ស្មើនឹងតួលេខសម្រាប់ស្រូវខាងលើដែរ។ (កំណើនសុទ្ធសម្រាប់បន្លែ ទំនងជាមានកម្រិតខ្ពស់ជាង។ ប៉ុន្តែ ដើម្បីជៀសវាងសុទិដ្ឋិនិយមខ្លាំងពេក មានការសន្មតិយកតួលេខ(ទាប)នៃស្រូវសម្រាប់ការគណនានេះ)។

សម្រាប់ឃុំទួលគរគី ខេត្តកោះកុង ជាមធ្យមគ្រួសារនីមួយៗធ្វើស្រែ និងដាំបន្លែលើដីទំហំ ០,៥ហ.ត រួមនឹងដំណាំបន្ទាប់បន្សំផងដែរ។ ទោះជាយ៉ាងណាក៏ដោយ ការពិចារណាដូចគ្នានេះ(ដូចសម្រាប់ព្រៃនប់ដែរ) ក៏យកមកអនុវត្តសម្រាប់ព្រៃនប់ផងដែរ ពោលគឺ សន្មតិអំពីកំណើនសុទ្ធប្រហែលគ្នានៃស្រូវនិងបន្លែ១ហិកតា។

### ៤.១.៣ ឥទ្ធិពលខាងសេដ្ឋកិច្ចប្រចាំគ្រួសារ/ឆ្នាំ (ការចិញ្ចឹមសត្វ និងជលផល)

ឥទ្ធិពលពីការអនុវត្តបង្ហាញសកម្មភាពដាំដំណាំចម្រុះមកលើការចិញ្ចឹមសត្វ និងនេសាទ ត្រូវបានគណនា ជាសមាមាត្រនៃប្រាក់ចំណូលសរុប ដែលទាក់ទងជាមួយសត្វចិញ្ចឹម និងនេសាទនៅក្នុងឃុំគោលដៅ។ ដូច្នេះ មានការសន្មតិថា សមាមាត្រ"ក្រោយគម្រោង" ដែលទាក់ទងនឹងការចិញ្ចឹមសត្វ និងជលផល នៅតែដូច"មុនគម្រោង"ផងដែរ។

នៅទីនេះ មានការទទួលស្គាល់អំពីតម្រូវការឲ្យមានវិធីគណនាដោយប្រយោល ដោយសារពុំមានទិន្នន័យនិងព័ត៌មាន ដើម្បីគណនាឲ្យបានសមស្របនូវឱកាសសម្រាប់ការចិញ្ចឹមសត្វ និងជលផល សម្រាប់គ្រួសារជាមធ្យមនៅក្នុងឃុំគោលដៅ។

ស្ថានភាពបច្ចុប្បន្ននៃមធ្យោបាយផលិតកម្មសត្វ និងជលផល ក្នុងឃុំគោលដៅខុសៗគ្នា ក៏ដូចជាឱកាសសម្រាប់ការចិញ្ចឹមសត្វ និងជលផល មានបង្ហាញជូនក្នុងឧបសម្ព័ន្ធ ២។

---

[32]សម្រាប់ការប្រៀបធៀប។ តារាង ៤.១ ខាងលើ ចេញជា ១.១៣០គ.ក/ហ.ត។

## ៥.១៤ ឥទ្ធិពលខាងសេដ្ឋកិច្ចនៃគម្រោង/ឆ្នាំ

ដោយរួមបញ្ចូលឥទ្ធិពលសម្រាប់គ្រួសារនីមួយៗ ឥទ្ធិពលជារួមបានពីសកម្មភាពអនុវត្តបង្ហាញដំណាំចម្រុះ (សកម្មភាព ១ និង ៣) មានបង្ហាញក្នុងតារាង ៤.១៖

**តារាង ៤.២៖ ឥទ្ធិពលសេដ្ឋកិច្ចនៅកម្រិតគម្រោង/ឆ្នាំ**

| ឥទ្ធិពលសេដ្ឋកិច្ចនៃគម្រោង សម្រាប់កសិករ១២០០នាក់ដែលចូលរួមក្នុង FFS | $ /គ្រួសារ | ចំនួនគ្រួសារ | តម្លៃ (១.០០០) | សរុប (១.០០០)$ |
|---|---|---|---|---|
| **ផលចំណេញដុល** | | | | |
| ១. កំណើនសុទ្ធប្រចាំឆ្នាំ | (២៣៦) | | | |
| គ្រួសារផលិតស្រូវនៅព្រៃនប់ខាងកើត[33] | ១៤២ | ៧០០ | ៩៩ | |
| គ្រួសារផលិតស្រូវនៅព្រៃនប់ខាងលិច | ១៩៥ | ៥០០ | ៤៣ | |
| គ្រួសារដាំបន្លែ[34] | ៣៦ | ១២០០ | ៤៣ | |
| គ្រួសារចិញ្ចឹមសត្វ និងនេសាទ[35] | ៣៦ | ១២០០ | | ២៨២ |
| **ការកែតម្រូវ** | | | | |
| ២. អត្រានៃការទទួលយក (៧៥%) | | | | -៧១ |
| ៣. មេគុណនៃការសាយភាយ (១0%) | | | | +២១ |
| ឥទ្ធិពលបណ្តោះអាសន្នជាប្រាក់ចំណូល | | | | ២៣៣ |
| កត្តាមេគុណប្រាក់ចំណូល[36] (ស្តង់ដារ) | ១,២ | | | ៤៧ |
| **ឥទ្ធិពលសរុបជាប្រាក់ចំណូល** | | | | **២៨០** |

ឥទ្ធិពលខាងសេដ្ឋកិច្ចប្រចាំឆ្នាំនៅឃុំគោលដៅចំនួន ៧ សម្រាប់សកម្មភាពបង្ហាញ ១ និង ៣ ត្រូវបានរំពឹងថាមាន ២៨0.000ដុល្លាក្នុងមួយឆ្នាំ។ តួលេខនេះត្រូវបានគណនាសម្រាប់ ១៥ឆ្នាំដូចខាងក្រោម។

---

[33]ការគណនានេះគិតបញ្ចូលការពិចារណាអំពីឃុំគោលដៅចំនួនពីរនៅកោះកុង

[34]គ្រួសារនីមួយៗមាន ០,១ហិកតា និង/ឬ ដំណាំបន្ទាប់បន្សំ

[35]ត្រូវបានវាយតម្លៃជាកំណើនផលដំណាំ ១៥%។ តួលេខនេះបានផ្អែកលើសមាមាត្រនៃសត្វចិញ្ចឹម និងប្រាក់ចំណូលពីត្រីនៅក្នុងប្រាក់ចំណូលសរុបនៅព្រៃនប់។ សម្រាប់ការវាយតម្លៃបន្ត។

[36]មេគុណប្រាក់ចំណូលសម្រាប់កម្ពុជា (សម្រាប់វិស័យទាំងអស់) គឺ ១,០៨។ប៉ុន្តែមេគុណសម្រាប់កសិកម្មត្រូវបានវាយតម្លៃឃើញថាមានខ្ពស់ជាងនេះ។

## តារាង ៤.៣ និទស្សន៍ឥទ្ធិពលសេដ្ឋកិច្ចនៃគម្រោង

| រង្វាស់ | តម្លៃ |
|---|---|
| ១. ឥទ្ធិពលជាប្រាក់ចំណូលសរុបនៃគម្រោង (១៥ឆ្នាំ) | $១,៩– ២,៦លាន[37] |
| ២. ផាត់ចេញថ្លៃចំណាយលើគម្រោង(តាមការគ្រោងទុកសម្រាប់ឆ្នាំ ២០១៣-១៤) | $ ២៥៧.០០០ |
| ៣. តម្លៃបច្ចុប្បន្នសុទ្ធ (១-២) | $ ១,៧ – ២,២លាន |
| ៤. អត្រាចំណូលផ្ទៃក្នុង | ១៩៣ % |

ផលចំណូលទាំងនេះមានកម្រិតខ្ពស់ បើទោះជាគិតតាមស្តង់ដារណាក៏ដោយ ប៉ុន្តែប្រការនេះមិនចម្លែកទេ សម្រាប់គម្រោង FFS។ ការវិនិយោគនេះពិតជាផ្តល់ផលខ្ពស់។ ទោះជាយ៉ាងណាក៏ដោយគួរកត់សំគាល់ថា តួលេខនៃការវិនិយោគដែលបានរួមបញ្ចូល ($២៥៧.០០០) គឺសម្រាប់តែសកម្មភាពបង្ហាញដែលពាក់ព័ន្ធប៉ុណ្ណោះ ពោលគឺដែលពាក់ព័ន្ធសម្រាប់ការវាយតម្លៃនេះ។ ថ្លៃចំណាយរួមសម្រាប់គម្រោង ឬសមាសភាគចំណាយរដ្ឋបាល សម្រាប់ការកសាងផែនការ ការគ្រប់គ្រង និងរដ្ឋបាលសម្រាប់CARPមិនបានគិតបញ្ចូលឡើយ។ សមាសភាគទាំងនោះមិនពាក់ព័ន្ធទេសម្រាប់ការគណនានេះ ដោយសារដំណាក់កាលនេះ ការសម្រេចគឺអំពីសកម្មភាពបង្ហាញដែលត្រូវអនុវត្ត។

ការរួមផ្សំគ្នារវាងសកម្មភាព ១ និង ៣ ទំនងជាមានភាពទាក់ទាញបំផុតដែលផ្តល់ចំណូលសេដ្ឋកិច្ច។

### ការវិភាគភាពងាយប្រែប្រួល

ការវិភាគនេះ មានគោលបំណងគណនាឥទ្ធិពលនៃការប្រែប្រួលដែលអាចកើតមានចំពោះអថេរនានា និងឥទ្ធិពលមកលើ IRR នៃករណីគោល។ ការវិភាគភាពងាយប្រែប្រួលនេះផ្តោតលើអថេរដែលអាចគណនាបានចំនួន ៣ ដែលមានឥទ្ធិពលមកលើ IRR (និងជោគជ័យ)នៃសកម្មភាពនេះ។ អថេរគន្លឹះដែលបានកំណត់ឃើញគឺប្រាក់ចំណូលក្នុងគ្រួសារនីមួយៗ អត្រានៃការទទួលយក និងការសាយភាយ។ តារាង ៤ ខាងក្រោម បង្ហាញពីឥទ្ធិលដែលអាចកើតមានមកលើអត្រាចំណូលផ្ទៃក្នុង បណ្តាលពីការថយចុះនៃអថេរទាំងនេះ ដូចតទៅៈ

[37]រូបខាងក្រោមគឺសម្រាប់ NPV(១០%);ចំណែករូបខាងលើ គឺសម្រាប់ NPV(៥%)។ អត្រាទាំងពី (៥-១០%) បង្ហាញពីរបាយនៃអប្បហារលើការប្រាក់។ បច្ចុប្បន្ននេះ អត្រាជិត ៥% ក្នុងមួយឆ្នាំ ប្រហែលជាមានភាពស្របគ្នាបំផុតជាមួយអត្រាការប្រាក់អន្តរជាតិ។

**តារាង ៤.៤ ការវិភាគភាពងាយប្រែប្រួលសម្រាប់សកម្មភាពបង្ហាញ ១ និង ៣**

| **បរិយាយ/អថេរ** | **ការប្រែប្រួល** | **IRR** |
|---|---|---|
| ករណីគោល | មិនពាក់ព័ន្ធ | ១៩៣% |
| ប្រាក់ចំណូល/គ្រួសារ ($) | -$១៧២ | ២០% |
| អត្រាទទួលយក | -0,៥៩ | ២០% |
| ការសាយភាយ | -0,៨៩ | ២០% |

នេះមានន័យថា កំណើនប្រាក់ចំណូលប្រចាំគ្រួសារអាចកាត់បន្ថយ$១៧២ និងនៅតែអាចរក្សាបាន យ៉ាងងាយក្នុងអត្រាចំណូលផ្ទៃក្នុង ២០%។ ទោះជាយ៉ាងណាក៏ដោយ កំណើនប្រាក់ចំណូលមិនទំនងជាអាចថយចុះបែបនេះទេ ដូច្នេះការគណនានេះមានការគិតគូរម៉ត់ចត់លើការប្រែប្រួលបែបនេះ។

ចំពោះអត្រានៃការទទួលយក ការគណនានេះក៏អាចកាត់បន្ថយ ៥៩%ផងដែរ (មកត្រឹមអត្រានៃការទទួលយក ១៦%) ហើយនៅតែអាចរក្សាអត្រា IRR បាន ២០%។ ដូចគ្នានេះដែរ សេណារីយ៉ូនៃការគណនានេះមានស្ថានភាពល្អ។ គេអាចនិយាយបានដូចគ្នាសម្រាប់ការសាយភាយសកម្មភាពបង្ហាញនេះ។ ការសាយភាយអាចកាត់បន្ថយមកត្រឹមសូន្យ និងនៅតែអាចផ្តល់ផលចំណូលបានច្រើន។

នៅក្នុងសេណារីយ៉ូនានាដែលបង្ហាញក្នុងតារាងទី ៤.៤ ផលចំណូលនៅតែមានកម្រិតខ្ពស់ បើទោះជាមានការប្រែប្រួលយ៉ាងច្រើននៃអថេរខាងលើក៏ដោយ។ ដូច្នេះ សកម្មភាពបង្ហាញនេះមិនបង្ហាញពីភាពងាយប្រែប្រួលកម្រិតខ្ពស់ឡើយ ធៀបនឹងអថេរខាងលើ។ តាមពិត សកម្មភាពបង្ហាញ ១ និង ៣ បង្ហាញពីភាពរឹងមាំក្នុងវិសាលភាពធំ ដោយផ្អែកលើ IRR ត្រឹម ២០%។

## ការសន្និដ្ឋាន

សកម្មភាពបង្ហាញ ១ និង ៣ ផ្តល់ផលចំណេញកម្រិតខ្ពស់ បើគិតពីកត្តាសេដ្ឋកិច្ច សម្រាប់ទាំងគម្រោង និងគ្រួសារដែលចូលរួម។ ការគណនាបង្ហាញពីភាពរឹងមាំ និងទំនងជាអាចរក្សាបានផលចំណេញកម្រិតខ្ពស់ បើទោះជាសន្មតថាកម្រិតប្រាក់ចំណូល និងអត្រានៃការទទួលយកទាបជាងច្រើន ធៀបនឹងការរំពឹងទុកក៏ដោយ។

## ៤.២ ការវិភាគសេដ្ឋកិច្ចសម្រាប់សកម្មភាពអនុវត្តបង្ហាញ ២

របបចិញ្ចឹមជីវិតភាគច្រើន និងប្រភពប្រាក់ចំណូលនៅពាមក្រសោម គឺការនេសាទ។ សកម្មភាពបង្ហាញ ២ មានការពាក់ព័ន្ធតែជាមួយការនេសាទ និងការគ្រប់គ្រងទីជម្រកសម្រាប់មច្ឆជាតិ នៅឃុំពាមក្រសោប។ ផលចំណូលដុល/គ្រួសារនីមួយៗនាពេលបច្ចុប្បន្ននេះ សម្រាប់ពាមក្រសោប ត្រូវបានប៉ាន់ស្មានថាមាន $១.៦០៨ ក្នុងមួយឆ្នាំ[38] – ក្នុងនោះ ប្រមាណ ៦០-៧០% បានមកពីការនេសាទ និង ២៥% បានពីអេកូទេសចរណ៍។

### ៤.២.១ ឥទ្ធិពលខាងសេដ្ឋកិច្ចមកលើគ្រួសារ/ឆ្នាំ (ជលផល)

**សំគាល់៖** ការគណនានេះ ពិនិត្យមើលភាពខុសគ្នារវាងសេណារីយ៉ូចំនួនពីក្នុងវិស័យនេសាទ("មុន"និង "ក្រោយ")-ថវិកាក្នុងឧបសម្ព័ន្ធ ២។ មានការប៉ាន់ស្មានថា សកម្មភាព ២ អាចបង្កើនប្រាក់ចំណូលដុលសរុប (ទាំងបានពីការនេសាទ និងអេកូទេសចរណ៍) ប្រមាណ ២០% ជាបន្តបន្ទាប់ (ក្នុង៥ឆ្នាំ) សម្រាប់គ្រួសារទាំង ២៧៧ ដូចខាងក្រោម៖

**តារាង ៤.៥ ឥទ្ធិពលមកលើគ្រួសារ នៅពាមក្រសោប**

| ឥទ្ធិពលនៃសកម្មភាព ២មកលើគ្រួសារ៖ សហគមន៍នេសាទ | ឯកត្តា (គ.ក) | $ /ឯកត្តា | តម្លៃ | សរុប $ |
|---|---|---|---|---|
| ផលចំណេញ/គ្រួសារមធ្យម | | | | |
| ១. កំណើនសុទ្ធពីការនេសាទ | ១៣៣ | ១,៨/គ.ក | ២៤០ | |
| ២. កំណើនសុទ្ធពីអេកូទេសចរណ៍ | | | ៨០ | ៣២០ |
| **កំណើនសុទ្ធក្នុងគ្រួសារនីមួយៗ** | | | | **៣២០** |

### ៤.២.៤ ឥទ្ធិពលខាងសេដ្ឋកិច្ចនៃគម្រោង/ឆ្នាំ

ដោយរួមបញ្ចូលឥទ្ធិពលលើគ្រួសារទាំងអស់ ឥទ្ធិពលសរុបពីសកម្មភាពអនុវត្តបង្ហាញ មានដូចតទៅ៖

[38] ឯកសារយោង “Vulnerability and Risk Assessment Report”, CARP, June 2012.

**តារាង ៤.៦ ឥទ្ធិពលខាងសេដ្ឋកិច្ចនៅកម្រិតគម្រោង/ឆ្នាំ**

| ឥទ្ធិពលខាងសេដ្ឋកិច្ចនៃគម្រោងសម្រាប់ ២៧៧ គ្រួសារ | $ /គ្រួសារ | ចំនួនគ្រួសារ | តម្លៃ (១.000) | សរុប (១.000) $ |
|---|---|---|---|---|
| <u>ផលចំណេញសរុប</u> | | | | |
| ១. កំណើនសុទ្ធប្រចាំឆ្នាំ | ៣២០ | ២៧៧ | ៨៩ | |
| <u>កែតម្រូវ</u> | | | | |
| ២. អត្រាទទួលយក (១00% ក្រោឆ្នាំទី ៥) | 0 | | 0 | ៨៩ |
| ៣. កត្តាសាយភាយ (សូន្យ) | | | | |
| **ឥទ្ធិពលបណ្តោះអាសន្នជាប្រាក់ចំណូល** | | | | **៨៩** |
| **កត្តាមេគុណប្រាក់ចំណូល (ស្តង់ដារ)** | **១,២** | | | **១៧** |
| **ឥទ្ធិពលជាប្រាក់ចំណូលសរុប** | | | | **១០៦** |

ឥទ្ធិពលខាងសេដ្ឋកិច្ចប្រចាំឆ្នាំនៅឃុំពាមក្រសោបសម្រាប់សកម្មភាព ២ ត្រូវរំពឹងថាមាន $១០៦.000 ក្នុងមួយឆ្នាំ។ តួលេខនេះត្រូវបានគណនាសម្រាប់រយៈពេល ១៥ឆ្នាំ ដូចខាងក្រោម។

**តារាង ៤.៧ និទស្សន៍ឥទ្ធិពលខាងសេដ្ឋកិច្ចនៃគម្រោង**

| រង្វាស់ | តម្លៃ |
|---|---|
| ១. ឥទ្ធិពលជាប្រាក់ចំណូលសរុបពីគម្រោង (១៥ឆ្នាំ) | $0,៥-0,៨ លាន[39] |
| ២. ដកថ្លៃចំណាយលើគម្រោង (សម្រាប់ឆ្នាំ ២០១៣-១៤) | $ ៨0.000 |
| ៣. តម្លៃបច្ចុប្បន្នសុទ្ធ (១-២) | $ 0,៥ – 0,៧ លាន |
| ៤. អត្រាចំណូលផ្ទៃក្នុង | ៦0 %[40] |

ផលចំណូលទាំងនេះមានកម្រិតខ្ពស់ ទោះបីគិតតាមស្តង់ដារណាក៏ដោយ ហើយការវិយោគនេះត្រូវបានរកឃើញថាផ្តល់ផលចំណេញខាងសេដ្ឋកិច្ច។ ទោះជាយ៉ាងណាក៏ដោយ គួរកត់សំគាល់ថា ការវិនិយោគ

[39] តួលេខទាបជាងគឺសម្រាប់ NPV(១0%); ចំណែកតួលេខខ្ពស់ជាងគឺសម្រាប់ NPV(៥%)។ អត្រាទាំងពីរ (៥-១0) បង្ហាញពីរបាយនៃផលចំណូលដែលដកចេញអប្បហា។ បច្ចុប្បន្ននេះ អត្រា ៥% ក្នុងមួយឆ្នាំ មានភាពស្របគ្នាបំផុតជាមួយអត្រាអន្តរជាតិ។

[40] ការផាត់ចេញឥទ្ធិពលមេគុណសេដ្ឋកិច្ចអាចកាត់បន្ថយ IRR មកត្រឹម៥៧%។ ទោះជាយ៉ាងណាក៏ដោយ មេគុណនេះចាំបាច់សម្រាប់ផ្តល់ការវាយតម្លៃឲ្យសុក្រិតអំពីការវិនិយោគបែបនេះ។

($៧០.000) គឺសម្រាប់តែសកម្មភាពបង្ហាញដែលពាក់ព័ន្ធប៉ុណ្ណោះ ដែលជាមូលដ្ឋានសមស្របនៃការសម្រេចសម្រាប់ការវាយតម្លៃនេះ។ ថ្លៃចំណាយរួមសម្រាប់គម្រោង ឬសមាសភាគចំណាយរដ្ឋបាល សម្រាប់ការកសាងផែនការ ការគ្រប់គ្រង និងរដ្ឋបាលសម្រាប់ CARPមិនបានគិតបញ្ចូលឡើយ។ សមាសភាគទាំងនោះមិនពាក់ព័ន្ធឡើយសម្រាប់ការគណនានេះ ដោយសារដំណាក់កាលនេះ ការសម្រេចគឺអំពីសកម្មភាពបង្ហាញដែលត្រូវអនុវត្ត។

សកម្មភាព ២ ក្នុងការអនុវត្តបង្ហាញនេះទំនងជាផ្តល់ផលខ្ពស់បើគិតតាមគោលការណ៍សេដ្ឋកិច្ច។

### ការវិភាគភាពងាយប្រែប្រួល

ការវិភាគនេះមានបំណងគណនាឥទ្ធិពលនៃការប្រែប្រួលដែលអាចកើតមាននៃអថេរ និងឥទ្ធិពលមកលើ IRR នៃករណីគោល។ ការវិភាគភាពងាយប្រែប្រួលនេះផ្តោតលើអថេរដែលអាចគណនាបានចំនួនបី ដែលមានឥទ្ធិពលមកលើ IRR (និងជោគជ័យ)នៃសកម្មភាពនេះ។ នេះ។ អថេរគន្លឹះដែលបានកំណត់ឃើញគឺប្រាក់ចំណូលក្នុងគ្រួសារនីមួយៗ អត្រានៃការទទួលយក និងការសាយភាយ។ តារាង ៤.៨ ខាងក្រោមបង្ហាញពីឥទ្ធិលដែលអាចកើតមានបណ្តាលពីការថយចុះនៃអថេរទាំងនេះ មកលើអត្រាចំណូលផ្ទៃក្នុងដូចតទៅៈ

**តារាង ៤.៨៖ ភាពងាយប្រែប្រួលសម្រាប់សកម្មភាពអនុវត្តបង្ហាញ ២**

| **បរិយាយ/អថេរ** | **ការប្រែប្រួល** | **IRR** |
|---|---|---|
| ករណីគោល | មិនពាក់ព័ន្ធ | ៦០% |
| ប្រាក់ចំណូល/គ្រួសារ ($) | -១៦៥ | ២០% |
| អត្រាទទួលយក | -០,៧៥ | ២០% |
| ការសាយភាយ | -០,៧៧ | ២០% |

នេះមានន័យថា កំណើនប្រាក់ចំណូលប្រចាំគ្រួសារអាចកាត់បន្ថយ $១៦៥ និងនៅតែអាចរក្សាបានយ៉ាងងាយក្នុងអត្រាចំណូលផ្ទៃក្នុង ២០%។ ទោះជាយ៉ាងណាក៏ដោយ កំណើនប្រាក់ចំណូលមិនទំនងជាអាចថយចុះបែបនេះទេ ដូច្នេះការគណនានេះមានការគិតគូរម៉ត់ចត់លើការប្រែប្រួលបែបនេះ។

ចំពោះអត្រានៃការទទួលយក ការគណនានេះក៏អាចកាត់បន្ថយ ៧៥%ផងដែរ ហើយនៅតែអាចរក្សាអត្រា IRR បាន ២០%។ ដូចគ្នានេះដែរ ការថយចុះបែបនេះ មិនទំនងជាកើតមានទេ ដូច្នេះសេណារីយ៉ូនៃការគណនានេះមានស្ថានភាពល្អ។

### ការសន្និដ្ឋាន

សកម្មភាពសាកល្បង ២ ផ្តល់ផលចំណេញខ្ពស់ខាងសេដ្ឋកិច្ចសម្រាប់គម្រោង និងគ្រួសារដែលចូលរួម។ ការគណនាបង្ហាញពីភាពរឹងមាំ និងទំនងជាអាចរក្សាបានផលចំណេញកម្រិតខ្ពស់ បើទោះជាសន្មតថាកម្រិតប្រាក់ចំណូល និងអត្រានៃការទទួលយកទាបជាងច្រើន ធៀបនឹងការរំពឹងទុកក៏ដោយ។

## ៤.៣ ការវិភាគសេដ្ឋកិច្ចសម្រាប់សកម្មភាពបង្ហាញ ៤

### ៤.៣.១ ឥទ្ធិពលខាងសេដ្ឋកិច្ចសម្រាប់គ្រួសារ/ឆ្នាំ (ការចិញ្ចឹមសត្វ)

**សំគាល់៖** ការគណនានេះ ពិនិត្យមើលភាពខុសគ្នារវាងទម្លាប់ពីរបែបខុសគ្នាក្នុងកសិកម្ម("មុន" និង"ក្រោយ" អនុវត្តប្រព័ន្ធទុនបង្វិលសម្រាប់ផ្តល់ជាសត្វចិញ្ចឹម) - សូមអានថវិកាផ្នែកការចិញ្ចឹមសត្វនៅក្នុងឧបសម្ព័ន្ធ ២។

**តារាង ៤.៩ ឥទ្ធិពលខាងសេដ្ឋកិច្ចនៅកម្រិតគ្រួសារ/ឆ្នាំ**

| ឥទ្ធិពលខាងសេដ្ឋកិច្ចជាមធ្យមសម្រាប់គ្រួសារដែលចូលរួមក្នុងប្រព័ន្ធទុនបង្វិលចិញ្ចឹមសត្វ | ឯកត្តា (គ.ក) | $ /ឯកត្តា | តម្លៃ | សរុប $ |
|---|---|---|---|---|
| <u>ផលចំណេញ/គ្រួសារមធ្យម</u> | | | | |
| ១. <u>កំណើន</u>ប្រាក់ចំណេញពីប្រព័ន្ធទុនបង្វិលចិញ្ចឹមសត្វ | ១០០ | ២,៥ | ២៥០ | |
| <u>ថ្លៃចំណាយ</u> | | | | |
| ១. កំណើនថ្លៃអថេរ/គ្រួសារ | | | -៣៥ | ២៥០ |
| ២. កំណើនថ្លៃសម្រាប់រយៈពេលវែង (ដូចជា បរិក្ខារ ជួល ការប្រាក់) | | | -១៥ | |
| ៣. ថ្លៃឱកាស (ចំណូលប្រចាំឆ្នាំដែលមិនបានទទួលប្រសិនបើមាន) | | | <u>0</u> | -៥0 |
| **កំណើនសុទ្ធក្នុងគ្រួសារនីមួយៗ** | | | | ២០០ |

### ៤.៣.២ ឥទ្ធិពលខាងសេដ្ឋកិច្ចសម្រាប់គម្រោង/ឆ្នាំ

ដោយរួមបញ្ចូលឥទ្ធិពលលើគ្រួសារទាំងអស់ ឥទ្ធិពលសរុបពីសកម្មភាពបង្ហាញដូចក្នុងតារាង ៤.១០៖

**តារាង ៤.១០ ឥទ្ធិពលខាងសេដ្ឋកិច្ចនៅកម្រិតគម្រោង/ឆ្នាំ**

| ឥទ្ធិពលខាងសេដ្ឋកិច្ចនៃគម្រោងសម្រាប់អ្នកចូលរួម ១០០នាក់ដំបូង | $ /គ្រួសារ | ចំនួនគ្រួសារ | តម្លៃ (១.០០០) | សរុប (១.០០០) $ |
|---|---|---|---|---|
| <u>ផលចំណេញសរុប</u> | | | | |
| ១. កំណើនសុទ្ធប្រចាំឆ្នាំ | ២០០ | ១០០ | ២០ | ២០ |
| <u>កែតម្រូវ</u> | | | | |
| ២. អត្រាទទួលយក (៧៥%) | | | | -៥ |
| ៣. កត្តាសាយភាយ (១០%) | | | | +២ |
| **ឥទ្ធិពលជាប្រាក់ចំណូលបណ្តោះអាសន្ន** | | | | **១៧** |
| **កត្តាមេគុណប្រាក់ចំណូល (ស្តង់ដារ)** | **១,២** | | | **៣** |
| **ឥទ្ធិពលជាប្រាក់ចំណូលសរុប (ជុំដំបូងប៉ុណ្ណោះ)** | | | | **២០** |

ឥទ្ធិពលខាងសេដ្ឋកិច្ចប្រចាំឆ្នាំដែលរំពឹងទុកសម្រាប់ឃុំគោលដៅទាំង ៧ ពីសកម្មភាពបង្ហាញ ៤ គឺ $២០.០០០ ក្នុងមួយឆ្នាំ - សម្រាប់តែជុំទីមួយ។ តួលេខនេះត្រូវបានគណនាសម្រាប់រយៈពេល ១៥ឆ្នាំ ជាមួយ ៥០គ្រួសារបន្ថែមទៀត ដែលរំពឹងថានឹងចូលរួមសម្រាប់រយៈពេល ១០ឆ្នាំ។ លទ្ធផលមានដូចខាងក្រោម។

**តារាង ៤.១១ និទស្សន៍ឥទ្ធិពលខាងសេដ្ឋកិច្ចនៃគម្រោង**

| **រង្វាស់** | **តម្លៃ** |
|---|---|
| ១. ឥទ្ធិពលជាប្រាក់ចំណូលសរុបពីគម្រោង (១៥ឆ្នាំ) | $0,៥-0,៧ លាន[41] |
| ២. ដកថ្លៃចំណាយលើគម្រោង (សម្រាប់ឆ្នាំ ២០១៣-១៤) | $ ១៧៥.000 |
| ៣. តម្លៃបច្ចុប្បន្នសុទ្ធ (១-២) | $ 0,៣ – 0,៥ លាន |
| ៤. អត្រាចំណូលផ្ទៃក្នុង | ៣១ % |

ផលចំណូលទាំងនេះមានកម្រិតខ្ពស់។ ទោះជាយ៉ាងណាក៏ដោយ គួរកត់សំគាល់ថា ការវិនិយោគ ($១៧៥.000) គឺសម្រាប់តែសកម្មភាពបង្ហាញដែលពាក់ព័ន្ធប៉ុណ្ណោះ ដែលជាមូលដ្ឋានសមស្របនៃការសម្រេចសម្រាប់ការវាយតម្លៃនេះប៉ុណ្ណោះ។ ថ្លៃចំណាយរួមសម្រាប់គម្រោង ឬសមាសភាគចំណាយរដ្ឋបាល

[41]តួលេខទាបជាងគឺសម្រាប់ NPV(១០%); ចំណែកតួលេខខ្ពស់ជាងគឺសម្រាប់ NPV(៥%)។ អត្រាទាំងពីរ (៥-១០) បង្ហាញពីរបាយនៃផលចំណូលដែលដកចេញអប្បហា។ បច្ចុប្បន្ននេះ អត្រា ៥% ក្នុងមួយឆ្នាំ មានភាពស្របគ្នាបំផុតជាមួយអត្រាអន្តរជាតិ។

សម្រាប់ការកសាងផែនការ ការគ្រប់គ្រង និងរដ្ឋបាលសម្រាប់ CARP មិនបានគិតបញ្ចូលឡើយ។ សមាសភាគទាំងនោះមិនពាក់ព័ន្ធឡើយសម្រាប់ការគណនានេះ ដោយសារដំណាក់កាលនេះ ការសម្រេចគឺអំពីសកម្មភាពបង្ហាញដែលត្រូវអនុវត្ត។

សកម្មភាព ២ ក្នុងការអនុវត្តបង្ហាញនេះទំនងជាផ្តល់ផលខ្ពស់បើគិតតាមគោលការណ៍សេដ្ឋកិច្ច។

**ការវិភាគភាពងាយប្រែប្រួល**

ការវិភាគភាពងាយប្រែប្រួលនេះផ្តោតលើអថេរដែលអាចគណនាបានចំនួនបីដែលមានឥទ្ធិពលមកលើ IRR (និងជោគជ័យ)នៃសកម្មភាពនេះ។ អថេរគន្លឹះដែលបានកំណត់ឃើញគឺប្រាក់ចំណូលក្នុងគ្រួសារនីមួយៗ អត្រានៃការទទួលយក និងការសាយភាយ។ តារាង ៤.១២ ខាងក្រោមបង្ហាញពីឥទ្ធិលដែលអាចកើតមានបណ្តាលពីការថយចុះនៃអថេរទាំងនេះ មកលើអត្រាចំណូលផ្ទៃក្នុងនៃសកម្មភាពបង្ហាញនេះ។

**តារាង ៤.១២៖ ភាពងាយប្រែប្រួលសម្រាប់សកម្មភាពអនុវត្តបង្ហាញ ៤**

| **បរិយាយ/អថេរ** | **ការប្រែប្រួល** | **IRR** |
|---|---|---|
| ករណីគោល | មិនពាក់ព័ន្ធ | ៣១% |
| ប្រាក់ចំណូល/គ្រួសារ ($) | -៧៦ | ២០% |
| អត្រាទទួលយក | -០,៣០ | ២០% |
| ការសាយភាយ | -០,៤១ | ២០% |

នេះមានន័យថា *កំណើនប្រាក់ចំណូលប្រចាំគ្រួសារ*អាចកាត់បន្ថយ $៧៦ និងនៅតែអាចរក្សាបានយ៉ាងងាយក្នុងអត្រាចំណូលផ្ទៃក្នុង ២០%។ ប៉ុន្តែ កំណើនប្រាក់ចំណូលមិនទំនងជាអាចថយចុះបែបនេះទេ ដូច្នេះ ការគណនានេះមានការគិតគូរម៉ត់ចត់លើការប្រែប្រួលបែបនេះ។

ចំពោះអត្រានៃការទទួលយក ការគណនានេះក៏អាចកាត់បន្ថយ ៣០%ផងដែរ ហើយនៅតែអាចរក្សាអត្រា IRR បាន ២០%។ ដូចគ្នានេះដែរ ការថយចុះបែបនេះ មិនទំនងជាកើតមានទេ ដូច្នេះសេណារីយ៉ូនៃការគណនានេះមានស្ថានភាពល្អ។

គេអាចនិយាយបានដូចគ្នានេះដែរសម្រាប់កម្រិតនៃការសាយភាយសកម្មភាពនេះ។ ការសាយភាយអាចកាត់បន្ថយ ៤១% និងអាចរក្សាបាន IRR ក្នុងរង្វង់ ២០%។ ដូចគ្នានេះដែរ ការថយចុះបែបនេះ មិនទំនងជាកើតមានទេ ដូច្នេះសេណារីយ៉ូនៃការគណនានេះមានស្ថានភាពរឹងមាំល្អ។

ដូច្នេះ បើទោះជាមានការប្រែប្រួលច្រើនក៏ដោយលើអថេរខាងលើ សកម្មភាពនេះបង្ហាញពីភាពសមស្របបំផុត ដែលអាចផ្ដល់ផលចំណេញ ដោយគិត IRR ក្នុងកម្រិត ២០%។

**ការសន្និដ្ឋាន**

សកម្មភាពសាកល្បង ៤ ផ្ដល់ផលចំណេញខ្ពស់ខាងសេដ្ឋកិច្ចសម្រាប់គម្រោង និងគ្រួសារដែលចូលរួម។ ការគណនាបង្ហាញពីភាពរឹងមាំ និងទំនងជាអាចរក្សាបានផលចំណេញកម្រិតខ្ពស់ បើទោះជាសន្មតថាកម្រិតប្រាក់ចំណូល និងអត្រានៃការទទួលយកទាបជាងច្រើន ធៀបនឹងការរំពឹងទុកក៏ដោយ។

## ៤.៤ ការវិភាគសេដ្ឋកិច្ចសម្រាប់សកម្មភាពសាកល្បង ៥

### ៤.៤.១ ឥទ្ធិពលខាងសេដ្ឋកិច្ចសម្រាប់គ្រួសារ/ឆ្នាំ (ការត្រងទឹកភ្លៀង)

**សំគាល់៖** ការគណនានេះ ពិនិត្យមើលភាពខុសគ្នារវាងទម្លាប់("ចាស់" និង"ថ្មី")។

**តារាង ៤.១៣ ឥទ្ធិពលនៅកម្រិតគ្រួសារនៃការត្រងទឹកភ្លៀង**

| ឥទ្ធិពលជាមធ្យមលើគ្រួសារនីមួយៗ | ឯកត្តា (គ.ក) | $/ឯកត្តា | តម្លៃ | សរុប $ |
|---|---|---|---|---|
| ផលចំណេញ/គ្រួសារមធ្យម | | | | |
| ១. កំណើនទិន្នផលបន្លែពីដី ០,១ហ.ត នៅរដូវប្រាំង (ឱឡឹក) | ២០០ | ០,៣៦ | ៧២ | |
| ២. បន្លែបន្ទាប់បន្សំ | | | ១៨ | |
| ៣. ទឹកប្រចាំគ្រួសារ (១០ម)៣ | ១០ | ២,៥ | | |
| ថ្លៃចំណាយ | | | | |
| ១. កំណើនថ្លៃអថេរ/គ្រួសារ | | | ២៥ | **១១៥** |
| ២. កំណើនថ្លៃសម្រាប់រយៈពេលវែង (ដូចជា បរិក្ខារ ជួល ការប្រាក់) | | | **-២៥** | **-២៥** |
| ៣. ថ្លៃឱកាស (ចំណូលប្រចាំឆ្នាំដែលមិនបានទទួល បើមាន) | | | ០ | |
| **កំណើនសុទ្ធក្នុងគ្រួសារនីមួយៗពីដីជាមធ្យម ០,១ហ.ត ដែលដាំបន្លែ** | | | | ៩០ |

**តារាង ៤.១៤ ឥទ្ធិពលខាងសេដ្ឋកិច្ចនៅកម្រិតគម្រោង/ឆ្នាំ**

| ឥទ្ធិពលខាងសេដ្ឋកិច្ចនៃគម្រោងសម្រាប់២០០ គ្រួសារ | $ /គ្រួសារ | ចំនួនគ្រួសារ | តម្លៃ (១.០០០) | សរុប (១.០០០) $ |
|---|---|---|---|---|
| **ផលចំណេញសរុប** | | | | |
| ១. កំណើនសុទ្ធប្រចាំឆ្នាំ | ៩០ | ២០០ | ១៨ | |
| **កែតម្រូវ** | | | | |
| ២. អត្រាទទួលយក (៩០%) | ០ | | ០ | ១៨ |
| ៣. កត្តាសាយភាយ (១០%) | | | | |
| **ឥទ្ធិពលជាប្រាក់ចំណូលបណ្តោះអាសន្ន** | | | | ១៨ |
| **កត្តាមេគុណប្រាក់ចំណូល (ស្តង់ដារ)** | ១,២ | | | ៤ |
| **ឥទ្ធិពលជាប្រាក់ចំណូលសរុប** | | | | ២២ |

ឥទ្ធិពលខាងសេដ្ឋកិច្ចប្រចាំឆ្នាំដែលរំពឹងទុកសម្រាប់ឃុំគោលដៅទាំង ៧ ពីសកម្មភាពបង្ហាញ ៥ គឺ $២២.០០០ ក្នុងមួយឆ្នាំ។ លទ្ធផលមានដូចខាងក្រោម៖

**តារាង ៤.១៥ និទស្សន៍ឥទ្ធិពលខាងសេដ្ឋកិច្ចនៃគម្រោង**

| រង្វាស់ | តម្លៃ |
|---|---|
| ១. ឥទ្ធិពលជាប្រាក់ចំណូលសរុបពីគម្រោង (១៥ឆ្នាំ) | $0,១៥ -0,២១ លាន[42] |
| ២. ដកថ្លៃចំណាយលើគម្រោង (សម្រាប់ឆ្នាំ ២០១៣-១៤) | $ ៥0.000 |
| ៣. តម្លៃបច្ចុប្បន្នសុទ្ធ (១-២) | $ 0,១១ – 0,១៧ លាន |
| ៤. អត្រាចំណូលផ្ទៃក្នុង | ៥៦ % |

ផលចំណូលទាំងនេះមានកម្រិតខ្ពស់ ហើយការវិនិយោគនេះផ្តល់ផលចំណេញ។ ទោះជាយ៉ាងណាក៏ដោយ គួរកត់សំគាល់ថា ការវិនិយោគ ($៥0.000) គឺសម្រាប់តែសកម្មភាពបង្ហាញដែលពាក់ព័ន្ធប៉ុណ្ណោះ ដែលជាមូលដ្ឋានសមស្របនៃការសម្រេចសម្រាប់ការវាយតម្លៃនេះប៉ុណ្ណោះ។ ថ្លៃចំណាយរួមសម្រាប់គម្រោង ឬសមាសភាគចំណាយរដ្ឋបាល សម្រាប់ការកសាងផែនការ ការគ្រប់គ្រង និងរដ្ឋបាលសម្រាប់ CARPមិនបាន

[42]តួលេខទាបជាងគឺសម្រាប់ NPV(១០%); ចំណែកតួលេខខ្ពស់ជាងគឺសម្រាប់ NPV(៥%)។ អត្រាទាំងពីរ (៥-១០) បង្ហាញពីរបាយនៃផលចំណូលដែលដកចេញអប្បហា។ បច្ចុប្បន្ននេះ អត្រា ៥% ក្នុងមួយឆ្នាំ មានភាពស្របគ្នាបំផុតជាមួយអត្រាអន្តរជាតិ។

គិតបញ្ចូលឡើយ។ សមាសភាគទាំងនោះមិនពាក់ព័ន្ធឡើយសម្រាប់ការគណនានេះ ដោយសារដំណាក់កាលនេះ ការសម្រេចគឺអំពីសកម្មភាពបង្ហាញដែលត្រូវអនុវត្ត។

សកម្មភាព ៥ ក្នុងការអនុវត្តបង្ហាញនេះទំនងជាផ្តល់ផលខ្ពស់បើគិតតាមគោលការណ៍សេដ្ឋកិច្ច។

## ការវិភាគភាពងាយប្រែប្រួល

ការវិភាគភាពងាយប្រែប្រួលនេះ ផ្តោតលើឥទ្ធិពលនៃការប្រែប្រួលដែលអាចមានមកលើអថេរ និងឥទ្ធិពលមកលើ IRR នៃករណីគោល។ ការវិភាគភាពងាយប្រែប្រួលនេះផ្តោតលើអថេរដែលអាចគណនាបានចំនួនបីដែលមានឥទ្ធិពលមកលើ IRR (និងជោគជ័យ)នៃសកម្មភាពនេះ។ អថេរគន្លឹះដែលបានកំណត់ឃើញ គឺប្រាក់ចំណូលក្នុងគ្រួសារនីមួយៗ អត្រានៃការទទួលយក និងការសាយភាយ។ តារាង៤.១៦ ខាងក្រោម បង្ហាញពីឥទ្ធិលដែលអាចកើតមានបណ្តាលពីការថយចុះនៃអថេរទាំងនេះ មកលើអត្រាចំណូលផ្ទៃក្នុងនៃសកម្មភាពបង្ហាញនេះ។

**តារាង ៤.១៦៖ ភាពងាយប្រែប្រួលសម្រាប់សកម្មភាពអនុវត្តបង្ហាញ ៥**

| បរិយាយ/អថេរ | ការប្រែប្រួល | IRR |
|---|---|---|
| ករណីគោល | មិនពាក់ព័ន្ធ | ៥៦% |
| ប្រាក់ចំណូល/គ្រួសារ ($) | -៤៩ | ២០% |
| អត្រាទទួលយក | -0,៤៦ | ២០% |
| ការសាយភាយ | -0,៦១ | ២០% |

នេះមានន័យថា *កំណើនប្រាក់ចំណូលប្រចាំគ្រួសារ*អាចកាត់បន្ថយ $៤៩ និងនៅតែអាចរក្សាបានយ៉ាងងាយក្នុងអត្រាចំណូលផ្ទៃក្នុង ២០% ។ ប៉ុន្តែ កំណើនប្រាក់ចំណូលមិនទំនងជាអាចថយចុះបែបនេះទេ ដូច្នេះការគណនានេះមានការគិតគូរម៉ត់ចត់លើការប្រែប្រួលបែបនេះ។

ចំពោះអត្រានៃការទទួលយក ការគណនានេះក៏អាចកាត់បន្ថយ ៤៦% ផងដែរ ហើយនៅតែអាចរក្សាអត្រា IRR បាន ២០%។ ដូចគ្នានេះដែរ ការថយចុះបែបនេះ មិនទំនងជាកើតមានទេ ដូច្នេះសេណារីយ៉ូនៃការគណនានេះមានស្ថានភាពរឹងមាំល្អ។

គេអាចនិយាយបានដូចគ្នានេះដែរសម្រាប់កម្រិតនៃការសាយភាយសកម្មភាពនេះ។ ការសាយភាយអាចកាត់បន្ថយ ៦១% និងអាចរក្សាបាន IRR ក្នុងរង្វង់ ២០%។ ដូចគ្នានេះដែរ ការថយចុះបែបនេះ មិនទំនងជាកើតមានទេ ដូច្នេះសេណារីយ៉ូនៃការគណនានេះមានស្ថានភាពរឹងមាំល្អ។

នៅក្នុងសេណារីយ៉ូដែលបានបង្ហាញ ផលចំណូលនៅតែមានកម្រិតខ្ពស់ បើទោះជាមានការប្រែប្រួលអថេរដូចខាងលើក៏ដោយ។ ដូច្នេះ សកម្មភាពបង្ហាញ មិនមានការប្រែប្រួលច្រើនឡើយ តបនឹងការប្រែប្រួលនៃ

អថេរខាងលើ។ នេះក៏បង្ហាញផងដែរថា សកម្មភាព ៥ មានភាពសមស្របបំផុត ដែលអាចផ្តល់ផលចំណេញដោយគិត IRR ក្នុងកម្រិត ២០%។

**ការសន្និដ្ឋាន**

សកម្មភាពសាកល្បង ៥ ផ្តល់ផលចំណេញខ្ពស់ខាងសេដ្ឋកិច្ចសម្រាប់គម្រោង និងគ្រួសារដែលចូលរួម។ ការគណនាបង្ហាញពីភាពរឹងមាំ និងទំនងជាអាចរក្សាបានផលចំណេញកម្រិតខ្ពស់ បើទោះជាសន្មតថា កម្រិតប្រាក់ចំណូល និងអត្រានៃការទទួលយកទាបជាងច្រើន ធៀបនឹងការរំពឹងទុកក៏ដោយ។

## ៤.៥ សង្ខេបអំពីការគិតគូរផ្សេងទៀត

### ៤.៥.១ ថ្លៃចំណាយ និងផលចំណេញសង្គម

សកម្មភាពដែលលើកស្នើសម្រាប់ការអនុវត្តបង្ហាញសុទ្ធតែស្របគ្នាជាមួយអាទិភាពដែលតំណាងសហគមន៍បានលើកឡើង និងពង្រឹងជាបន្ថែមនូវយុទ្ធសាស្ត្រដោះទ័លដែលមានស្រាប់។ ដូច្នេះ ថ្លៃចំណាយសង្គមមានកម្រិតកំណត់ ប៉ុន្តែផលចំណេញសង្គមនៃសកម្មភាពដែលលើកស្នើមានច្រើន ដោយសារតែសំណើសកម្មភាពទាំងនេះគាំទ្រដល់អាទិភាពដែលសហគមន៍បានលើកឡើង។

ទោះជាយ៉ាងណាក៏ដោយ គេអាចកត់សំគាល់បានថា សំណើពង្រីកការចិញ្ចឹមសត្វ (ជាពិសេស សត្វតូចៗ) និងការដាំបន្លែ អាចបន្ថែមសម្ពាធមកលើកម្លាំងពលកម្មរបស់ស្ត្រី ដោយសារតែសកម្មភាពទាំងនេះតាមប្រពៃណី ត្រូវបានចាត់ទុកថាជាការទទួលខុសត្រូវរបស់ស្ត្រី។ នេះជាកិច្ចការមួយដែលត្រូវលើកយកមកពិចារណាផងដែរ នៅក្នុងពេលអនុវត្ត។

ក្រៅពីនេះ មានផលចំណេញបន្ថែមដែលពិបាកគណនា។ ជាសង្ខេប ផលចំណេញទាំងនោះរួមមាន៖

សម្រាប់សកម្មភាព ១ នៃការអនុវត្តបង្ហាញនេះគឺ៖

- ការថយចុះនៃសម្ពាធលើបរិស្ថាន ក៏ដូចជា សុខភាពសត្វ និងមនុស្ស តាមរយៈការជម្រុញវិធានការចម្រុះការពារដំណាំ (IPM) ដែលបានបង្ហាញថា អាចកាត់បន្ថយការប្រើប្រាស់ថ្នាំកំចាត់កត្តាចង្រៃពី ៧០-៩០% ឧទា. នៅបង់ក្លាដែស (ការសិក្សាឥទ្ធិពលដោយដានីដា ឆ្នាំ ២០០៣)
- ការជម្រុញការផលិតបន្លែ ដែលទំនងជាជួយបង្កើនអាហារូបត្ថម្ភ ក៏ដូចជាប្រាក់ចំណូល សម្រាប់គ្រួសារដែលចូលរួម

សម្រាប់សកម្មភាព ៣ នៃការអនុវត្តបង្ហាញនេះគឺ៖

- កំណែលម្អការគ្រប់គ្រងបរិស្ថាន តាមរយៈវិធានការដែលមាននិរន្តរភាពសម្រាប់ការផលិតចំណីស្ងួត ដែលមានគោលដៅ បញ្ចៀសការលែងសត្វឲ្យស៊ីស្មៅច្រើនហួសកម្រិត
- កំណែលម្អអាហារូបត្ថម្ភរបស់គ្រួសារដែលចូលរួម តាមរយៈ ការទទួលបានផលិតផលពីសត្វចិញ្ចឹម។

ចំណុចទាំងអស់ខាងលើ និងផលចំណេញដែលបានប៉ាន់ប្រមាណក្នុងផ្នែក ៤.១-៤.៣ បង្ហាញពីទស្សនវិស័យល្អក្នុងការកែលម្អបានច្រើននូវរបរចិញ្ចឹមជីវិតនៃគ្រួសារជាគោលដៅ។

### ៤.៥.២ សមត្ថភាពបន្សាំ

សមត្ថភាពរបស់សហគមន៍ ដើម្បីបន្សាំនឹងការប្រែប្រួលអាកាសធាតុ ត្រូវបានគិតគូររួចមកហើយនៅក្នុង“របាយការណ៍វាយតម្លៃភាពងាយរងគ្រោះ និងហានិភ័យ”, CARP,ខែកក្កដា ឆ្នាំ ២០១២។ សកម្មភាពសាកល្បងដែលបានលើកស្នើនេះ ត្រូវបានរៀបចំឡើងដោយឡែកដើម្បីឲ្យស្របគ្នាជាមួយសមត្ថភាពបន្សាំរបស់សហគមន៍។[43]

### ៤.៥.៣ បញ្ហាស្ថាប័ន

សកម្មភាពសាកល្បងដែលលើកស្នើឡើងទាំងអស់អាចអនុវត្តទៅបាន អាស្រ័យលើកិច្ចសហការរលូនរវាងCARP, ក្រសួងបរិស្ថាន និងស្ថាប័នដទៃទៀតនៃរដ្ឋាភិបាល ជាពិសេស ស្ថាប័ននានាចំណុះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលរួមទាំង មន្ទីរកសិកម្ម ខណ្ឌរដ្ឋបាលជលផល និងមន្ទីរធនធានទឹក និងឧតុនិយមផងដែរ។

កិច្ចសហប្រតិបត្តិការអន្តរក្រសួងបែបនេះនៅកម្ពុជា មិនសុទ្ធតែមានដំណើរការបានរលូនដូចដែលចង់បានឡើយ។ ទោះជាយ៉ាងណាក៏ដោយ នៅក្នុងន័យនេះវាជាតម្រូវការចាំបាច់ដើម្បីឲ្យការអនុវត្តទទួលជោគជ័យ ដែលកិច្ចសហប្រតិបត្តិការត្រូវតែទាន់ពេលវេលា និងសមស្របផងដែរ។

សមត្ថភាពនៅក្នុងស្ថាប័ននានាដែលបានលើកឡើងខាងលើ ក៏អាចមានកម្រិតកំណត់ផងដែរ។ ដូច្នេះ ការពិគ្រោះយោបល់ និងការចរចាដែលកំពុងប្រព្រឹត្តទៅអំពីតួនាទី និងការទទួលខុសត្រូវ ដែលទាក់ទងនឹងការអនុវត្តពិតជាមានសារៈសំខាន់ណាស់។

### ៤.៥.៤ រយៈពេលខ្លីសម្រាប់ការអនុវត្ត

មានការគូសបញ្ជាក់រួចមកហើយ (នៅក្នុងផ្នែក ៤.១) ថា សមាសភាគ CARP នឹងត្រូវបញ្ចប់នៅចុងត្រីមាសទី១ ឆ្នាំ២០១៤ ដូច្នេះអនុញ្ញាតឲ្យមានពេលត្រឹមតែមួយរដូវដាំដំណាំ (រដូវវស្សាឆ្នាំ២០១៣) សម្រាប់ការអនុវត្តសកម្មភាពសាកល្បងទាំងនេះ។ នេះមិនមែនជាស្ថានភាពល្អឡើយ ដោយសារសកម្មភាពសាកល្បងទាំងអស់អាចបានផលល្អ ក្នុងករណីដែលសមាសភាគនេះនៅមានវត្តមានជាសកម្មភាពបន្ត និងពង្រឹងលទ្ធផលដែលបានទទួលកន្លងមក។

ក្នុងចំណោមសកម្មភាពដែលលើកស្នើទាំង៥ដែលបានវិភាគសេដ្ឋកិច្ច សកម្មភាព ១, ៣ និង ៥ ត្រូវបានចាត់ទុកថា អាចប្រែប្រួលតិចតួចបំផុត អាស្រ័យដោយការគាំទ្ររយៈពេលខ្លី ដោយសារតែយន្តការចំបងៗ (សាលាស្រែកសិករ) ប្រតិបត្តិការខ្លាំងក្លាតែក្នុងមួយរដូវប៉ុណ្ណោះ សម្រាប់ទីកន្លែងនីមួយៗ។

ទាំងសកម្មភាព ២ និង ៤ ពឹងផ្អែកខ្លាំងជាង មកលើសកម្មភាពបន្ត និងពង្រឹងឲ្យបានគ្រប់គ្រាន់ នៅក្រោយការអនុវត្តក្នុងឆ្នាំដំបូង។ ដូច្នេះឥទ្ធិពលជាប្រាក់ចំណូលនៅពាមក្រសោប ត្រូវបានរំពឹងថានឹងទទួលបានតែនៅក្រោយបានអនុវត្តរយៈពេល ៥ឆ្នាំពេញ ចំណែកប្រព័ន្ធទុនបង្វិលសម្រាប់ផ្តល់សត្វចិញ្ចឹមត្រូវបានរំពឹងថា

---

[43]ក្រុមនេះបានទទួលដំណឹងថា ការចរចាបន្ថែមរវាងវិនិយោគិន និងឃុំថ្មីទាំងបី នៅព្រែនប់ អាចត្រូវអនុវត្តជាបន្តទាក់ទងនឹងកិច្ចសន្យាសម្រាប់ការដាំដំណាំ និងការថែទាំទំនប់។

នឹងបន្តទទួលអ្នកចូលរួមថ្មីៗសម្រាប់រយៈពេល ១០ឆ្នាំ។ ដូច្នេះ ទាំងសកម្មភាពទី ២ និង ៤ ទំនងជាប្រឈមហានិភ័យខ្លាំងជាង ដោយសារត្រូវការឲ្យមានសកម្មភាពបន្ត និងការពង្រឹងបន្ថែមនេះ។

ការប៉ាន់ស្មានថ្លៃចំណាយសម្រាប់សកម្មភាពភាគច្រើន ពិតជាមានគិតគូរអំពីសកម្មភាពបន្ត និងលក្ខខណ្ឌនៃការពង្រឹងបន្ថែមទាំងនេះ ដោយលៃលកមូលនិធិខ្លះសម្រាប់ឃុំនីមួយៗ សម្រាប់សកម្មភាពបន្ត។ សកម្មភាពបន្តទាំងនេះ អាចមានក្រោមរូបភាពជាក្រុមប្រឹក្សាឃុំជួលបុគ្គលិកផ្សព្វផ្សាយ ឧទា.សម្រាប់រយៈពេល ៣ ឆ្នាំ ដោយអាចក្លាយជាការងារពេញម៉ោង ប្រសិនបើបង្ហាញថាផ្តល់លទ្ធផលល្អ និងក្នុងករណីដែលក្រុមប្រឹក្សាឃុំមានលទ្ធភាពបំពេញការចំណាយ។

## ៥. សេចក្តីសន្និដ្ឋាន និងអនុសាសន៍

ក្នុងន័យសេដ្ឋកិច្ច សកម្មភាពសាកល្បងដែលបានវិភាគ អាចប្រៀបធៀបបានដូចតទៅ៖

**តារាង ៥.១ ការប្រៀបធៀបផលចំណេញសេដ្ឋកិច្ច**

| សកម្មភាពសាកល្បង | ផលចំណេញផ្ទាល់ដល់គ្រួសារ | អត្រាចំណូលផ្ទៃក្នុង | តម្លៃបច្ចុប្បន្នសុទ្ធនៃការវិនិយោគ[44] | ផលចំណេញក្នុងមួយគ្រួសារ |
|---|---|---|---|---|
| ១និង៣៖ FFS | ១២០០ | ១៩៣% | $១,៧លាន | $១៤១៧ |
| ២. ពាមក្រសោប | ២៧៧ | ៦០% | $០,៥លាន | $១៨០៦ |
| ៤. ការចិញ្ចឹមសត្វ | ៦០០ | ៣១% | $០,៣លាន | $៥០០ |
| ៥. ការត្រងទឹកភ្លៀង | ២០០ | ៥៦% | $០,១លាន | $៥០០ |

ដូច្នេះ ជាការច្បាស់ណាស់ថា សកម្មភាពសាកល្បងនានាដែលមានក្នុងការវិភាគសេដ្ឋកិច្ចនេះត្រូវបានចាត់ទុកថាជាបេក្ខភាពពិតប្រាកដសម្រាប់ការអនុវត្ត ដោយសារសកម្មភាពទាំងនេះសុទ្ធសឹងជាការវិនិយោគដែលផ្តល់ផលចំណេញ។ ក្នុងករណីដែលមានមូលនិធិក្នុងកម្រិតកំណត់ ការរួមបញ្ចូលសកម្មភាពសាកល្បង ១និង៣ គឺជាជម្រើសអាទិភាពខ្ពស់ បន្ទាប់មកគឺ គម្រោងសហគមន៍នៃសាទពាមក្រសោបជាអាទិភាពទីពីរ។ ក្នុងករណីមានមូលនិធិគ្រប់គ្រាន់ សម្រាប់ការវិនិយោគបន្ថែមទៀត គួរអនុវត្តសកម្មភាពទី ៤។

ចំណុចដែលបានលើកឡើងពីខាងដើម ដែលរួមទាំងការគិតគូរអំពីកត្តាសេដ្ឋកិច្ចនាំមកនូវអនុសាសន៍ដូចខាងក្រោម៖

[44] តួលេខទាបនៃ NPV (NPV(១០%)) បានប្រើប្រាស់សម្រាប់ការបង្ហាញនេះតែប៉ុណ្ណោះ

## ៥.១ អនុសាសន៍

ការវាយតម្លៃនេះផ្តល់អនុសាសន៍ដូចតទៅ៖

១. **អនុវត្តបង្កើសកម្មភាព ១, ៣ និង ៥៖ ការប្រែប្រួលអាកាសធាតុ និងការដាំដំណាំចម្រុះ ការអនុវត្តសាកល្បងពូជស្រូវស្រាល និងការគ្រងទឹកភ្លៀង ជាសកម្មភាពសាកល្បងមួយ ប៉ុន្តែនៅក្រោមកិច្ចសន្យាដាច់ដោយឡែកពីគ្នា ជាមួយ DAE/PDA, CARDI / PDA and PDWRAM**

២. **ពិចារណាអនុវត្តសកម្មភាព២៖ ការអភិវឌ្ឍសហគមន៍នេសាទពាមក្រសោប ក្នុងករណីដែលអាចទទួលការជានាពីក្រុមប្រឹក្សាឃុំ ក៏ដូចជា ស្ថាប័នគ្រប់គ្រងឧទ្យានជាតិ និងរដ្ឋបាលជលផល ទាក់ទងនឹងសកម្មភាពបន្ត និងការពង្រឹង នៅក្រោយឆ្នាំ ២០១៤។ កិច្ចការនេះគួរតែរួមបញ្ចូល ការប្តេជ្ញាផ្តល់ថវិកាបដិភាគខ្លះៗពីសហគមន៍ពាមក្រសោបផងដែរ។**

៣. **ពិចារណាអនុវត្តសកម្មភាព ៤ (ប្រព័ន្ធទុនបង្វិលសម្រាប់ចិញ្ចឹមសត្វ) ប្រសិនបើមាន NGO សមស្រប ឬ ជំនួយឥតសំណងប្រហែលគ្នានេះ សម្រាប់អនុវត្ត និងតាមដានជាបន្ត។**

៤. **ពិចារណាអនុវត្តសកម្មភាព ៦-៧ ក្រោយមានការពិគ្រោះយោបល់បន្ថែមជាមួយអង្គការនានាដែលអាចមានសក្តានុពលជាដៃគូ។**

ចំណុចទាំងអស់ខាងលើ ត្រូវដាក់ឲ្យមានការពិគ្រោះយោបល់ និងការចរចាបន្ថែមទៀត ជាមួយស្ថាប័នដៃគូ។ ជាការច្បាស់ណាស់ថា សកម្មភាព១ គួរតែចាប់ផ្តើមការអនុវត្តនៅតាមភូមិសាស្ត្រ មិនឲ្យយឺតជាងថ្ងៃទី១ ខែមករា ឆ្នាំ២០១៣ ដើម្បីត្រៀមខ្លួនជាស្រេចសម្រាប់អនុវត្តសកម្មភាពធំៗ (សាលាស្រែកសិករ) នៅខែមេសា ឆ្នាំ ២០១៣។

ការពិគ្រោះយោបល់ និងការចរចាទាំងនេះ អាចបង្ហាញឲ្យឃើញពីភាពចាំបាច់សម្រាប់កែសម្រួលទិដ្ឋភាពខ្លះៗនៃសកម្មភាពសាកល្បងដែលបានលើកស្នើ អនុលោមតាមទស្សនទាន ធនធាន និងអនុសាសន៍ពីស្ថាប័ននានា ដែលមានសក្តានុពលជាដៃគូទាំងនេះ។

# តារាងឯកសារយោង

*Adaptation knowledge Platform*, “Climate Change Adaptation: Finding the appropriate responses”, 2010.

*Adaptation Knowledge Platform*, ”Climate Change Adaptation: Factors of Choice, Effectiviness and Supporting Systems, 2011

*Adaptation Knowledge Platform,* “Climate Change Resilience in Coastal Cambodia: Adaptive Capacity & Human Development”, 2011

*Cambodia Climate Change Alliance*, “Coastal Adaptation and Resilience Planning Component, 2010.

*Climate Change and Resilience Component*, “Assessment of Community Vulnerability and Risks from Climate Change in the Coastal Zone of Cambodia”, June 2012

*Climate Change and Resilience Component*, “Assessment of Coping Strategies in the Coastal Zone of Cambodia”, June 2012

*Climate Change and Resilience Component,* “Vulnerability of Coastal Cultivation Systems”, June 2012.

*Cambodian National Mekong Committee*, “The state of Climate Change Management in Cambodia”, 2012

*Commune Data Bases 2012,* Target Communes, Sihanoukville and Koh Kong Provinces

*Danida*, ASSP Impact Assessment, Dhaka, 2003,

*Danida*, Mid-term Review of IMP Programme, Hanoi, 2003.

*EU*, “Smallholder Livestock Production Programme (SLPP) in Cambodia 2005-10, “Post Evaluation Report”, December 2011.

*EU,* “SPSP for MAFF, Fisheries and Livestock Sub-sectors, Draft Formulation Report”, May 2012.

*Ministry of Environment*, “Evaluation Report, Coastal Zone Management Project 1997-2007”, June 2007.

*Provincial Departments of Planning , Koh Kong and Shinaoukville* “Investment Plans”, 2011,2012

*Royal Government of Cambodia*, “National Adaptation Programme of Actions taken to Climate Change”, 2006

*Royal Government of Cambodia*: The Strategic Planning Framework for Fisheries, 2010-2019: Vol.II – Background Information (updated October 2010).

Annual Work Plan 2012 for Fisheries Strategic Framework.

*UNEP/Stockholm Environment Institute* "Rainwater Harvesting: A Lifeline for Human Well-Being". 2009

*UN-Habitat*, "Interim Report on Vulnerability to Climate Change in Sihanoukville Municipality", 2012

NAPA follow-up project documents

## ទំព័រក្នុងវេបសាយ

http://www.businessinsider.com/climate-change-vulnerability-2011-10, 2/2-2012

http://sdwebx.worldbank.org/climateportalb/home.cfm?page=country_profile, 25/2-2012,

http://www.thegef.org/gef/sites/thegef.org/files/documents/document/2-7-11%20-%20Webposting.pdf, 17/2-2012

http://www.sida.se/Global/Countries%20and%20regions/Asia%20incl.%20Middle%20East/Cambodia/Environmental%20Policy%20Brief%20Cambodia.pdf, 2/2-2012

http://www.wepa-db.net/policies/state/cambodia/seaarea.htm, 3/2-2012.